ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ

រាជរដ្ឋាភិបាលកម្ពុជា

កម្មវិធីស្តារឡើងវិញដោយ
មានជំនួយពីសហគមន៍អឺរ៉ុប
កម្មវិធីជួយសិក្សាធិការផ្នែកបឋមសិក្សានៅកម្ពុជា

# ទស្សនាវដ្ដី លេខ ៧

# គ្រូបង្រៀន



ខែ កក្កដា សីហា កញ្ញា ១៩៩៧


ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ

១២៨ B. មហាវិថីព្រះនរោត្តម (ភ្នំពេញ)

ទូរស័ព្ទ : ០១៥ ៩១៨ ១២៤

## I. គណៈកម្មការតំរង់ទិស-អំនាន និង តាមដាន

១- លោក យ៉ង់ ធី ប្រធាន
២- លោក ស៊ិន ងួនហេង សមាជិក
៣- លោក ណាត ប៊ុនរឿន សមាជិក
៤- លោក ធ សោ សមាជិក
៥- លោក ជា ជាតិ សមាជិក
៦- លោក ស៊ុង វ៉ាន់ថន សមាជិក
៧- លោកស្រី ហួរ ស៊ីរី សមាជិក
៨- លោក សង់ មីសែលឡឺប៊ិច សមាជិក
៩- លោក សេវា រិទ្ធ សមាជិក

## II. គណៈកម្មការតែងអត្ថបទ

១- លោក យ៉ង់ យ៉ាណូ
២- លោក ឆយ យីហ៊ាង
៣- លោក អ៊ុម កុច
៤- លោក កង ឱម
៥- លោក ពត សុត
៦- លោក ជិត សុកហេង
៧- អ្នកស្រី ផាន់ សំអោ
៨- អ្នកស្រី អិច សារ៉ូ
៩- លោក សំអាន សាយ
១០- លោក ប្រាក់ ព្រុំ
១១- លោកអធិការបឋមសិក្សានៅគ្រប់ខេត្ត - ក្រុងបណ្ដុះបណ្ដាលនៅមហាវិទ្យាល័យគរុកោសល្យ


# មាតិកាអត្ថបទ


ទំព័រ

**១- ពត៌មានស្ដីពីការបង្កើតទិវាគ្រូបង្រៀន**
- អនុក្រឹត្យស្ដីពីការបង្កើតទិវាគ្រូបង្រៀន ១
- អនុក្រឹត្យស្ដីពីការបន្ថែមប្រាក់កំរៃគរុកោសល្យ ជូនបុគ្គលិកសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ២
- សាររបស់រាជរដ្ឋាភិបាល ៣
- សន្ទរកថា សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ថ្លែងក្នុងឱកាស : ៥
  - ទិវាគ្រូបង្រៀន
  - ប្រគល់សញ្ញាប័ត្រ
  - សម្ពោធសមិទ្ធិផលមួយចំនួន

**២- វប្បធម៌នូវនៅ - ការអប់រំ**
- សីលធម៌ពលរដ្ឋ ៩
- ពលកម្ម ១០
- ប្រព័ន្ធអេកូ : ប្រព័ន្ធមានលំនឹង ១១
- ការប្រើពាក្យថ្មី ១២
- តើត្រូវគិតយ៉ាងណា នៅពេលសិស្សសួរយើង យើងឆ្លើយមិនរួច ១៣
- លទ្ធភាពរបស់មាតាបិតាសិស្ស និងសហគមន៍ ក្នុងការជួយសាលារៀនបឋមសិក្សា ១៤

**៣- គរុកោសល្យ - ការគ្រប់គ្រង**
- ភ្នំជ្រៃហួរញ្ញើ ១៨
- ទិសដៅនិងភារកិច្ចអប់រំយុវជននិងកីឡាឆ្នាំសិក្សា ១៩៩៧-៩៨ ២១
- សិស្សយើងខ្សោយតែងសេចក្ដីណាស់ ២៥
- ការទទួលខុសត្រូវរបស់គ្រូទទួលបន្ទុកថ្នាក់រៀន ៣៧
- យល់ដឹងពីជំងឺគ្រុនផ្ដាសាយ ៤០

**៤- វិញ្ញាសាប្រលងអធិការបឋមសិក្សាលើកទី ៤** ៤២

**៥- វេទិកាស្វែរិន ( សំនួរ - ប្រស្នា - ចំលើយ )** ៤៩

ក. សំនួរ :
  - ព្រះបាទអង្គឌួង
  - ព្រះបាទនរោត្តម
  - មាត្រដ្ឋាន

ខ. ចំលើយ - សំនួរ ក្នុងទស្សនាវដ្ដីលេខ ៦
  - បញ្ញាសជាតក
  - ប្រាសាទភ្នំជីសូរ

**៦. កំណាព្យ**
- ធម្មជាតិខ្ញុំអើយ ! ៥០
- ដំណឹងមរណភាព ៥៣



ទស្សនាវដ្ដីនេះ បោះពុម្ពដោយមានការរួមចំណែកជាបច្ចេកទេស និងហិរញ្ញវត្ថុ

**ពី កម្មវិធីទ្រទ្រង់ផ្នែកអប់រំបឋមសិក្សានៅកម្ពុជារបស់សហគមន៍អឺរ៉ុប**

Revue publiée avec le concours technique et financier
du Programme d'Appui au Secteur de l'Education Primaire
au Cambodge (PASEC) de l'Union Européenne.



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាល
លេខ : ៤៧ អនក្របក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតទិវាគ្រូបង្រៀន

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .
- . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .
- . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

## សំរេច

**មាត្រា ១ :** កំនត់យកថ្ងៃ ០៥ ខែ តុលា រៀងរាល់ឆ្នាំ ធ្វើជាទិវាជាតិ ឈ្មោះថា « ទិវាគ្រូបង្រៀន » នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ :** ក្រសួងអប់រំ យុវជន និងកីឡា មានភារកិច្ចអប់រំសិស្ស - និស្សិត និង សង្គម អំពីអត្ថន័យនៃ « ទិវាគ្រូបង្រៀន » និងបំផុសការអនុវត្ត អោយបានល្អនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣ :** សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀងៗ ខ្លួនអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៩៧

**នាយករដ្ឋមន្ត្រីទី ១** — **អ៊ុង ហួត**

**នាយករដ្ឋមន្ត្រីទី ២** — **ហ៊ុន សែន**

**កន្លែងទទួល :**
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យឯកឧត្តមនាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
- គ្រប់ក្រសួងស្ថាប័នថ្នាក់កណ្តាល
- គ្រប់សាលាខេត្ត - ក្រុង
- ដូចមាត្រា ៣
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
xxx x xxx

រាជរដ្ឋាភិបាល
លេខ : ០២ អនក្រ-បក
xxx x xxx

# អនុក្រឹត្យ
## ស្តីពីការបន្ថែមប្រាក់កំរៃតរុកោសល្យ ជូនបុគ្គលិកសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា

---

# រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .
- . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .
- . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

## សំរេច

**មាត្រា ១ :** ត្រូវបានបន្ថែមប្រាក់កំរៃតរុកោសល្យលើប្រាក់កំរៃតរុកោសល្យពីមុន ជូនបុគ្គលិកសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា មួយខែម្នាក់ ១១.៨០០ រៀល ។

**មាត្រា ២ :** ប្រាក់ឧបត្ថម្ភបន្ថែមដែលកំនត់ក្នុងមាត្រា ១ ត្រូវចាប់អនុវត្តពីថ្ងៃ ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ តទៅ ។

**មាត្រា ៣ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៤ :** អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៩៧

**នាយករដ្ឋមន្ត្រីទី ១** **នាយករដ្ឋមន្ត្រីទី ២**

**អ៊ឹង ហួត** **ហ៊ុន សែន**

**កន្លែងទទួល :**
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យឯកឧត្តមនាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
- ដូចមាត្រា ៣
- ឯកសារ - កាលប្បវត្តិ

# សាររបស់រាជរដ្ឋាភិបាល ក្នុងឱកាស « ទិវាគ្រូបង្រៀន » ថ្ងៃទី ៥ ខែ តុលា ថ្លែងដោយ ឯ. ស ហ៊ុន សែន សហនាយករដ្ឋមន្ត្រីទី២

- សូមថ្វាយបង្គំសម្តេចព្រះសង្ឃរាជទាំង ២ គណៈ និង ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- សូមគោរពជនរួមជាតិជាទីស្នេហា
- សូមគោរពលោកគ្រូ - អ្នកគ្រូ នៅទូទាំងព្រះរាជាណាចក្រកម្ពុជាជាទីស្រលាញ់រាប់អាន

« **ទិវាគ្រូបង្រៀន** » ដែលសម្តេច **ហ៊ុន សែន** បានលើកជាយោបល់ដំបូងនាឱកាសសន្និបាតបូកសរុបវាយតំលៃការងារអប់រំ យុវជន និង កីឡា ឆ្នាំសិក្សា ១៩៩៥ -១៩៩៦ និងទិសដៅភារកិច្ច ឆ្នាំសិក្សា ១៩៩៦ -១៩៩៧ មានគោលបំណងពង្រឹងឡើងវិញ នូវទំលាប់ល្អរបស់ប្រជាជាតិយើង នោះគឺ « គ្រូបង្រៀនជាឪពុកម្តាយទី ២ ដែលផ្តល់ចំណេះដឹង » ។ សីលធម៌សង្គមនេះ ដែលឆ្លុះបញ្ចាំងពីចរិតកត្តញ្ញូរបស់ជនជាតិខ្មែរ បានត្រូវរលាយស្ទើរតែសាបសូន្យ ក្នុងរបបប្រល័យពូជសាសន៍ ។ ឥឡូវនេះ រាជរដ្ឋាភិបាល បានសំរេចចេញអនុក្រឹត្យកំណត់យកថ្ងៃ ៥ តុលា រៀងរាល់ឆ្នាំ ជាទិវាជាតិ ដើម្បីរំលឹកគុណគ្រូបង្រៀន ដែលខ្ញុំព្រះករុណា ខ្ញុំមានជំនឿថា សង្គមទាំងមូលរីករាយគាំទ្រ និង លើកទឹកចិត្ត ។

ក្តីស្រមៃគ្រូបង្រៀន ដែលយើងគិតថា គ្មានអ្វីក្រៅពីចង់ឃើញសិស្សរបស់ខ្លួនក្លាយជាពលរដ្ឋល្អរស់នៅបានសមរម្យ ថ្លៃថ្នូរក្នុងសង្គម ហើយក៏គ្មានអ្វីរីករាយ និង មោទនៈជាងនៅពេលបានទទួលពាក្យគួរសមមួយម៉ាត់ពីអតីតសិស្ស ដែលបានក្លាយជាមន្ត្រីរាជការ ជាកងកំលាំងប្រដាប់អាវុធ ជាពាណិជ្ជករ ឧស្សាហករ ជាកម្មករ ជាកសិករ ។ ល ។

គឺក្នុងន័យនេះហើយ ដែលខ្ញុំ - ព្រះករុណា ខ្ញុំ ក្នុងនាមរាជរដ្ឋាភិបាល ក្នុងនាមឯកឧត្តម នាយករដ្ឋមន្ត្រីទី ១ និងសម្តេចនាយករដ្ឋមន្ត្រីទី ២ សូមចូលរួមអបអរសាទរ សប្បាយរីករាយជាមួយប្រជាពលរដ្ឋទាំងប្រុស ទាំងស្រី ទាំងចាស់ទាំងក្មេង នាឱកាសប្រារព្ធ « **ទិវាគ្រូបង្រៀន** » លើកទី ១ ក្នុងបរិយាកាស ដែលគ្រប់ស្ថាប័នរដ្ឋ ព្រះសង្ឃ សហគមន៍ជាតិទាំងអស់ កងកំលាំងប្រដាប់អាវុធ សិស្ស - និស្សិត ឯកភាពស្រុះស្រួលគ្នា បន្តនិរន្តរភាពនៃអ្វីទាំងអស់ ដែលជាសមិទ្ធផលនៃការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និង យុត្តិធម៌ នាឆ្នាំ ១៩៩៣ ។

ឆ្លៀតឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំព្រះករុណាខ្ញុំ សូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោកគ្រូ - អ្នកគ្រូ ទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលបាន និង កំពុងបំរើបុព្វហេតុអប់រំ យុវជន និង កីឡា ដោយមនសិការជាតិគួរអោយគោរពសរសើរ ទោះបីជាជីវភាពរស់នៅ នៅមានការខ្វះខាត មិនទាន់គ្រប់គ្រាន់យ៉ាងណាក៏ដោយ ។

ចំពោះរូបយើងទាំងអស់គ្នា ដែលមានលទ្ធភាពបំរើជាតិមកដល់សព្វថ្ងៃនេះ ក៏ដោយសារការអប់រំទូន្មានល្អរបស់លោកគ្រូ អ្នកគ្រូរបស់យើងដែរ ។ ប្រការនេះ ប្រជាពលរដ្ឋទាំងអស់ ប្រាកដជាទទួលស្គាល់គុណគ្រូបង្រៀនមិនអាចបំភ្លេចបានឡើយ ។

ដើម្បីញ៉ាំងអោយការប្រារព្ធពិធី « **ទិវាគ្រូបង្រៀន** » មានអត្ថន័យទូលំទូលាយចូលជ្រៅដល់សន្តានចិត្តយើងគ្រប់រូប ពិសេស កុមារា កុមារី សិស្សានុសិស្ស និស្សិតដែលជាទំពាំងស្នងឫស្សី ខ្ញុំព្រះករុណាខ្ញុំយល់ថា យើងទាំងអស់គ្នាដែលសព្វថ្ងៃកំពុងទទួលខុសត្រូវលើជោគវាសនារបស់ប្រទេសជាតិមាតុភូមិ តាមភារកិច្ច តួនាទីរៀងៗខ្លួន ត្រូវធ្វើជាគំរូល្អ សំដៅបង្កើនទំលាប់គោរពស្រលាញ់គ្រូបង្រៀនសំរាប់ជំនាន់យុវវ័យ ដែលថ្ងៃស្អែកគេទាំងនោះនឹងនិយាយច្រើនពីចាស់ៗជំនាន់មុន ។

គំរូល្អនៅត្រង់សហគមន៍មូលដ្ឋាននីមួយៗ រៀបចំ « **ទិវាគ្រូបង្រៀន** » អោយបានគ្រប់សាលារៀនដោយម្នាក់ៗ និយាយអោយសិស្សានុសិស្ស និងនិស្សិតស្តាប់ពីអនុស្សាវរីយ៍រវាងគ្រូ និង សិស្សជំនាន់មុន សំដៅអោយមនោសញ្ចេតនាគ្រូ សិស្សស្អិតស្អួរជារៀងរហូត ។

គំរូល្អ នៅត្រង់មាតា បិតា អាណាព្យាបាលណែនាំទូន្មានកូនចៅជាប្រចាំ អោយស្រលាញ់គោរពគ្រូបង្រៀន ទុកដាក់លោកដូចជាអ្នកមានគុណមួយរូបដែរ ។

គំរូល្អ នៅត្រង់ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យប្រដៅទូន្មានសិស្ស តាមទស្សនៈព្រះពុទ្ធសាសនាថា អំពើល្អមិនអាចរលាយសាបសូន្យឡើយ ។

គឺក្នុងមោទនភាពជាតិ តាងនាមរាជរដ្ឋាភិបាល តាងនាមឯកឧត្តមនាយករដ្ឋមន្ត្រីទី ១ និងសម្តេចនាយករដ្ឋមន្ត្រីទី ២ ជាថ្មីម្តងទៀត ខ្ញុំព្រះករុណាខ្ញុំ សូមជូនពរបវរសួស្តី មហាប្រសើរចំពោះលោកគ្រូ អ្នកគ្រូទូទាំងព្រះរាជាណាចក្រកម្ពុជា សូមជួបប្រទះតែនឹងសេចក្តីសុខចំរើនគ្រប់ប្រការ និងសូមអោយស្មារតីនៃ « **ទិវាគ្រូបង្រៀន** » ៥ តុលា នាំមកជាដំបូងនូវការឃោគយល់គ្នា ការសន្តោសប្រោសប្រណីគ្នា ហើយជាបន្តបន្ទាប់ ឈានដល់ការគោរពសិទ្ធិគ្នា រវាងជនជាតិកម្ពុជាគ្រប់រូប ។ អនាគតសន្តិភាព ការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការអភិវឌ្ឍ និង សុភមង្គលដែលជាបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់យើង នឹងបានសំរេចដោយយើងទាំងអស់គ្នា ។

**សូមអរព្រះគុណ សូមអរគុណ !**

# សុន្ទរកថា

## សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា

## ថ្លែងក្នុងឱកាស :

- **ទិវាគ្រូបង្រៀន**
- **ប្រគល់សញ្ញាប័ត្រ**
- **សម្ពោធសមិទ្ធិផលមួយចំនួន**

( មហាវិទ្យាល័យគរុកោសល្យ ថ្ងៃអង្គារ ទី២១ ខែ តុលា ឆ្នាំ១៩៩៧ )

xxx x xxx

- សូមក្រាបថ្វាយបង្គំ ព្រះតេជគុណ គ្រប់ព្រះអង្គជាទីសក្ការៈ
- ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រី និងនាងកញ្ញាទាំងអស់
- ប្អូនៗ គរុនិស្សិត និងសិក្ខាកាមទាំងអស់

ក្នុងឱកាសបើកបវេសនកាលថ្មីនេះ ដែលបានប្រព្រឹត្តទៅជាមួយនឹងទិវាគ្រូបង្រៀនជាលើកដំបូង ហើយរួមនឹងបុណ្យផ្កាសាមគ្គីជាតិរំលឹកគុណគ្រូកំពុងដំណើរការ ដោយមានការចូលរួមយ៉ាងច្រើនកុះករពីគ្រប់មូលដ្ឋាន ថ្ងៃនេះ ភរិយាខ្ញុំ និងខ្ញុំ មានកិត្តិយសបានមកកាន់ទីនេះ ដើម្បីចូលរួមបើកវគ្គគ្រប់គ្រងដល់មន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និងចូលរួមសម្ពោធសមិទ្ធិផលមួយចំនួនទៀតរបស់មហាវិទ្យាល័យ ដែលជាទីកន្លែងមួយក្នុងរយៈពេល ១៨ឆ្នាំមកនេះ បានបណ្ដុះបណ្ដាល និងបំពាក់បំប៉នគ្រូបង្រៀនបានចំនួន ១៣៥វគ្គ ដែលនៅក្នុងនោះ មានមុខសញ្ញារៀនសូត្រចំនួន ១៥.៧០០០នាក់ ។

ខ្លឹមសារទាំង ៥ ដែលយើងរំលឹក និងប្រារព្ធនាពេលនេះ សុទ្ធតែមានគោលបំណងរួមតែមួយ គឺជំរុញ និងលើកស្ទួយដល់វិស័យអប់រំសិក្សារបស់យើង ។ ដើម្បីមើលឃើញច្បាស់ពីភាពចាំបាច់ សារៈសំខាន់ និង តំលៃរបស់វិស័យអប់រំសិក្សា យើងចាំបាច់ត្រូវមើលឃើញអោយច្បាស់ពីភាពចាំបាច់ សារៈសំខាន់ និងតំលៃរបស់អ្នកបង្រៀន ហើយភាពចាំបាច់ សារៈសំខាន់ និងតំលៃរបស់អ្នកបង្រៀន អាចអោយយើងឃើញច្បាស់នៅពេលដែលយើងចាត់ទុកថា កុមារា កុមារី យុវជន យុវនារី សិស្ស និស្សិតរបស់យើងមានតំលៃថា ជាអាយុជីវិតនៃអនាគតរបស់ប្រទេសជាតិ ។

ហេតុនេះហើយ មុនបង្អស់ ខ្ញុំសូមលើកឡើងអំពីការចាំបាច់នៃការលើកស្ទួយគុណភាពបង្រៀន និងរៀន ដែលប្រការនេះ វាទាក់ទងមុនគេបង្អស់ទៅដល់គរុកោសល្យ ដែលយើងទើបនឹងធ្វើការកែទំរង់យ៉ាងសកម្ម ។

ទស្សនៈមុននេះ អំពីការបង្រៀន គឺសកម្មភាពរបស់គ្រូបង្រៀនច្រើនសង្កត់ធ្ងន់ពីការបង្រៀនរបស់ខ្លួន ដើម្បីផ្ដល់ចំណេះអោយដល់សិស្ស ប្រៀបដូចជាការដងទឹកពីពាងមួយទៅពាងមួយទៀត រឺ អាចនិយាយបានថា ផ្ដល់ចំណេះពីគ្រូទៅសិស្ស ។ រីឯសកម្មភាពរបស់សិស្សវិញ គឺគ្រាន់តែអង្គុយស្ដាប់ ការពន្យល់ កត់ត្រា តាមការពន្យល់របស់គ្រូ យល់តាមការពន្យល់របស់គ្រូ ។

ឥឡូវនេះ ទស្សនៈនៃការបង្រៀន មិនមែនដូចមុននេះទៀតទេ ដែលត្រឹមតែធ្វើអោយសិស្សកត់តាម ថាតាមយល់តាមនូវអ្វីដែលគ្រូបង្រៀនបានលើកឡើងនោះទេ ។ មុខសញ្ញានៃការផ្លាស់ប្តូរថ្មី នៃគរុកោសល្យ បច្ចុប្បន្ន គឺការផ្តេកទៅលើសកម្មភាពរបស់សិស្ស ក្នុងការរៀនសូត្រ អ្វីជាស្នូល និងនិយាយដោយខ្លី គឺយកសិស្សធ្វើជាមជ្ឈមណ្ឌលនៃសកម្មភាពរៀនសូត្រ ។ ហេតុនេះ ការបង្រៀនរបស់គ្រូ គឺត្រូវពង្រីកតួនាទីសកម្មរបស់សិស្សអោយសិស្សធ្វើចលនា ធ្វើសកម្មភាពរៀនសូត្រ ត្រិះរិះពិចារណា និងពិភាក្សារវាងសិស្ស និងសិស្ស រវាងសិស្ស និងគ្រូ ។ គរុកោសល្យថ្មី គឺធ្វើអោយសិស្សម្នាក់ៗ ចូលជ្រៅទៅក្នុងខ្លឹមសារមេរៀន ដើម្បីទទួលយកការយល់ដឹងដោយខ្លួនឯង និងរីកចំរើនដោយខ្លួនឯង ។ គឺសិស្សជាអ្នកទទួលទានអំពៅដោយខ្លួនឯង ដោយជញ្ជក់យកជាតិស្ករដោយខ្លួនឯង ហើយលេបជាតិស្ករនោះដើម្បីភាពរីកចំរើន ។ មិនមែនគ្រូជាអ្នកទទួលទានអំពៅ ហើយជញ្ជក់យកជាតិស្ករនោះទៅបញ្ចុកអោយដល់សិស្សនោះឡើយ ។ គរុកោសល្យថ្មី គឺយកសិស្សធ្វើជាមជ្ឈមណ្ឌល ហើយពង្រីកតួនាទីសកម្មរបស់សិស្សក្នុងការរៀនសូត្រ ក្នុងការបញ្ចេញយោបល់ រហូតដល់ក្លាយទៅជាពលរដ្ឋមួយដែលមានទំលាប់ល្អក្នុងការចេះវែកញែក គឺចំណុចនោះហើយ ដែលជាប្រភពនៃលទ្ធិប្រជាធិបតេយ្យរបស់សង្គម ។ គ្មានការសិក្សា គឺគ្មានលទ្ធិប្រជាធិបតេយ្យឡើយ រឺមិនដូច្នោះទេ ប្រជាធិបតេយ្យវាត្រឹមតែជារបស់បុគ្គលណាមួយនោះ រឺក្រុមណាមួយនោះតែប៉ុណ្ណោះ ។ ហើយបើបុគ្គលនោះ ក្រុមនោះ ជាមនុស្សខ្វះមនសិការជាតិទៀតនោះអ្វីដែលគេនិយាយពីប្រជាធិបតេយ្យ វាគ្រាន់តែជាមធ្យោបាយដ៏សាហាវមួយ មិនខុសពីគ្រាប់កាំភ្លើង ដើម្បីស្វែងរកអំណាចតែប៉ុណ្ណោះ ។ ចំពោះខ្ញុំ ខ្ញុំតែងតែយល់ថា ដើម្បីលទ្ធិប្រជាធិបតេយ្យយើងត្រូវការ ការអប់រំសិក្សាដល់គ្រប់ប្រជាពលរដ្ឋទាំងមូលដោយស្មើភាព ហេតុនេះ យើងត្រូវការសាលារៀន យើងត្រូវការគ្រូបង្រៀន ដែលនោះគឺជាមធ្យោបាយដ៏រឹងមាំនិងល្អបរិសុទ្ធបំផុត ដើម្បីកសាងប្រទេសជាតិអោយដើរតាមលទ្ធិប្រជាធិបតេយ្យដ៏ពិតប្រាកដមួយ ។ គេក៏មិនអាចនិយាយពីលទ្ធិប្រជាធិបតេយ្យបានដែរ ប្រសិនបើបរទេសនៅតែដាក់ការគាបសង្កត់ នៅតែលូកដៃចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសយើង ហើយប្រការនេះ គេអាចធ្វើទៅបានក៏ដោយសារប្រទេសយើងនៅមានអ្នកនយោបាយខ្លះ ដែលចេះតែផ្អែកទៅលើបរទេសជាងលើខ្លួនឯង និង ក្នុងករណីដែលយើងនៅមានអ្នកមិនចេះអក្សរ យើងនៅតែមានកង្វះសាលារៀនយ៉ាងច្រើនដូចនេះ ។ ទោះបីមកដល់សព្វថ្ងៃនេះ ខ្ញុំបានជួយដល់ការកសាងសាលារៀនបានជាង ១៦០០ ខ្នងក្តី ប៉ុន្តែ ជារួមពីឥឡូវនេះទៅដល់ឆ្នាំ ២០០០ យើងនឹងត្រូវនៅខ្វះអាគារសិក្សាប្រមាណ ៥០០០ខ្នងថែមទៀត ។ នេះជាការលំបាកដ៏ធ្ងន់ធ្ងរមួយ ប៉ុន្តែខ្ញុំយល់ថា បើយើងរួមទាំងអស់គ្នា ដើម្បីរកដំណោះស្រាយនោះ យើងនឹងអាចដោះស្រាយបានជាមិនខាន ។ នោះហើយជាលទ្ធិប្រជាធិបតេយ្យ ក្នុងការអនុវត្តន៍ជាលទ្ធិប្រជាធិបតេយ្យដែលយើងកសាង និងពង្រីកឡើងចាប់ផ្តើមពីប្រភពរបស់វា គឺពីការផ្តល់នូវចំណេះដឹង ផ្តល់នូវលទ្ធភាពពិចារណា វិភាគដល់មនុស្សគ្រប់ៗ រូប ។

ក្នុងបុព្វហេតុនេះហើយ ដែលយើងទាំងអស់គ្នានៅទីនេះ សូមអបអរសាទរចំពោះគរុនិស្សិត ដែលបានបញ្ចប់ការសិក្សាជាសាស្ត្រាចារ្យមធ្យមសិក្សាក៏រិត ២ អបអរសាទរវគ្គអធិការមធ្យមសិក្សា និងបឋមសិក្សា ព្រមទាំងអបអរសាទរចំពោះវគ្គគ្រប់គ្រងមន្ត្រីក្រសួងអប់រំ ដែលបានបើកវគ្គថ្មីនាពេលនេះ ហើយសូមនិយាយទៅកាន់ប្អូនៗ ជាគរុនិស្សិតដោយស្និទ្ធស្នាលថា :

- ទី ១ : តាមគរុកោសល្យថ្មីនេះ ការពង្រីកសកម្មភាពរបស់សិស្សក្នុងការរៀនសូត្រ មិនមែនមានន័យថាបន្ថយចុះនូវតួនាទីរបស់អ្នកបង្រៀននោះទេ ។ ផ្ទុយទៅវិញ តួនាទីរបស់អ្នកបង្រៀនកាន់តែមានសារៈសំខាន់ជាងមុនទៅទៀត ក្នុងការធ្វើអោយសិស្សចេះធ្វើសកម្មភាព ហើយសកម្មភាពអ្នកបង្រៀនមិនស្ថិតនៅត្រឹមបង្រៀនតែប៉ុណ្ណោះទេ ។ បង្រៀនកំពុងមានន័យថ្មីមួយទៀត គឺដើម្បីសកម្មភាព និងចលនារៀនសូត្ររបស់សិស្ស ដែលប្រការនេះ វាធ្វើអោយអ្នកបង្រៀនត្រូវហត់នឿយជាងមុនទៅទៀត ។

- ទី ២ : តាមការបណ្តុះបណ្តាលគ្រូបង្រៀនរបៀបថ្មី ដូចជាករណីនៅប្រទេសបារាំង គេក៏បានប្តូរពីការបណ្តុះបណ្តាលអ្នកបង្រៀនសំរាប់បឋមសិក្សាផ្សេង សំរាប់មធ្យមសិក្សាផ្សេង ទៅជាការបណ្តុះបណ្តាលអ្នកបង្រៀន ដែលមានលទ្ធភាពបង្រៀនបានទាំងនៅបឋមសិក្សាផង និងទាំងនៅមធ្យមសិក្សាផង ។ ហេតុនេះ ជាសាស្ត្រាចារ្យបឋមសិក្សា គឺពិតជាមានលទ្ធភាពខុសគ្នាពីសាស្ត្រាចារ្យមធ្យមសិក្សាតែមួយមុខ ព្រោះថា មហាវិទ្យាល័យគរុកោសល្យយើង បានបង្ហាត់បង្ហាញប្អូនៗ អោយចេះបង្រៀន ទាំងនៅបឋមសិក្សាផង និងនៅមធ្យមសិក្សាផង ។

**ប្អូនៗ គរុនិស្សិត និង សិក្ខាកាមទាំងអស់**

ទិវាគ្រូបង្រៀនដែលខ្ញុំបានផ្តួចផ្តើមគំនិតស្នើសុំរាជរដ្ឋាភិបាល តាំងពីឆ្នាំមុនមក ឥឡូវនេះ ត្រូវបានសំរេចយកថ្ងៃទី ០៥ តុលា រៀងរាល់ឆ្នាំដែលជាថ្ងៃបើកបវេសនកាល ធ្វើជាទិវាគ្រូបង្រៀន ។

កាលពីឆ្នាំទៅនៅប្រទេសស្វីស ក្នុងពេលប្រារព្ធទិវាគ្រូបងៀន គេក៏បានបង្ហាញឆន្ទៈចង់អោយគ្រូបង្រៀន ៥០ លាននាក់ ជាសមាជិកនៅលើពិភពលោក ដែលក្នុងនោះមាន ៨ ម៉ឺននាក់ ចូលជាគ្រូបង្រៀនកម្ពុជា ឯកភាពគ្នា សាមគ្គីគ្នាចេះជួយគ្នាទៅវិញទៅមក ក្នុងការបង្កើនវិជ្ជាជីវៈ ការជួបគ្នាអំពីមធ្យោបាយ និងជួយគ្នាដើម្បីដោះស្រាយចំណោទសង្គមដែលកំពុងចោទមកលើសាលារៀន ។

ពិភពលោកសព្វថ្ងៃនេះ គឺជាពិភពលោកមួយដែលកំពុងមានការរីកចំរើនខ្លាំងខាងវិទ្យាសាស្ត្រ បច្ចេកវិទ្យា ដែលគេអោយឈ្មោះថា ជាសម័យកុំព្យូទ័រ ។ ជាមួយនឹងផលប្រយោជន៍ពីការរីកចំរើននេះ វាក៏បានផ្តល់នូវការលំបាកជាច្រើនដល់បណ្តាប្រទេសក្រីក្រ និងប្រទេសកំពុងអភិវឌ្ឍនៅពិភពលោកដែរ ។

កុមារកាន់តែច្រើន បានចំណាយពេលរៀនសូត្រផង ពេលមើលទូរទស្សន៍ផង ឆ្លងតាមនេះ កុមារមើលឃើញច្បាស់នូវភាពផ្ទុយគ្នាដ៏ធំធេងរវាងសំណូមពរសិក្សា និងសំណូមពរជីវភាពសង្គម ។ សិស្សម្នាក់ៗ ចូលទៅក្នុងថ្នាក់រៀនដោយនាំទៅជាមួយនូវស្នាមរូបភាពពិភពលោកដ៏ពិតប្រាកដមួយ ដែលឆ្ងាយហួសពីព្រំដែននៃការអប់រំរបស់សាលារៀន ។ លើសពីនេះទៀត គេបានទុកចោលនូវបញ្ហាជាច្រើននៅនឹងមាត់ទ្វារសាលារៀន ដូចជាបញ្ហាក្រីក្រ បញ្ហាអត់ឃ្លាន បញ្ហាគ្រឿងញៀន បញ្ហាជំងឺ អេដស៍ អំពើហឹង្សា ។ល។ និង ។ល។ ដែលត្រូវបាននាំចូលជាមួយសិស្សទៅក្នុងសាលារៀន ។

ដោយឡែកនៅកម្ពុជាយើងវិញ បញ្ហា និងការលំបាកអាចនៅមានច្រើនជាងនេះទៅទៀត ដោយយើងត្រូវលុបបំបាត់ចោលនូវផលវិបាកបន្សល់ទុកដោយសង្គ្រាម ៥ ឆ្នាំ ១ ខែ ព្រមទាំងរបបប្រល័យពូជសាសន៍ ប៉ុលពត ៣ឆ្នាំ ៨ខែ ២០ថ្ងៃ រួមទាំងការបន្តសង្គ្រាមមកលើមាតុភូមិយើង អស់រយៈជាច្រើនឆ្នាំទៀតផង ។

គឺស្ថិតក្នុងស្ថានភាពបែបនេះហើយ និងនៅចំពោះមុខបរិបទបច្ចុប្បន្ននៃពិភពលោក ដែលវិស័យអប់រំ សាលារៀន និងគ្រូបង្រៀនទាំងអស់នៅកម្ពុជាយើង កាន់តែមានតួនាទី និងសារៈសំខាន់ខ្លាំងឡើងៗ ។ នេះហើយជាអត្ថន័យដំបូងបំផុតនៃទិវាគ្រូបង្រៀនសំរាប់នៅកម្ពុជាក្តី និងនៅលើពិភពលោកក្តី ។

ម្យ៉ាងវិញទៀត ចាប់តាំងពីឆ្នាំ ១៩៧៩ មក គ្រូបង្រៀនកម្ពុជាមានគុណបំណាច់ដ៏ពិសេសបំផុត ដែលទោះបីនៅក្នុងស្ថានភាពបាតដៃទទេយ៉ាងណាក្តី ក៏នៅតែខំបំពេញភារកិច្ចរបស់ខ្លួនដើម្បីជាតិ និងមាតុភូមិ ដោយគ្មានត្អូញត្អែរ ។ ឥឡូវនេះ អំរែកជីវភាពកំពុងសង្កត់ធ្ងន់ទៅលើគ្រូបង្រៀន ប៉ុន្តែអ្វីៗ ដែលគ្រូបង្រៀនយើងបានបំពេញក្នុងរយៈពេល ១៨ឆ្នាំនេះ ពិតជាមិនអាចកាត់ថ្លៃបានទេ ។ ប៉ុន្តែ ក្រោយឆ្នាំ១៩៩៣ ការមើលស្រាលមកលើគ្រូបង្រៀនក៏ចេះតែកើតមានឡើង

ជាលំដាប់ ដោយមិនបានមើលឃើញពីការលះបង់ដ៏ធំធេងរបស់គ្រូបង្រៀនឡើយ ។ ប្រការនេះហើយ ដែលជាអត្ថន័យជំរុញអោយខ្ញុំផ្ដើមគំនិតឡើង ដើម្បីសុំបង្កើតប្រារព្ធទិវាគ្រូបង្រៀនសំដៅនាំគ្នាសំដែងនូវការគោរពដឹងគុណដល់គ្រូបង្រៀនដែលបានលះបង់គ្រប់បែបយ៉ាង ជាពិសេស ក្នុងស្ថានភាពដ៏លំបាកនៃជីវភាពរបស់យើងទាំងអស់គ្នា ។ ជាមួយគ្នានេះដែរ ការផ្ដួចផ្ដើមធ្វើបុណ្យផ្កាសាមគ្គីជាតិរំលឹកគុណគ្រូបង្រៀន ពិតមែនតែខ្ញុំគិតដល់កត្តាសកម្មភាពច្រើន ទាំងផ្នែកសេដ្ឋកិច្ច ផ្នែកសង្គម ហើយដែលលទ្ធភាពដំបូងនេះ គឺចង់ជួយដល់ការបណ្ដុះបណ្ដាលគ្រូបង្រៀន ប៉ុន្តែ អ្វីដែលខ្ញុំចង់បានបំផុត គឺការធ្វើអោយសង្គមទាំងមូល មានការលើកទឹកចិត្តដល់គ្រូបង្រៀន ដែលកំលាំងនោះហើយ អាចបង្កើតបាននូវរលកថ្មីនៃគំនាស់សេដ្ឋកិច្ច និងការអភិវឌ្ឍរាប់ទាំងការអភិវឌ្ឍដើម្បីប្រជាធិបតេយ្យនៅកម្ពុជាជាអចិន្ត្រៃយ៍ផង ។

**ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រី និងនាងកញ្ញាទាំងអស់**

ក្នុងពិធីបុណ្យផ្សេងៗ រឺក្នុងពេលដែលគេជួបការលំបាក គេតែងតែបន់ស្រន់រំលឹកគុណទាំង ៣ គឺគុណព្រះរតនៈត្រ័យ គុណមាតាបិតា និងគុណគ្រូបាធ្យាយប្រការនេះក៏សរបញ្ជាក់អោយឃើញថា គ្រូបង្រៀន គឺជាមនុស្សដ៏សំខាន់មួយរូបក្នុងសង្គម ហើយត្រូវបានសង្គមគោរព និងស្រលាញ់រាប់អាន ។ ប៉ុន្តែ កិច្ចតបស្នងវិញ សង្គមបច្ចុប្បន្ននៅតែមិនទាន់មានលទ្ធភាពសំរាប់ជួយដល់គ្រូបង្រៀន ដើម្បីបំពេញភារកិច្ចអោយបានល្អគ្រប់គ្រាន់នៅឡើយ ។ មានតែការផ្អែកលើខ្លួនយើងជាមូលដ្ឋាន មានតែការរួមគ្នាដើម្បីដោះស្រាយការលំបាកជាមួយគ្នានោះទេ ទើបយើងនឹងអាចឆ្លងកាត់ការលំបាកទាំងឡាយបាន ដើម្បីសំរេចគោលដៅនូវសង្គមជាតិមួយដ៏រុងរឿងតាមបំណងប្រាថ្នារបស់យើងបាន ។ ទោះបីនៅក្នុងការលំបាកអំពីសេដ្ឋកិច្ចយ៉ាងណាក៏ដោយ ក៏យើងនៅតែបន្តខិតខំបណ្ដុះបណ្ដាលគ្រូបង្រៀនដែលក្នុងនោះ យើងបានព្យាករណ៍ហើយថាពីឆ្នាំនេះទៅដល់ឆ្នាំ ២ ០០០ យើងត្រូវនៅខ្វះគ្រូបង្រៀនចំនួន ៣ ០០០នាក់ក្នុងមួយឆ្នាំៗ ។ ក្នុងន័យនេះហើយដែលខ្ញុំសូមថ្លែងអំណរគុណជូនចំពោះសាលាគរុកោសល្យទាំងអស់ និងមហាវិទ្យាល័យគរុកោសល្យនេះ ដែលបានជំនះគ្រប់ការលំបាកក្នុងការបណ្ដុះបណ្ដាលដល់គ្រូបង្រៀន ។

ក្នុងនាមរាជរដ្ឋាភិបាល ក្នុងនាមឯកឧត្ដម **អ៊ុង ហួត** នាយករដ្ឋមន្ត្រីទី ១ និងក្នុងនាមខ្ញុំផ្ទាល់ ព្រមទាំងភរិយាខ្ញុំសូមថ្លែងនូវការដឹងគុណចំពោះគ្រូបង្រៀននៅទូទាំងប្រទេស ហើយសូមជឿជាក់ថា ខ្ញុំនឹងស្ថិតនៅជាមួយលោកគ្រូ - អ្នកគ្រូសាស្ត្រាចារ្យ បុគ្គលិកសិក្សាទាំងអស់ ដើម្បីជំនះការលំបាកជាមួយគ្នាក្នុងការនាំកូនចៅរបស់យើងឆ្ពោះទៅរកពន្លឺវិជ្ជា និងពន្លឺដែលជាប្រភពនៃភាពរុងរឿងលើគ្រប់វិស័យ ។

ក្នុងគំនិតដឹងគុណនេះ ភរិយាខ្ញុំ និងខ្ញុំ ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ នឹងប្រារព្ធពិធីប្រគល់សញ្ញាប័ត្រជូនដល់គរុនិស្សិត និងសិក្ខាកាមអធិការបឋមសិក្សា និងមធ្យមសិក្សា ព្រមទាំងការបើកវគ្គគ្រប់គ្រងដល់មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។

ភរិយាខ្ញុំ និងខ្ញុំ សូមប្រគេនពរ និងជូនពរបវរសួស្ដី ដល់បវេសនកាលថ្មី ហើយសូមអោយឯកឧត្ដម និងលោកជំទាវ អស់លោក លោកស្រី នាងកញ្ញា និងគ្រូបង្រៀនទាំងអស់ ព្រមទាំងនិស្សិត និងសិស្សានុសិស្សទាំងអស់ សូមប្រកបដោយពុទ្ធពរទាំង ៥ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ បដិភានៈ និងពរពីប្រការទៀត គឺអភិវឌ្ឍន៍ និង សុភមង្គលកុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរព្រះគុណ និង អរគុណ !**




# សីលធម៌ពលរដ្ឋ
## La morale civique

ការអប់រំសីលធម៌ពលរដ្ឋ នៅក្នុងសាលារៀន មានសារៈសំខាន់ណាស់ ។ សព្វថ្ងៃនេះ សង្គមខ្មែរហាក់ដូចមិនសូវយកចិត្តទុកដាក់ដល់ការអភិវឌ្ឍខាងស្មារតី សីលធម៌ និង មនុស្សធម៌ ។ មនុស្សមួយចំនួន គិតតែពីផ្នែកសំភារៈ គិតតែពីទ្រព្យសម្បត្តិ ទោះជាទ្រព្យសម្បត្តិនោះកើតឡើងក្នុងអំពើអសីលធម៌ក៏ដោយ ពោលគឺគេអោយតំលៃតែទៅលើភាពហ៊ឺហា ខ្ពស់មុខ ខ្ពស់មាត់ សំរាប់ខ្លួនគេតែប៉ុណ្ណោះ ។ ទាំងអស់នេះ បណ្ដាលមកពី លោភៈ ទោសៈ មោហៈ ខ្វះសីលធម៌ ដែលគ្របសង្កត់មកលើខ្លួនគេ ដែលធ្វើអោយខ្លួនគេមើលពុំឃើញនូវតំលៃពិតរបស់សង្គម និងរបស់មនុស្សនៅលើពិភពផែនដីនេះ ។ អាស្រ័យហេតុនេះ ទើបយើងសង្កេតឃើញថា នៅក្នុងសង្គមជាតិយើង គេតែងជួបប្រទះនូវការកាប់សំលាប់ និងសង្គ្រាមមិនឈប់ឈរ ដែលជាប្រភពធ្វើអោយសង្គមជាតិយើងអាប់អោនកិត្តិយស ពីមួយថ្ងៃទៅមួយថ្ងៃ ។

តំលៃរបស់ជាតិនីមួយៗ ស្ថិតនៅត្រង់ពលរដ្ឋម្នាក់ៗ មាន ៖

១. ចំណេះដឹង វិទ្យាសាស្ត្របច្ចេកទេស

២. សីលធម៌ ចរិយាធម៌សមរម្យជាមនុស្សពិត ស្គាល់ខុស ស្គាល់ត្រូវ ស្គាល់ល្អ ស្គាល់អាក្រក់ ដែលមិនយកកំលាំង ចង្កូម និងក្រញាំជើងជាទីអាង ។

៣. អាជីវកម្មប្រកបដោយសម្មាអាជីវោ និងសុចរិត តាមសមត្ថភាពរបស់ខ្លួន ។

ដើម្បីសំរេចលក្ខណៈសម្បត្តិខាងលើនេះ គ្រួសារ សាលារៀន សហគមន៍ មានភារកិច្ចរួមគ្នា ក្នុងការកសាងសង្គមជាតិ ខាងផ្នែកសីលធម៌ ។ ការកសាងមនុស្សម្នាក់ៗ អោយមានអាកប្បកិរិយាថ្លៃថ្នូរ ជាវិភាគទានទាំអោយសង្គមជាតិមានតំលៃ ( valeur de la société ) ។

បច្ចុប្បន្នកាលនេះ តាមរយៈការសិក្សាពលរដ្ឋវិទ្យា សាលារៀនត្រូវតែបំពេញបេសកកម្ម ៤ យ៉ាងគឺ :

១. កសាង និង អភិវឌ្ឍបុគ្គលិកលក្ខណៈរបស់កុមារ អោយបានល្អប្រសើរ ចេះគោរពច្បាប់ ចេះអនុវត្តតួនាទីរបស់ខ្លួនជាប្រជាពលរដ្ឋម្នាក់នាពេលអនាគត ដើម្បីអោយសក្តិសមជាទំពាំងស្នងឫស្សី និងជាសសរទ្រូងនៃប្រទេសជាតិ

២. អប់រំយុវជនអោយចេះយោគយល់គ្នា ស្គាល់តំលៃសន្តិភាព ស្គាល់ន័យនៃជីវិត ខាងផ្លូវលោក និងផ្លូវធម៌

៣. អប់រំយុវជន អោយរៀនរស់នៅ អោយបានសុខដុមរមនា ជាមួយមនុស្សដទៃនៅក្នុងសង្គមទោះបីមានសាសនាផ្សេងៗ គ្នាក៏ដោយ

៤. អប់រំយុវជនអោយចេះឈ្លាសចំពោះសង្គម ដោយចង់អោយសង្គមមនុស្សមានការអភិវឌ្ឍគ្រប់វិស័យ ទាំងផ្នែកសំភារៈ និងស្មារតី ។

យ៉ង់ ធី

# ពលកម្ម
# Le travail

## I. តំលៃពលកម្ម ( valeur du travail )

ពលកម្មជាសកម្មភាពដ៏មានតំលៃខ្ពស់បំផុត ។ មនុស្សមានជីវិតរស់នៅ និងមានសុភមង្គលដោយសារពលកម្ម ។ សុភមង្គលដែលកើតឡើងដោយសារពលកម្មគឺជាសុភមង្គលប្រកបដោយសេចក្ដីថ្លៃថ្នូររុងរឿង ។

តំលៃពលកម្មចែកចេញជា :

**១. តំលៃសេដ្ឋកិច្ច : ( valeur économique )**

ដើម្បីរស់នៅ មនុស្សត្រូវការសម្បត្តិសំភារៈផង និង សម្បត្តិស្មារតីផង ។ សម្បត្តិសំភារៈចាំបាច់គឺ : ចំណីអាហារ សំលៀកបំពាក់ ផ្ទះសំបែង ។ សម្បត្តិស្មារតីចាំបាច់គឺ : សៀវភៅ ទស្សនាវដ្ដី សារពត៌មាន សិល្បៈ ។ ជនណាដែលពុំបានផលិតអ្វីសោះ ជននោះពិតជាពឹងផ្អែកលើកំលាំងគ្រួសារ និងកំលាំងសង្គម ។

**២. តំលៃសីលធម៌ : ( valeur morale )**

មនុស្សដែលរស់នៅដោយសារពលកម្មរបស់ខ្លួន អ្នកនោះមិនមែនជាពួកបញ្ញើក្អែក រឺពួកឆក់ប្លន់ទេ ។ គេមានអារម្មណ៍រីករាយដោយសារគេបានធ្វើអោយខ្លួនគេ និងប្រជាជនសំបូរសប្បាយ ។

**៣. តំលៃបញ្ញា : ( valeur intellectuelle)**

ពលកម្ម ពិសេសពលកម្មច្នៃប្រឌិត ( travail créatif ) ជាកត្តាដែលធ្វើអោយមនុស្សមានបញ្ញាវាងវៃ និងបើកទូលាយពុទ្ធិមនុស្ស ។ វិទ្យាសាស្ត្រ បច្ចេកទេស កាន់តែរីកចំរើនរៀងរាល់ថ្ងៃដោយសារពលកម្មនេះ ។

**៤. តំលៃសោភណ : ( valeur esthétique )**

ពលកម្មបានធ្វើអោយគេបង្ហាន អគារ វិមាន ប្រាសាទ លេចឡើងប្រកបដោយសោភណភាពគួរជាទីចាប់ចិត្តនៅគ្រប់សម័យកាល ។

មនុស្សដែលប្រកបការងារបានល្អ គឺជាមនុស្សដែលគិតអំពីគុណភាពនៃពលកម្ម ។ លទ្ធផលនេះ កើតឡើងដោយចំណាត់តាំងការងារល្អ ដោយការកែច្នៃឧបករណ៍ពលកម្ម និងការលើកកំពស់បច្ចេកទេស ។

## II. វិន័យពលកម្ម ( Discipline du travail )

ការងារមិនអាចប្រព្រឹត្តទៅបានល្អឡើយ ប្រសិនបើខ្វះវិន័យ ។ វិន័យដែលកើតឡើងដោយការកៀបសង្កត់ មិនទាន់មានលក្ខណៈល្អទេ ។ វិន័យដែលកើតឡើងដោយសេចក្ដីភ្ញាក់រលឹកជាវិន័យដែលមិនអាចកាត់ថ្លៃបាន ។ វិន័យពលកម្មគឺការអនុវត្តតាមសណ្ដាប់ធ្នាប់មួយជាកំណត់ ដើម្បីស្វែងរកបរិមាណ និងគុណភាពនៃពលកម្ម ។

អាកប្បកិរិយា ដែលមកធ្វើការយឺតយូរក្រោយម៉ោងកំណត់ ត្រលប់ទៅវិញមុនម៉ោងកំណត់ ខ្វះស្មារតីទទួលខុសត្រូវជាអាកប្បកិរិយាអន់ថយនៅក្នុងសង្គម ។ ត្រូវប្រឆាំងចំពោះសេចក្ដីខ្ជិលច្រអូស ស្អប់ខ្ពើមពលកម្ម ។

## II. ការអប់រំអោយមានស្មារតីស្រលាញ់ពលកម្ម ( éducation à l'amour du travail )

ការអប់រំមនុស្សអោយមានស្មារតីស្រលាញ់ពលកម្ម ត្រូវចាប់ផ្ដើមអនុវត្តតាំងពីកុមារភាព ។ ទំលាប់ទំរើសកូនមិនអោយកូនធ្វើអ្វីសោះ មានន័យថា អប់រំអោយកូនមានទំលាប់អាក្រក់ ។

ការអប់រំអោយស្រលាញ់ពលកម្ម គឺជាការចាំបាច់សំរាប់មនុស្សគ្រប់វ័យ ។ ចលនាប្រលងប្រទាំង ជាវិធីសំខាន់បំផុត សំរាប់អនុវត្តការងារពលកម្ម ។

**ឌយ យីម៉ាន**
បណ្ឌិតទស្សនវិជ្ជា

# ប្រព័ន្ធអេកូ ៖ ប្រព័ន្ធមានលំនឹង
# L'écosystème : un système en équilibre

អ្វីជាប្រព័ន្ធអេកូ ? តើវត្ថុធាតុអ្វីខ្លះដែលអាចបញ្ជាក់ន័យអោយប្រព័ន្ធអេកូ ?

ប្រព័ន្ធអេកូរួមមាន ប៊ីយ៉ូសេណូស ( la biocénose ) និងប៊ីយ៉ូតូប ( le biotope ) ។

**ក. ប៊ីយ៉ូសេណូស :**

គឺជាសហគមន៍នៃភាវៈរស់រួមមាន សត្វ រុក្ខជាតិ ដែលមានទំនាក់ទំនង រឺ ជាប់ជំពាក់រវាងគ្នានឹងគ្នាទៅវិញទៅមក ក្នុងលំនាំនៃសង្វៃងរកអាហារ ។ ទំនាក់ទំនងនេះ អាចបញ្ជាក់កាន់តែច្បាស់អំពីសញ្ញាណនៃខ្សែចង្វាក់អាហារណីយ ( chaîne alimentaire ) របស់ក្រុមសត្វ និង រុក្ខជាតិ ដូចជា :

នៅផ្នែកខាងក្រោម ( លើផ្ទៃដី - ក្នុងដី ) ពពួកបំបែកធាតុ ( décomposeurs ) ដូចជា ដង្កូវ សត្វល្អិត និងពពួកបំលែងធាតុ ( transformateurs ) មានអំបូរផ្សិត បាក់តេរី សុទ្ធតែជាអ្នកបំបែកធាតុ សេរីរាង្គ ដែលមាន ស្លឹកឈើ សាកសពធាតុជាដើម អោយទៅជាសារធាតុដែលឫសរុក្ខជាតិអាចស្រូបយកបាន ។

បន្ទាប់មក ពពួករុក្ខជាតិដែលជាផលិតករ ( Les producteurs ) បានដុះលូតលាស់ល្អ ដោយការប្រើប្រាស់សំនេសសំទល់បំបែកធាតុ និង ពួកបំលែងធាតុ ។ ពពួករុក្ខជាតិទាំងនោះមានជាអាទិ៍ ស្មៅ រុក្ខជាតិប្រភេទតូច រុក្ខជាតិធំ ។ល ។

នៅខាងលើ ( លើផ្ទៃដី ) មានសកម្មភាពរបស់ពួកស្វះស្វែងអាហារ ( Les consommateurs ) ដែលចែកជាច្រើនក៏រិតដូចជា តិណាសីសត្វ មំសាហារសត្វ សត្វស៊ីគំរង់ . . . ។ ពពួកទាំងនេះស្លាប់ទៅ ដោយបន្សល់ទុកនូវសំទល់ រឺ សាកសព ដែលជាបន្ទុកដល់ពពួកបំបែកធាតុ និងពពួកបំលែងធាតុជាថ្មីវិញ ។

**ខ. ប៊ីយ៉ូតូប : ( Biotope )**

គឺជាមជ្ឈដ្ឋានរស់ ( Lieu de vie ) រួមផ្សំនឹងលក្ខខ័ណ្ឌខាងក្រៅដូចជា សីតុណ្ហភាពសំណើម ពន្លឺ និងកំដៅព្រះអាទិត្យ ដី សណ្ឋានដី ។

សរុបមក ប្រព័ន្ធអេកូ រួមផ្សំដោយប៊ីយ៉ូសេណូស និង ប៊ីយ៉ូតូប ហើយស្ថិតនៅក្រោមឥទ្ធិពលនៃភាពផ្សេងគ្នា នៃបរិយាកាសមួយជាកំណត់ ។ ដូចនេះ ព្រៃគុម្ពោត បឹងត្រពាំង ជ្រោះជ្រលងភ្នំ សុទ្ធតែជាប្រព័ន្ធអេកូឡូស៊ី ដូចគ្នានឹងតំបន់ព្រៃស្លុកអាមាំសូន រឺតំបន់ភ្នំដូច្នោះដែរ ។ នៅក្នុងមាត្រដ្ឋាននៃតំបន់ធំៗ ប្រព័ន្ធអេកូបានប្រមូលផ្ដុំក្របខ័ណ្ឌរបស់ខ្លួនអោយមានដំណើរការ ក្រោមឥទ្ធិពលអាកាសធាតុមួយ សណ្ឋានដីមួយ និងតំបន់កំនើតរុក្ខជាតិ សត្វ គ្រប់ប្រភេទរបស់ខ្លួនមួយ ។

គេអាចកំនត់អោយដឹងអំពីភាពទូលំទូលាយនៃប្រព័ន្ធអេកូឡូស៊ីនៃមជ្ឈដ្ឋាននានា ដូចគ្នានឹងប្រព័ន្ធអេកូឡូស៊ីនៃតំបន់ព្រៃស្លុកសើម តំបន់ព្រៃរបោះ តំបន់វាលស្មៅ និងតំបន់វាលលំហដែរ ។

ដូច្នេះ ដើម្បីអោយប្រព័ន្ធអេកូឡូស៊ីនៃតំបន់មួយ មជ្ឈដ្ឋានមួយមានលំនឹងទៅបាន លុះត្រាតែប៊ីយ៉ូស៊ីណូស ដែលជាពិភពនៃភាវៈរស់ និងប៊ីយ៉ូតូបដែលជាពិភពនៃមជ្ឈដ្ឋានរស់នៅមានអត្ថិភាពជារៀងរហូត ។

ដូចនេះ គេមិនទាំគ្នាបំផ្លិចបំផ្លាញពិភពសត្វ រុក្ខជាតិ ដោយបរបាញ់ នេសាទ រឺធ្វើអាជីវកម្មអោយលើសប្រមាណ និងមិនត្រូវខិតខំបំពុលបរិយាកាស អោយមជ្ឈដ្ឋានរស់នៅរបស់មនុស្ស សត្វ រុក្ខជាតិ កករល្អក់ឡើយ ។ តែផ្ទុយទៅវិញ គេត្រូវតែថែរក្សាការពារវាអោយបានគង់វង្ស និង ស្អាតបរិសុទ្ធជារៀងរហូត ទៅតាមការប្រកាសយ៉ាងទទូចរបស់ក្រសួងកសិកម្ម និងក្រសួងបរិដ្ឋាន ។

បើយើងធ្វើបានដូចនេះ នោះបរិដ្ឋានដែលជាមជ្ឈដ្ឋានរស់នៅរបស់យើង នៅឈរបំរើយើងយ៉ាងញញឹមជានិច្ចនិរន្តរ៍ ។

**សូត ស៊ុម**

នាយកអនុវិទ្យាល័យព្រៃទទឹង ស្រុកព្រៃឈរ ខេត្តកំពង់ចាម

# ការប្រើពាក្យថ្មី

ខ្ញុំចាំបានថា មានលោកគ្រូយើងម្នាក់ មិនដឹងធ្វើការនៅខេត្តណាឡើយ បានធ្វើសំណូមពរអោយខ្ញុំពន្យល់ពាក្យ **សេវា** ដែលជាពាក្យថ្មី ។ ក្រោយពីបានពិចារណា រិះរកសេចក្ដីពន្យល់អោយបានស្រួលស្ដាប់ឆាប់យល់ ខ្ញុំសំរេចថានឹងពន្យល់គាត់ដោយប្រើពាក្យបារាំងជាគោល ព្រោះពាក្យ **សេវា** បាលីបកពីពាក្យបារាំង **Service** ។ ដូច្នេះ លំដាប់តទៅនេះ ខ្ញុំសូមប្រែពាក្យមួយចំនួន ដែលជាគ្រួសារនៃពាក្យ **Service** :

**Servir** : បំរើ គឺបំពេញភាតកិច្ច រឺភារកិច្ច

ឧ. : លោកគ្រូនេះបានបំរើក្រសួងអប់រំល្អណាស់ ។

**Se Servir** : : បំរើខ្លួនឯង

ឧ. : នៅភោជនីយដ្ឋាននេះ ភ្ញៀវបំរើខ្លួនឯង ( ដើរយកម្ហូបអាហារខ្លួនឯង )

**Serveur** : : អ្នកបំរើភ្ញៀវនៅភោជនីយដ្ឋាន - ហាងកេសដ្ឋ - អ្នករើសបាល់កូនឃ្លី នៅពេលគេលេងកូនឃ្លី

**Servante** : ស្ត្រីបំរើម្ចាស់ផ្ទះណាមួយ

**Servir à** : សំរាប់ប្រើ

ឧ. : ឧបករណ៍នេះ សំរាប់ប្រើធ្វើអ្វី ?

A quoi sert cet instrument ? Il sert à ouvrir les bouteilles .

**Servir de** : សំរាប់ជា ប្រើវា

ឧ. : បន្ទប់តូចនេះ សំរាប់ទុកប្រើដាក់ឧបករណ៍កំប៉ុកកំប៉ុក

Cette petite pièce sert de débarras

ឧ. : គ្រោះថ្នាក់នេះ ទុកជាមេរៀនចំពោះវា

Cet accident lui sert de leçons

**Serviteur** : : សេវកៈ ( អ្នកបំរើ )

ឧ. : វាជាអ្នកបំរើរដ្ឋដ៏ស្មោះត្រង់ម្នាក់

ជាសរុបពាក្យ **Service** មានន័យច្រើនតែជាទំលាប់យើងជាខ្មែរ យើងមិនដែលប្រើពាក្យ **សេវា** ទាំងអស់ទេ ។

**ឧទាហរណ៍**: ក. ក្នុងពេលបំពេញការងារ រឺធ្វើការងារ ( **សេវា**) ខ្ញុំមិនដែលនិយាយលេងជាមួយមិត្តភក្តិទេ ។

Pendant les heures de service, je n'ai jamais perdu mon temps à bavarder.

ខ. ក្នុងទីស្ដីការក្រសួងអប់រំ យុវជន និងកីឡា មានការិយាល័យច្រើន ។
ការិយាល័យទាំងនោះ គេហៅថា **Service** ក៏បាន រឺ **Bureau**

**Service de presse:** ការិយាល័យពត៌មាន

**Service d'ordre:** ការិយាល័យរបៀប

គ. ការចូលបំរើកងទ័ពៈ **Service militaire**

ឃ. វេនវាយបាល់កូនឃ្លី រឺបាល់ទះ **Service de tennis ou de volley ball**

ការពន្យល់នេះ នៅមិនទាន់អស់សេចក្ដីនៅឡើយទេ តែវាជាពន្លឺចំពោះអ្នកចង់ចេះ ចង់ដឹងក្នុងការប្រើពាក្យ **សេវា** ( **Service** ) ។

**យ៉ង់ ឌី**

# តើគ្រូគិតយ៉ាងណា នៅពេលដែលសិស្សសួរយើង យើងឆ្លើយមិនរួច ?

ជាធម្មតា អ្នកដែលចង់ដឹង តែតែងតែសួរ ។ សង្គមបានចាត់ទុកជាស្រេចថា គ្រូបង្រៀនជាអ្នកចេះដឹងច្រើនជាងអ្នកដទៃ ។ អ្វីដែលគេឆ្ងល់ រឺមិនយល់ គេតែងតែរត់មករកលោកគ្រូ - អ្នកគ្រូ ។ បើអ្នកឆ្ងល់នោះ ជាគ្រូបង្រៀនដែរ គាត់តែងតែរត់មកសួរលោកគ្រូ - អ្នកគ្រូដែលចាស់ជាង រឺធ្លាប់ធ្វើគ្រូរបស់គាត់ រឺធ្លាប់ធ្វើជាគ្រូយូរជាងគាត់ ។

នៅក្នុងក្រុមគ្រួសារ បើកូនឆ្ងល់ វានឹងរត់ទៅសួរម្តាយ ។ ម្តាយឆ្លើយមិនរួច ក៏រុញអោយទៅសួរឪពុក ។ ឪពុកឆ្លើយមិនរួច ក៏រុញកូនអោយទៅសួរគ្រូ ។ ឪពុកម្តាយខ្លះ តូចចិត្តដោយសារកូនជឿគ្រូជាងខ្លួន ។ នេះជាការលើកតំកើងដែលគួរអោយសប្បាយរីករាយ និងគួរអោយព្រួយបារម្ភរបស់គ្រូបង្រៀន ។ ហេតុនេះហើយ បានជាក្នុងម៉ោងបង្រៀនទីមួយៗ យើងតែងសង្កេតឃើញសកម្មភាពសប្បាយ និងព្រួយបារម្ភនេះលេចឡើង ។ គ្រូខ្លះតែងតែបើកដៃអោយសិស្សសួរដោយគ្មានល័ក្ខខ័ណ្ឌ ។ ចំនែកគ្រូខ្លះខិតខំរិះរកមធ្យោបាយទប់ស្កាត់ កុំអោយសិស្សសួរកើត ហើយជួនកាល មានទាំងសំឡុតសិស្ស នៅពេលដែលសិស្សសួរកន្លែងឆ្លើយមិនរួច ដោយយកលេសថា « **សួរដើម្បីផ្ចាញ់ផ្ចាល** » ។

ក្នុងឋានៈជាគ្រូបង្រៀន បើយើងបដិសេធមិនទទួលការលើកតំកើងពីសង្គមក៏ហើទៅចុះ ប៉ុន្តែត្រូវតែទទួលដោយរីករាយបំផុត នូវការលើកតំកើងពីសំនាក់សិស្សដែលជាអ្នកនៅក្បែរយើងជាងគេ ។ ចំលើយ រឺដំណោះស្រាយសមហេតុផល ជាករណីចាំបាច់ដែលយើងត្រូវតែព្យាយាមប្រើប្រាស់ដោយចៀសវាង ពាក្យថា « **ខ្ញុំអត់ចេះទេ** » ។ បើយើងពិតជាមិនចេះពីមុន យើងត្រូវរកវិធីផ្សេងៗ មកដោះស្រាយអោយស្អាត ដើម្បីយករួចខ្លួនសិន សឹមគិតតទៅទៀត ។ ឧទាហរណ៍ : សិស្សសួរថា : ‹‹ **បើស្រមោចមានមាឌតូចៗ អញ្ចឹង ហេតុអ្វីបានជាវាអាចរកហ្វូង រឺកន្លែងមានចំនី រឺសំបុកឃើញ ?** ›› ខ្ញុំគិតថា បើសិនជាយើងមិនចេះឆ្លើយ ពន្យល់វាទេ យើងគួរតែប្រាប់វាថា « ចំពោះសំនួរនេះ ខ្ញុំបានគិតរួចហើយថា ខ្ញុំនឹងដាក់អោយក្រុម ( រឺថ្នាក់ ) របស់អ្នកពិភាក្សាគ្នា ដើម្បីរកចំលើយមកអោយខ្ញុំ ហេតុនេះ ខ្ញុំមិនអាចប្រាប់ក្នុងពេលនេះបានទេ . . . បើបានជាដឹងថា ខ្ញុំកំពុងតែត្រៀមសំរាប់សួរអ្នក សូមអ្នកយកសំនួរនេះទៅប្រាប់មិត្តភក្តិក្នុងថ្នាក់អោយបានដឹងទាំងអស់គ្នា ហើយពិភាក្សារកអោយឃើញចំលើយ គ្រូទុកពេលអោយ . . . អាទិត្យក្រោយ គ្រូនឹងធ្វើការកែតំរូវលើចំលើយរបស់អ្នកទាំងអស់គ្នា » ។

ពេលនេះខ្ញុំជឿថា បញ្ហាពីរនឹងកើតឡើង គឺចំពោះសិស្សខ្ជិល ( ដែលចេះតែសួរៗ ទៅ ) វានឹងឈប់សួរជាលើកទី ២ទៀត ព្រោះវានឹងគិតថា ‘ សួរធ្វើអ្វី បើសួរទៅវានាំរវល់ដល់ខ្លួនឯងយ៉ាងនេះ ’ ។ នេះជាវិធីដោះស្រាយស្របច្បាប់ និងតាមចិត្តសាស្ត្រ ។ មួយវិញទៀត ចំពោះសិស្សឧស្សាហ៍នោះ វានឹងខិតខំរកសំនួរផ្សេងៗ ទៀត ។

ទោះជាយ៉ាងណាក៏ដោយ សំនួរនីមួយៗ គឺជាបំនុលដែលយើងជាគ្រូបង្រៀនត្រូវតែសងទៅអ្នកសួរ តាមចំលើយសមហេតុផល មានលក្ខណៈវិទ្យាសាស្ត្រ ។ ហេតុនេះហើយបានជាការស្រាវជ្រាវ គឺជាការងារមួយដែលគ្រូបង្រៀនមិនត្រូវបោះបង់ចោលឡើយ ។ តាមរយៈ**ទំព័រទស្សនាវដ្តីគ្រូបង្រៀនរបស់** ស.ប.ស.ខ ខ្ញុំនឹងបន្ថយការលំបាកក្នុងការស្រាវជ្រាវរបស់លោកគ្រូ-អ្នកគ្រូ ដោយអត្ថបទដែលខ្ញុំបានស្រាវជ្រាវពីប្រភពយ៉ាងច្រើន ស្តីអំពីបាតុភូតធម្មជាតិ វិទ្យាសាស្ត្រ ជីវសាស្ត្រ រូបសាស្ត្រ . . . ដំណឹងប្លែកៗ បានកើតឡើងនៅក្បែរខ្លួន ជុំវិញខ្លួន និងឆ្ងាយៗ ពីខ្លួនយើង ។ ម្យ៉ាងទៀតមានការពន្យល់តាមបែបវិទ្យាសាស្ត្រនូវពាក្យដំណាលតៗ គ្នា តាំងពីសម័យដែលបុព្វបុរសយើងមិនទាន់ស្គាល់វិទ្យាសាស្ត្រនៅឡើយ ។

ដោយ **ឈា ឈឿន**

# លទ្ធភាពរបស់មាតាបិតា និង សហគមន៍ ក្នុងការជួយសាលារៀនបឋមសិក្សា

សាលារៀនមានបេសកកម្មបណ្តុះបណ្តាលកុមារអោយមានការរីកចំរើនគ្រប់ញាណសក្តិ ។

សាលារៀនជាកន្លែងដែល :

- មានអនាម័យល្អ អនុគ្រោះដល់ការលូតលាស់ខាងរាងកាយរបស់កុមារ អោយមានដំណើរការប្រក្រតី ។
- អាចបណ្តុះបណ្តាលចំណេះដឹងដល់កុមារ និងអាចអោយកុមារ បន្តការសិក្សារបស់ខ្លួនជាលំដាប់លំដោយទៅថ្នាក់លើ ។
- អាចបណ្តុះបណ្តាលឆន្ទៈសីលធម៌ និង សុភាវធម៌ចំពោះកុមារ ដើម្បីអោយគេទាំងឡាយក្លាយទៅជាមនុស្សពិតប្រាកដ ប្រកបដោយចំណេះដឹង និង សីលធម៌ ។

ការអប់រំបណ្តុះបណ្តាលកុមារមានលក្ខណៈស្មុគ្រស្មាញ ។ សាលារៀនតែម្នាក់ឯង មិនអាចធ្វើអោយបានសំរេចនូវគោលបំណងខាងលើនេះបានឡើយ ។ ពោលគឺត្រូវមានការចូលរួមពីគ្រួសារសិស្ស និងពីសហគមន៍ថែមទៀត ។ គ្រូបង្រៀន មាតាបិតាសិស្ស និងសហគមន៍ មានគោលបំនង និងផលប្រយោជន៍រួម ត្រូវកសាងបុគ្គលិកលក្ខណៈរបស់កុមារ ។

## ១. មាតាបិតាសិស្សជួយរៀបចំការងាររបស់សាលារៀន

តាំងពីកើតមក រហូតមកទល់ថ្ងៃដែលចូលរៀនដំបូងនៅសាលារៀនបឋមសិក្សា កុមារបានទទួលឥទ្ធិពល និងការអប់រំជាបន្តបន្ទាប់ពីឪពុកម្តាយ និងមជ្ឈដ្ឋានជុំវិញ ។ ឥទ្ធិពល និងការអប់រំ ត្រូវសមស្របទៅនឹងការអប់រំនៅសាលារៀន ដូចជារបៀបរៀបរយ ការសំអាត ការគោរពការងារ ការចេះរួមរស់ជាក្រុម ។ល ។ ទាំងអស់នេះ ពិតជាបានបង្កលក្ខណៈងាយស្រួលដល់បេសកកម្មរបស់សាលារៀន ។ ចំពោះសិស្សដែលមានលទ្ធភាពចូលមត្តេយ្យសាលាមុន រួចចូលរួមនៅសាលារៀនបឋមសិក្សានោះ បណ្តាទំលាប់ទាំងឡាយសុទ្ធតែត្រូវបានអភិវឌ្ឍល្អជាងកុមារដែលពុំបានចូលរៀននៅមត្តេយ្យសិក្សា ។ ប្រការនេះ វាកាន់តែបង្កលក្ខណៈងាយស្រួលបានមួយកំរិតថែមទៀត ក្នុងការរៀបចំការអប់រំនៅសាលារៀនបឋមសិក្សា ។

ដើម្បីបុព្វហេតុអនាគតរបស់កុលបុត្រ កុលធីតារបស់ខ្លួន មាតាបិតា ត្រូវតែជួយរៀបចំ និងបង្កលក្ខណៈងាយស្រួលដល់បេសកកម្មរបស់សាលារៀន ដូចជាការអប់រំកូនចៅអោយមានសណ្តាប់ធ្នាប់ អោយចេះគួរសម ចេះរួមរស់ជាមួយគេឯង និងចេះស្រលាញ់ការរៀនសូត្រ ជាពិសេសស្គាល់តំលៃនៃចំណេះវិជ្ជា ។ មាតាបិតាសិស្ស ត្រូវត្រៀមឧបករណ៍សិក្សា និងសំលៀកបំពាក់ឯកសណ្ឋានសំរាប់កូនចៅរបស់ខ្លួនជាដើម ។

## ២. មាតាបិតាសិស្សត្រូវជួយគាំទ្រការអប់រំនៅសាលារៀន

បើសិនជាមាតាបិតាសិស្សបន្ថយ រឺបំពេញឥទ្ធិពលរបស់គ្រូបង្រៀនដូចជាថា « គ្រូកូនឯងបង្រៀនមិនកើត មិនចេះបង្រៀន » រឺក៏ថា « គ្រូកូនឯងមានឫកពាមិនល្អយ៉ាងនេះ រឺយ៉ាងនោះវិញ » រឺក៏ថា « មិនត្រូវធ្វើតាមគ្រូកូនឯងជាដើម » ។ល ។ កុមារពិតជាធ្វើតាមឪពុកម្តាយ ។ ការទិតៀនគ្រូបង្រៀននៅចំពោះមុខកូន ពិតជាធ្វើអោយបាត់ឥទ្ធិពលរបស់គ្រូបង្រៀន ហើយក៏អាចអោយកូនបាត់ជំនឿទៅលើគ្រូបង្រៀនរបស់ខ្លួន ។ បើយ៉ាងនេះ លទ្ធផលនៃការសិក្សារបស់កុមារពិតជាត្រូវរងគ្រោះ ។

គ្រូបង្រៀនក៏ត្រូវការការជួយគាំទ្រពីមាតាបិតាសិស្សពុំអាចខ្វះបាន ។ ក្នុងករណីមាតាបិតាសិស្សបានឃើញកូនរបស់ខ្លួនមិនសមស្រប គួរទៅសាកសួរពត៌មានពីគ្រូបង្រៀន ដើម្បីចៀសវាងការស្តាប់គ្នាមិនបាន រវាងមាតាបិតាសិស្ស និងគ្រូបង្រៀន ។ មាតាបិតា ត្រូវឧបត្ថម្ភគាំទ្រការអប់រំរបស់សាលារៀន ដូចជាជួយអប់រំកូនចៅអោយចេះគោរពពេលវេលា គោរពវិន័យសាលារៀន និងចេះគោរពគ្រូបាធ្យាយជាដើម ។ ប្រការនេះ ជាអំណោយផលមួយ ធ្វើអោយរស់ឡើងវិញនូវអរិយធម៌របស់ជាតិ និងទំលាប់ល្អរបស់សង្គម នៃជនជាតិយើង ។

## ៣. មាតាបិតាសិស្សត្រូវជួយបំពេញការអប់រំនៅសាលារៀន

កុមាររស់នៅចំនួន ៣ ភាគ ៤ នៃពេលវេលារបស់ខ្លួនក្នុងគ្រួសារ និងក្នុងសហគមន៍ ហើយមានតែ ១ ភាគ ៤ នៃពេលវេលាប៉ុណ្ណោះ ដែលរស់នៅក្នុងសាលារៀន ។ សាលារៀនតែម្នាក់ឯងមិនអាចបំពេញភារកិច្ចរបស់ខ្លួនបានពេញលេញសព្វគ្រប់ទេ តែត្រូវការជំនួយពីគ្រួសារសិស្សជាចាំបាច់ផងដែរ ។ ការបណ្តុះបណ្តាលនៅសាលារៀនច្រើនតែទ្រឹស្តី គឺនៅផ្ទះមានការអនុវត្តច្រើន ដូចជាការធ្វើកិច្ចការនៅផ្ទះជាដើម ។ គឺក្នុងន័យនេះហើយ បានជាគ្រូអាចធ្វើការអប់រំបានល្អ ដោយមានការសហការល្អពីមាតាបិតាសិស្ស រឺអាណាព្យាបាល ។ កំលាំងទាំងពីរនេះជួយគ្នាទៅវិញទៅមក ។ បើម្នាងៗ ស្គាល់ករណីយកិច្ច និងកាតព្វកិច្ចរៀងៗ ខ្លួននោះ ការអប់រំកុមារនឹងទទួលបាននូវប្រសិទ្ធភាព តាមសំណូមពរនៃគោលដៅអប់រំនៅបឋមសិក្សា តាមគោលដៅអប់រំចំណេះទូទៅ និងគោលដៅអប់រំជាតិ ។

មាតាបិតា ត្រូវតែជួយបំពេញការងារអប់រំរបស់សាលារៀន ដូចជាការអភិវឌ្ឍចរិយាសម្បត្តិ ការណែនាំអោយធ្វើកិច្ចការនៅផ្ទះជាដើម ។

## ៤. សហគមន៍ត្រូវជួយរៀបចំ ជួយគាំទ្រ និងជួយបំពេញការអប់រំ

គ្រួសារជាកោសិការបស់សង្គម « La famille est la cellule sociale » រឺអាចនិយាយថា ជាកោសិការបស់សហគមន៍ « Communauté » ។ សមាគមមាតាបិតាសិស្ស រឺសហគមន៍ អាចជួយគាំទ្រ និងជួយបំពេញការអប់រំសាធារណៈ ទាំងស្មារតី និងសំភារៈ ដូចជាការជួយកុមារអោយចូលរៀន ជួយកសាងសាលារៀន ជួយផ្តល់សំភារៈចាំបាច់ ជួយការពារឥទ្ធិពលរបស់សាលារៀន ។ ដើម្បីបុព្វហេតុ អនាគតដ៏រុងរឿងរបស់ខ្លួន ក៏ដូចជាគ្រួសារដែរ សហគមន៍ត្រូវតែជួយរៀបចំ ជួយគាំទ្រ ជួយបំពេញការអប់រំសាធារណៈ និងត្រូវតែចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍអនាគត សមាជិកសកម្ម « Les futurs membres actifs » ពោលគឺ កុមារា - កុមារី ទាំងឡាយ ដែលកំពុងតែសិក្សានៅក្នុងសាលារៀនបឋមសិក្សារបស់យើងនាសព្វថ្ងៃនេះ ។

ដូចនេះ សាលារៀនសាធារណៈរបស់យើង មិនគ្រាន់តែត្រូវផ្សារភ្ជាប់ជាមួយគ្រួសារសិស្សតែប៉ុណ្ណោះទេ « Ecole - famille » ប៉ុន្តែ ត្រូវមានសហប្រតិបត្តិការល្អ ជាមួយសហគមន៍ផងដែរ « Ecole-communauté » ។

ម្យ៉ាងទៀត ក្នុងការងារសហប្រតិបត្តិការសាលារៀន - សហគមន៍នេះ ក្រៅពីពលរដ្ឋ និង មាតាបិតាសិស្ស គ្រូបង្រៀនត្រូវមានទំនាក់ទំនងល្អជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ខេត្ត - ស្រុក ជាពិសេស មេឃុំ មេភូមិ ដែលជាអាជ្ញាធរដែនដីមូលដ្ឋាន ជាមួយព្រះគ្រូចៅអធិការវត្ត ព្រះសង្ឃ លោកតា អាចារ្យ គណៈកម្មការវត្ត ចាស់ព្រឹទ្ធាចារ្យ រឺអ្នកដឹកនាំដទៃទៀតក្នុងសហគមន៍ រឺក៏សប្បុរសជនជាតិ និងអន្តរជាតិ ដើម្បីអោយកំលាំងដែលដឹកនាំសហគមន៍ទាំងមូលបានរួមចំណែកដ៏មានប្រសិទ្ធភាព ក្នុងការអភិវឌ្ឍសាលារៀនជាបន្តបន្ទាប់ ។

## ៥. បណ្តាមធ្យោបាយដែលគ្រូបង្រៀនត្រូវប្រើ ដើម្បីសហប្រតិបត្តិការល្អ រវាងសាលារៀន - គ្រួសារសិស្ស និង រវាងសាលារៀន - សហគមន៍

ដើម្បីសំរុះសំរួលភាពខ្វែងគ្នា រវាងគរុកោសល្យសាលារៀន « La pédagogie de l'école » និងគរុកោសល្យគ្រួសារ « La pédagogie de la famille » និងដើម្បីអោយគ្រួសារសិស្សស្គាល់ យល់ និងអនុវត្តបានល្អប្រសើរ និងតាមសំណូមពរចាំបាច់ សាលារៀនត្រូវតែជាអ្នកមានភាគពួកិច្ចឈានមុខ និងត្រូវប្រើប្រាស់មធ្យោបាយសមស្របទាំងឡាយដូចតទៅនេះ ៖

- ត្រូវឧស្សាហ៍ប្រជុំមាតាបិតាសិស្សនៅបវេសនកាល នៅពេលប្រជុំគណៈកម្មការសាងសង់ នៅពេលបញ្ចប់ឆមាសទី ១ និងនៅពេលដំណាច់ឆ្នាំ និងពិធីចែករង្វាន់ជាដើម ។
- អាចសាកសួរ រឺ កត់ត្រាពតិមានពីសុខភាព អត្តចរិត លក្ខណៈពិសេសរបស់សិស្សពេលសិស្សសុំចូលរៀន ។
- គ្រូអញ្ជើញទៅជួបនៅផ្ទះរបស់សិស្ស បើមានឱកាស ។
- គ្រូទៅចូលរួមបុណ្យទានផ្សេងៗ ដែលរៀបចំឡើងដោយមាតាបិតាសិស្ស រឺដោយសហគមន៍ ។
- អប់រំគ្រួសារតាមរយៈកុមារ តាមរយៈការផ្តាំផ្ញើតាមសិស្ស ទៅឪពុកម្តាយសិស្ស « On éduque la famille à travers l'enfant » ។

## ៦. ប្រការដែលគ្រូបង្រៀនយើងចងចាំជុំវិញទំនាក់ទំនងទាំងឡាយ ដើម្បីទាញគុណប្រយោជន៍អោយបានខ្ពស់ក្នុងបុព្វហេតុអភិវឌ្ឍន៍វិស័យអប់រំជាតិ

ជាការសោកស្តាយណាស់ ដែលមាតាបិតាសិស្សមួយចំនួនយល់ថា : គ្រូបង្រៀនអាចជំនួសគ្រួសារសិស្សបាន ។ តាមពិតនៅក្នុងគ្រួសារនេះហើយ ដែលការអប់រំដំបូង និងជាសារវ័ន្តត្រូវកើតមានឡើង « Il serait fâcheux de faire croire aux parents que l'instituteur peut remplacer la famille, c'est dans la famille que la première et la plus essentielle éducation doit être donnée »

ប្រការមួយទៀត ដែលគួរអោយសោកស្តាយជាងនេះទៀត គឺនៅពេលដែលសាលារៀន និងគ្រួសារសិស្ស ស្ថិតនៅជាមជ្ឈដ្ឋានពីរដាច់ដោយឡែកពីគ្នា និងបដិបក្ខនឹងគ្នា ។ មជ្ឈដ្ឋានទាំងពីរនេះ ត្រូវផ្សារភ្ជាប់គ្នា សហការគ្នា ជួយបំពេញគ្នាទៅវិញទៅមក ដើម្បីសកម្មភាពអប់រំកុមារបានរឹងមាំ និងបានជាប់លាប់ ។

គ្មានអ្វីជំនួសគ្រួសារសិស្ស គ្មានអ្វីក្រោមឱវាទគ្រួសារសិស្ស « Ni substitution, Ni subordination aux familles » ។

គ្មានអ្វីជំនួសគ្រួសារសិស្សក៏ពិតមែន ប៉ុន្តែប្រការមួយដែលគ្រូបង្រៀនត្រូវតែចងចាំថា : តើត្រូវស្តាប់គ្រួសារសិស្សរឺទេ ?

យើងធ្លាប់ដឹងថា មាតាបិតាសិស្សខ្លះ ចូលចិត្តទិតៀនគ្រូបង្រៀនយើង ដោយគ្មានហេតុផលត្រឹមត្រូវនៅចំពោះមុខសិស្ស ដូចវិធី និងរបៀបបង្រៀន « Méthodes et procédés d'enseignement » អំពើ រឺអាកប្បកិរិយាផ្សេងៗ របស់គ្រូបង្រៀន ជួនកាលមានពេលខ្លះ គាត់ណែនាំអំពីវិធីសាស្ត្របង្រៀន និងអំពីអាកប្បកិរិយាដល់គ្រូបង្រៀនថែមទៀតផង ។ គ្រូបង្រៀនត្រូវទុកមតិទិតៀននេះ គ្រាន់តែជាធាតុទាំងឡាយសំរាប់ការពិចារណាបានហើយ ។

គ្មានអ្វីជំនួសគ្រួសារសិស្ស និង គ្មានអ្វីស្ថិតនៅក្រោមឱវាទគ្រួសារសិស្ស : « គឺជារូបមន្តសំរាប់សំគាល់មុខងាររបស់គ្រូបង្រៀនក្នុងការងារសហប្រតិបត្តិការសាលារៀន - គ្រួសារសិស្ស » « Ni substitution, Ni subordtination

aux familles : Telle est la formule qui parait bien marquer le rôle du maître dans la coopération de l'école et de la famille » ។

អ្នកគរុកោសល្យម្នាក់បានមានប្រសាសន៍ថា : « បើសិនជាគ្មានការចុះសំរុងគ្នារវាងសាលារៀន និងគ្រួសារសិស្ស បើសិនជាឥទ្ធិពលទាំងពីរដែលត្រូវតែផ្សារភ្ជាប់គ្នាបែរជាយល់ច្រឡំដោយបែកបាក់គ្នា និងប្រយុទ្ធរវាងគ្នាទៅវិញទៅមកនោះ មិនមែនសាលារៀនទេដែលជាអ្នកឈ្នះនៅក្នុងការប្រយុទ្ធមិនស្មើគ្នានេះ តែគឺគ្រួសារទៅវិញទេ ដែលបំផ្លាញស្ទើរតែអស់នូវស្នាដៃរបស់សាលារៀន » « S'il y a désaccord entre l'école et la famille, si ces deux influences au lieu de s'unir, de se confondre, se séparent, se combattent, ce n'est pas l'école qui a le dessus dans cette lutte inégale, c'est la famille que défait presque infailliblement l'œuvre de l'école » ។

- គ្រួសារសិស្សមិនត្រូវខ្វាចគំនិតផ្ដួចផ្ដើមរបស់សាលារៀនទេ ព្រោះសាលារៀនដឹកនាំដោយអ្នកបច្ចេកទេសដែលអនុវត្ត ចិត្ត-គរុកោសល្យ ។ រីឯសាលារៀនវិញ ក៏មិនត្រូវខ្លាចសហប្រតិបត្តិការពីឪពុកម្ដាយសិស្សដែរ ព្រោះគ្រួសារអាចផ្ដល់ពត៌មានអំពីសិស្សបានជាក់លាក់ស្ដីពីសុខភាព អត្តចរិត គុណសម្បត្តិ និងលក្ខណៈពិសេស ។

ជាពិសេស គ្រួសារក៏ស្រលាញ់កុមារក្នុងមនោសញ្ចេតនាសាច់ឈាម « Sentiment affectif » រីឯ សាលារៀនវិញ ក៏ស្រលាញ់កុមារក្នុងមនោសញ្ចេតនាបញ្ញា « Sentiment intellectuel » ។ ពាក្យចាស់បុរាណបានពោលថា : « **ត្រឡប់ខាងនៅ . ទើបឈ្លោះខាងមក** » មានន័យថា : ក្នុងបញ្ហាទំនាក់ទំនងនេះគ្រូបង្រៀនត្រូវតែជាអ្នកផ្ដើមមុន ព្រោះមាតាបិតាសិស្សភាគច្រើនមិនបានយល់ពីខ្លឹមសារនេះទេ ។ ការចាំបាច់ក្នុងទំនាក់ទំនងនេះ អ្នកអប់រំត្រូវរក្សាអោយបាននូវអាកប្បកិរិយាថ្លៃថ្នូរសមរម្យ ជាមន្ត្រីអប់រំជាតិ ។ ការពឹងផ្អែកទៅលើជំនួយពីគ្រួសារ និងសហគមន៍មិនមែនមានន័យបញ្ជាក់ថាសាលារៀនអត់សមត្ថភាពនេះទេ តែជាភស្តុតាងបញ្ជាក់នូវសុឆន្ទៈទទួលខុសត្រូវមួយរបស់សាលារៀនចំពោះអនាគតកុមារដែលជាភារៈជាទីស្រលាញ់បណ្ដូលចិត្តរបស់គ្រួសារ ក៏ដូចជាភារៈដ៏មានតំលៃមិនអាចកាត់ថ្លៃបានរបស់ប្រទេសជាតិ ។

សម្បទាគរុកោសល្យ និង ពលិកម្មក្នុងមុខងាររបស់គ្រូបង្រៀន ទោះបីធ្ងន់ធ្ងរយ៉ាងណាក៏ដោយក៏មិនអាចសំរេចជោគជ័យបានសមតាមប្រាថ្នាដែរ បើសិនជាគ្មានសហការសាលារៀន - គ្រួសារ និងសាលារៀន - សហគមន៍ទេនោះ ។

តាមរយៈការសិក្សាខាងលើនេះ និង តាមរយៈបទពិសោធន៍ជាក់ស្ដែង ក្នុងការងារនៅសាលារៀននានា បានបង្ហាញអោយយើងឃើញថា : គ្រួសារសិស្ស និងសហគមន៍ គឺជាដៃគូមិនអាចខ្វះបានរបស់សាលារៀន ។ គ្រួសារ និងសហគមន៍ ត្រូវតែជួយរៀបចំគាំទ្រ និងបំពេញការអប់រំសាធារណៈ ។ កំលាំងទាំង ៣ មជ្ឈដ្ឋានទាំង ៣ ដែលមានឥទ្ធិពលទៅលើកុមារ និង ស្រលាញ់កុមារ ត្រូវសហប្រតិបត្តិការគ្នា រួមចំណែកទទួលខុសត្រូវតាមភារកិច្ច និង កាតព្វកិច្ចរៀងៗខ្លួន ។

គ្រូបង្រៀន និងនាយកសាលារៀនយ៉ាងណា សាលារៀនក៏យ៉ាងនោះដែរ គ្រូបង្រៀន និង នាយកសាលារៀនយ៉ាងណា ការជួយរៀបចំ គាំទ្រ និងបំពេញការអប់រំសាធារណៈរបស់មាតាបិតាសិស្ស និងសហគមន៍ក៏យ៉ាងនោះដែរ ។ តំលៃនេះយោងទៅលើអ្វីដែលគ្រូបង្រៀន « **ខាងធ្វើ** » ជាជាងអ្វីដែលគ្រូបង្រៀន « **ខាងថា** » ។

ដោយលោក **ឈឹម សុត**
អធិការបឋមសិក្សា និង ជាអនុប្រធានមន្ទីរអ.យ.ក ខេត្តព្រៃវែង



# ការអប់រំ & គរុកោសល្យ

## ភ្នំជ្រៃហូរញ្ញែ

កាលណាបើយើងធ្វើដំណើរចេញពីភ្នំពេញ ឆ្ពោះទៅខេត្តកំពត តាមផ្លូវជាតិលេខ ៣ បានចំងាយ ៣៩គីឡូម៉ែត ហើយយើងក្រឡេកមើលទៅខាងស្តាំដៃ យើងនឹងឃើញកូនភ្នំតូចមួយដែលលេចធ្លោឡើងផុតពីវាលរាបស្មើ គួរទីចាប់អារម្មណ៍នៃអ្នកធ្វើដំណើរទាំងឡាយ ។ នោះគឺជាភ្នំ **ជ្រៃហូរញ្ញែ** ។ ភ្នំជ្រៃហូរញ្ញែស្ថិតនៅក្នុងឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។



**TAKEN BY Mr. john J KATT**

យើងអាចធ្វើដំណើរតាមផ្លូវក្រួសមួយ ដែលបានបែកចេញពីផ្លូវជាតិលេខ ៣ ត្រង់ចំណុចគីឡូម៉ែតលេខ៣៩ ត្រង់ផ្សារដើមរការ ឆ្ពោះទៅកាន់ទិសឯលិច ចំងាយតែពីរគីឡូម៉ែតកន្លះ យើងនឹងទៅដល់ជើងភ្នំជ្រៃហូរញ្ញែ ដែលមានទេសភាពស្រស់ប្រិមប្រិយ គ្របដណ្តប់ទៅដោយរុក្ខជាតិពណ៌បៃតងស្រងាត់ ។ នៅតាមជើងភ្នំមានដើមត្នោតជាច្រើន ដុះរកេតរកូត ខ្លះទាប ខ្លះខ្ពស់ លាយឡំជាមួយរុក្ខជាតិចំរុះ ខ្លះមានផ្លែ ខ្លះទៀតគ្មានផ្លែ ព្រមជាមួយនឹងផ្ទះប្រជាជន ខ្លះប្រក់ស្លឹក ខ្លះប្រក់ក្បឿង សង់ជាជួរតាមផងផ្លូវជើងភ្នំនោះ ។ បើក្រឡេកមើលទៅលើកំពូលភ្នំ យើងនឹងឃើញវត្តមួយយ៉ាងច្បាស់ គឺដំបូលព្រះវិហារ និងកុដិព្រះសង្ឃប្រក់ក្បឿងពណ៌ និងក្បឿងក្បាច់យ៉ាងស្អាត គួរជាទីចាប់អារម្មណ៍ក្រៃលែង ។ បើយើង

ធ្វើដំណើរទៅមុខទៀត រហូតដល់ភាគខាងលិចភ្នំ យើងនឹងឃើញមានវត្តមួយទៀត ដែលមានលក្ខណៈល្អឥតខ្ចោះ ស្ថិតនៅលើទីធ្លារាបស្មើមួយ ប្រកបដោយរុក្ខជាតិមានម្លប់ត្រឈឹងត្រឈៃអមសងខាងផ្លូវចូល និងស្រះទឹកធំមួយនៅជាប់នឹងព្រះវិហារ ។ កាលពីឆ្នាំ ១៩៧០ សាលារៀនជាច្រើនខ្នងនៅទីនោះគឺជាអនុវិទ្យាល័យជ្រៃហូរញ្ញេ ហើយវត្តនោះ គឺជាវត្តជ្រៃហូរញ្ញេ វត្ត **និគ្រោធនលក្ខណ៍** ។

បើយើងធ្វើដំណើរទៅមុខទៀតតាមជើងភ្នំ យើងនឹងឃើញមានផ្លូវមួយដែលអាចអោយអ្នកធ្វើដំណើរឡើងទៅដល់កំពូលភ្នំបានដោយជិះឡាន រឺម៉ូតូ ក្រឡឹងព័ទ្ធជុំវិញភ្នំ មានលក្ខណៈដូចគូទខ្យងរហូតដល់កំពូលភ្នំ រឺបើសិនជាអ្នកធ្វើដំណើរដោយជើងផ្ទាល់ គឺអាចឡើងតាមជណ្ដើរថ្ម ដែលរៀបឡើងត្រង់ពីខាងជើងភ្នំ តំរង់ទៅលើតែម្ដង រហូតដល់កំពូលភ្នំ មានលក្ខណៈជាកាំជណ្ដើរ និងមានបង្កាន់ដៃរហូតតាំងពីក្រោមដល់លើ ។ វត្តដែលនៅលើកំពូលភ្នំនេះ គឺស្ថិតនៅលើទីធ្លារាបស្មើល្អ ដែលអាចចតឡានបានប្រហែល ៥០គ្រឿង ។

វត្តដែលស្ថិតនៅលើកំពូលភ្នំនេះ គឺជាវត្តភ្នំជ្រៃហូរញ្ញេ ដែលមានព្រះវិហារប្រកបដោយក្បាច់ចំលាក់យ៉ាងល្អ ព្រះវិហារនេះគឺមានអាយុច្រើនណាស់ប្រមាណប្រហែលមួយសតវត្ស ប៉ុន្តែបច្ចុប្បន្នត្រូវបាន សប្បុរសជន និង ពុទ្ធបរិស័ទចំណុះជើងវត្តជួសជុលឡើងវិញយ៉ាងស្អាត ។ ក្រៅពីនោះមានកុដិពីរ បី និងសាលាឆាន់មួយ សុទ្ធសឹងធ្វើឡើងអំពីថ្មទាំងអស់ ជាពិសេស គឺមានបាំងកាឡូមួយ(១) ដែលនៅបែកខាងមុខមានជណ្ដើរឡើង ហើយអាចអង្គុយ និងឈរនៅលើនោះបានប្រមាណជា ១០នាក់ ។ នៅទីនោះយើងអាចមើលឃើញទេសភាពដ៏ល្អ ដូចជាមើលឃើញវត្តជ្រៃហូរញ្ញេខាងក្រោម « **និគ្រោធនលក្ខណ៍** » វាលស្រែល្វឹងល្វើយដាច់កន្ទុយភ្នែក ព្រមទាំងដើមត្នោតរាប់មិនអស់ រួមផ្សំជាមួយ និងខ្យល់អាកាសបរិសុទ្ធ គួរជាទីមនោរម្យ ដែលធ្វើអោយភ្ញៀវជាតិ និង អន្តរជាតិបានទៅដល់ទីនោះមិនអាចទប់មាត់ និងសរសើរបានថា « អស្ចារ្យមែន » ។



**TAKEN BY Mr. john J KATT**

តាមការស្រាវជ្រាវដើម្បីស្វែងយល់អោយបានច្បាស់លាស់អំពីប្រវត្តិរបស់ភ្នំនេះ គឺមិនបានជួបអ្នកណាម្នាក់ដែលបានដឹងរឿងរ៉ាវប្រាកដច្បាស់លាស់នោះទេ ប៉ុន្តែគ្រាន់តែបានដឹងតាមការតំណាលតៗ គ្នារបស់មនុស្សជំនាន់មុន នៅតំបន់

---

(១). Bungalow : ផ្ទះសំរាកលំហែកាយ

នោះតែប៉ុណ្ណោះ ។ ជាពិសេស ខ្ញុំក៏មានកំនើតនៅទីនោះដែរ បានឮតំណាលតៗគ្នានេះ ដោយផ្ទាល់នឹងត្រចៀកតាមរយៈលោកអាចារ្យ **ឆិត្យ ស៊ុម** ដែលជាអតីតជាលោកគ្រូសូត្រស្តាំវត្តជ្រៃហូរញ្ញេ សម័យមុនឆ្នាំ ១៩៧១ ។ សព្វថ្ងៃនេះ គាត់ជាព្រឹទ្ធាចារ្យម្នាក់គួរជាទីគោរពនៃមនុស្សទាំងឡាយនៅតំបន់នោះ ដោយមានសេចក្តីទាំងស្រុងដូចតទៅ ៖

មានសេចក្តីមួយតំណាលតគ្នាមកថា មានថ្ងៃមួយ ក្នុងកាលកន្លងទៅជាយូរណាស់មកហើយ មានស្តេចមួយអង្គដែលមានព្រះនាម និង គោត្តនាមមិនប្រាកដ បាននាំរាជបរិពារជាច្រើន ដើម្បីកំសាន្តព្រះរាជហឫទ័យនៅភ្នំនេះ ។ លុះយាងមកដល់ហើយ ព្រះអង្គរួមជាមួយនឹងរាជបរិពារ ក៏បានទៅប្រថាប់នៅក្រោមដើមជ្រៃធំមួយដើម ដែលស្ថិតនៅលើកំពូលភ្នំនោះ ។ ម្លប់ជ្រៃត្រឈឹងត្រឈៃ ព្រមទាំងមានខ្យល់អាកាសល្អបរិសុទ្ធ លាយឡំសំឡេងបក្សាបក្សី ដែលនៅលើដើមជ្រៃ និង ដើមញ្ញេជាច្រើននៅក្បែរនោះ ធ្វើអោយបរិយាកាសគួរជាទីសែនមនោរម្យក្រៃលែង ។ ក្នុងពេលនោះដែរ មានបរិពារម្នាក់បានយកផ្លែញ្ញេទុំរលោង ដែលមានក្លិនក្រអូបឈ្ងុយមួយមកថ្វាយព្រះអង្គ ពេលនោះព្រះអង្គសព្វព្រះរាជហឫទ័យយ៉ាងខ្លាំង ទើបហៅតាហោរពិសេសរបស់ព្រះអង្គម្នាក់អោយមកទាយថ្វាយ ព្រះអង្គក៏ទ្រង់បានសួរទៅកាន់តាហោរថា : « មើល៍តាហោរ ផ្លែញ្ញេដែលយើងកាន់នៅដៃនេះ តើយើងនឹងបានសោយរឺទេ ? » ។ ចំណែកតាហោរវិញ ក៏បានគន់គូរលេខអត្ថៈតាមព្រះរាជបញ្ជា ក្រោយពីគន់គូរលេខសព្វគ្រប់ហើយ ក៏ក្រាបបង្គំទូលព្រះរាជាថា : « ព្រះករុណាថ្លៃវិសេស ព្រះអង្គមិនបានសោយផ្លែញ្ញេនេះទេក្រាបទូល » ។ ពេលនោះ ព្រះរាជាទ្រង់ព្រះពិរោធយ៉ាងខ្លាំង ក៏ចាប់យកផ្លែញ្ញេនោះមកចោលចំតាហោរ ។ ប៉ុន្តែ តាហោរនោះបានគេចទាន់ ។ ចំណែកឯផ្លែញ្ញេវិញ ក៏បានទៅប៉ះដុំថ្មមួយដុំនៅក្បែរនោះ ហើយក៏បានធ្វើអោយផ្លែញ្ញេនោះបែកខ្ទេចខ្ទី ដោយខ្ទាតទៅលើដី ដែលធ្វើអោយព្រះរាជាពុំបានសោយផ្លែញ្ញេនោះមែន ។ ព្រះអង្គក៏បានដាក់ងារហោរនោះថា « **ហោរញ្ញេ** » ដោយភ្នំនោះមានដើមជ្រៃ និងដើមញ្ញេជាច្រើនផងនោះ ទើបបានគេប្រសិទ្ធិនាមថា **ភ្នំជ្រៃហោរញ្ញេ** ។ ប៉ុន្តែ ការហៅភ្នំនេះរបស់ប្រជាជន បានក្លាយទៅជា **ភ្នំជ្រៃហូរញ្ញេ** រហូតមកដល់សព្វថ្ងៃនេះ ។ រីឯដើមញ្ញេ ក៏មានរហូតមកដល់សព្វថ្ងៃនេះដែរ ។

ម្យ៉ាងវិញទៀត ប្រសិនបើយើងធ្លាប់ស្គាល់ភ្នំជ្រៃហូរញ្ញេ មុនឆ្នាំ ១៩៧០ ហើយបានទៅម្តងទៀតក្រោយឆ្នាំ ១៩៧៩នោះ យើងនឹងឃើញមានលក្ខណៈប្លែកគ្នាឆ្ងាយណាស់ គួរអោយសោកស្តាយក្រៃលែង ដោយសារការយកភ្នំនេះ ធ្វើជាមន្ទីរឃុំឃាំង និងមណ្ឌលប្រល័យពូជសាសន៍របស់ពួកឧក្រិដ្ឋជនប៉ុលពត ។ ពួកវាបានកាប់បំផ្លាញរុក្ខជាតិធំៗដែលមានអាយុរាប់រយឆ្នាំគ្មានសល់ ។ វត្តជ្រៃហូរញ្ញេខាងក្រោមត្រូវបានពួកក្បត់ជាតិនេះរុះបំផ្លាញគ្មានសល់អ្វីបន្តិចសោះឡើយ ព្រមទាំងសាលាបាលី សាលារៀនបឋមសិក្សា និង អនុវិទ្យាល័យក៏ត្រូវបានបំផ្លាញអស់រលីង ដែលមិនគួរអោយយើងអត់អោនអោយបានទេ ។

ប៉ុន្តែក្រោយឆ្នាំ ១៩៧៩ មកដល់បច្ចុប្បន្ននេះ អ្វីៗទាំងអស់ត្រូវបានកសាងឡើងវិញ ដោយកំលាំងសាមគ្គីរបស់ប្រជាជន សប្បុរសជន អង្គការអភិវឌ្ឍន៍ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដូចជាវត្តទាំងពីរ សាលាបាលី សាលារៀន និងដើមឈើ ត្រូវបានដាំឡើងវិញហើយ ដែលកំពុងតែលូតលាស់យ៉ាងស្រស់បំព្រងគួរជាទីសប្បាយរីករាយ ។

ដូច្នេះ សរុបសេចក្តីទៅ **ភ្នំជ្រៃហូរញ្ញេ** គឺជាកន្លែងមួយដែលមានលក្ខណៈជាមណ្ឌលទេសចរ តាំងពីយូរយារណាស់មកហើយ ដោយព្រះរាជាបានយកកន្លែងនោះទុកជាកន្លែងសំរាប់កំសាន្តព្រះទ័យ ។ មិនត្រឹមតែប៉ុណ្ណោះ មានទីតាំងនៅក្បែរភ្នំនោះ មានឈ្មោះថា ជាកន្លែងដែលព្រះរាជាទៅកំសាន្តទៀតផង ដូចជាព្រៃហ្លួង ត្រពាំងហ្លួង ដែលស្ថិតនៅជាប់នឹងភូមិព្រៃខ្លុង រហូតមកដល់បច្ចុប្បន្ននេះ ។

លោក **គង ឌិម**

# ទិសដៅ និង ភារកិច្ចអប់រំ យុវជន និង កីឡា ឆ្នាំសិក្សា១៩៩៧-៩៨ (១)

ផិតពីរទសវត្សរ៍កន្លងមកនេះ ការងារអប់រំបានអភិវឌ្ឍន៍ជាលំដាប់ទាំងបរិមាណ និងគុណភាព ដោយផ្សារភ្ជាប់ជាមួយបរិស្ថាននយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជា ។ នេះជាការឈានឡើងជាវិជ្ជមាន ឆ្លើយតបនឹងតម្រូវការចាំបាច់របស់ប្រទេសជាតិ ក្នុងដំនាក់កាលស្ដារ និងកសាងឡើងវិញ ។

ស្របតាមទស្សនៈនៃទិន្នាការសកល « **អប់រំសំរាប់ទាំងអស់គ្នា ទាំងអស់គ្នាដើម្បីអប់រំ** » និងក្នុងបរិបទនៃផែនការវិនិយោគ ៥ឆ្នាំ (១៩៩៥-២០០០) ដើម្បីស្ដារ និងអភិវឌ្ឍន៍ប្រទេសជាតិ ដែលបានកំនត់ថាអាទិភាព នៃការអភិវឌ្ឍន៍ធនធានមនុស្ស ជាកត្តាដ៏សំខាន់មួយក្នុងចំនោមកត្តាសំខាន់ទាំង ៣ ។ ក្រសួងអប់រំ យុវជន និង កីឡា បានលើកគោលនយោបាយ និង ទិសដៅចំបងដែលមានជាអាទិ :

១- អប់រំចំនេះទូទៅជាមូលដ្ឋាន ៩ឆ្នាំ និង អភិវឌ្ឍន៍អក្ខរកម្មវិជ្ជាជីវៈ

២- ទំនើបកម្ម និង កំនែលំអគុណភាពអប់រំតាមរយៈការកែទំរង់ដ៏មានប្រសិទ្ធភាព

៣- ការផ្សារភ្ជាប់ការអប់រំបណ្ដុះបណ្ដាលទៅនឹងតំរូវការទីផ្សារពលកម្ម និងសង្គម

៤- ការស្ដារ និងអភិវឌ្ឍន៍ការងារយុវជន និង កីឡា ។



(១). ស្រង់ចេញពីសៀវភៅ « ប្រជុំបូកសរុបវាយតំលៃឆ្នាំសិក្សា 1996 - 1997 ទិសដៅ និង សកម្មភាពឆ្នាំសិក្សា 1997 - 98 »

ដើម្បីអនុវត្តគោលនយោបាយអប់រំខាងលើអោយមានប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និង កីឡា បានកំនត់ទិសដៅធំៗ ៣ សំរាប់ជាត្រីវិស័យ ។

១. យកចិត្តទុកដាក់ប្រមូលកុមារ យុវជន ប្រជាជន អោយចូលរៀនបានគ្រប់ៗគ្នា ជាពិសេសកុមារជួបការលំបាក កុមាររស់នៅក្នុងតំបន់ដាច់ស្រយាល កុមារជាកូនជនជាតិភាគតិច ដោយសិក្សារិះរកគោលនយោបាយផ្សេងៗ សំរាប់អនុវត្តសមធមិក្នុងការអប់រំ និង ឱកាសទទួលការអប់រំបានចប់ឆ្នាំសិក្សា ចប់ភូមិសិក្សា ឈានដល់ទទួលការអប់រំមូលដ្ឋាន៩ឆ្នាំ ។ ពង្រឹងសមត្ថភាពស្រូបសិស្ស - និស្សិតចូលរៀននៅឧត្តមសិក្សា និង អប់រំបច្ចេកទេស បណ្តុះបណ្តាលវិជ្ជាជីវៈ ។

២. លើកកំពស់គុណភាពអប់រំ បណ្តុះបណ្តាល ដោយបង្កើនសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន ពង្រីកលទ្ធភាពនៃការប្រើប្រាស់សៀវភៅសិក្សា សំភារៈឧបទេស និងការបញ្ជ្រាបខ្លឹមសារថ្មីៗ ពាក់ព័ន្ធដល់តំលៃស៊ីលធមិ ភាវតភាពប្រជាធិបតេយ្យស្របតាមកម្មវិធីថ្មីនៃប្រព័ន្ធអប់រំ ១២ឆ្នាំ និងកែលំអទិដ្ឋភាពសាលារៀន ជួសជុល សាងសង់បន្ទប់រៀន អគារសិក្សាទីចាត់ការ - បង្កើនទំនាក់ទំនង និងការចូលរួមគ្រប់រូបភាពរបស់សហគមន៍ក្នុងវិស័យអប់រំ ។ ជាមួយនេះ ក៏ខិតខំប្រឹងប្រែងស្តារ និងរៀបចំរចនាសម្ព័ន្ធ ការគ្រប់គ្រងផ្នែកកីឡា និង យុវជន ។ បង្កើនល័ក្ខខ័ណ្ឌថវិកា និងសំភារៈធ្វើជាបុព្វបទ ដើម្បីពង្រីក និងពង្រីកឧត្តមសិក្សា និង អប់រំបច្ចេកទេស បណ្តុះបណ្តាលវិជ្ជាជីវៈ ទាំងបរិមាណ និង គុណភាព ។

៣. កែលំអបណ្តើរៗ ការងារគ្រប់គ្រងធនធានមនុស្ស ហិរញ្ញវត្ថុ សំភារៈ បរិក្ខារ នៅគ្រប់លំដាប់ថ្នាក់ តាំងពីថ្នាក់ក្រសួងដល់សាលារៀន ដោយការបំប៉នសមត្ថភាពជំនាញដល់មន្ត្រីគ្រប់គ្រង សំរួលមធ្យោបាយបំពេញការងារ បង្កើនការទទួលខុសត្រូវតាមលំដាប់ថ្នាក់ ធ្វើសនិទានកម្មមន្ត្រីគ្រប់គ្រង និង ឈានអនុវត្តវិមជ្ឈការការងារគ្រប់គ្រងអប់រំ ។

ផ្អែកលើលទ្ធភាពប្រទេសជាតិ បរិស្ថាន និង សក្តានុពលសង្គម ក្នុងភារកិច្ចអនុវត្តទិសដៅខាងលើក្រសួងអប់រំ យុវជន និង កីឡា បានដាក់ចេញនូវយុទ្ធវិធីដូចតទៅ ៖

## I. ការប្រមូលកុមារ - យុវជន - អនក្ខរជនអោយចូលរៀនគ្រប់ៗ គ្នា

ដើម្បីធានាសមធមិក្នុងការចូលរៀន ចាំបាច់ត្រូវសិក្សារិះរកគោលនយោបាយនានា ធនធានមនុស្ស និងសំភារៈដែលបង្កឱកាសអោយប្រជាពលរដ្ឋបានទទួលការអប់រំ ។ ដូចនេះ យើងត្រូវ ៖

- បន្តអនុវត្តការប្រើប្រាស់អោយអស់លទ្ធភាពបន្ទប់រៀន និង សំភារៈដែលមានស្រាប់ និង ខិតខំជួសជួល សាងសង់បន្ទប់រៀនថ្មីទៀត សំរាប់ជំនួស និង បន្ថែមលើតំរូវការចាំបាច់ ព្រមទាំងកែលំអទិដ្ឋភាពទូទៅនៃសាលារៀនផង ។
- បន្តពង្រឹងកំរងសាលារៀនដែលរៀបចំហើយ ស្របតាមបញ្ញត្តិកំរងសាលារៀន ក្នុងកិច្ចសហការជួយគ្នាអោយមានវឌ្ឍនភាពទាំងរូបវ័ន្ត ទាំងបច្ចេកទេស ដោយបង្កើនតួនាទីចូលរួមរបស់សហគមន៍ និង អង្គការផ្សេងៗតាមគ្រប់រូបភាព ។
- សិក្សាលទ្ធភាព លើកគោលការណ៍បំប៉នគ្រូបង្រៀនថ្នាក់គួប និងកសាងសាលារៀនអន្តេវាសិកដ្ឋាននៅតំបន់ដាច់ស្រយាល តំបន់មានការលំបាក និង តំបន់ជនជាតិភាគតិច ។
- បន្តកសាងសំរាំងសាលារៀននៅតាមខេត្ត - ក្រុង : សាលាមត្តេយ្យសិក្សាគំរូ សាលាបឋមសិក្សាគំរូ អនុវិទ្យាល័យគំរូ វិទ្យាល័យគំរូ ។
- ខិតខំសហការជាមួយស្ថាប័ន និង អង្គការនានា ដើម្បីបើកថ្នាក់អក្ខរកម្មវិជ្ជាជីវៈ និង បំពេញវិជ្ជាដោយផ្សារ

ភ្ជាប់កម្មវិធីអប់រំមូលដ្ឋានក្រៅប្រព័ន្ធ ទៅនឹងការបណ្ដុះបណ្ដាលបច្ចេកទេសមុខជំនាញ និង សកម្មភាពបង្កើនប្រាក់ចំណូល ។

- រក្សាគុណភាពនៃការបណ្ដុះបណ្ដាលនៅឧត្ដមសិក្សា និង សិក្សាឯកទេស រវាងគុណភាពនឹងបរិមាណ ដើម្បីឆ្លើយតបជាជំហានៗ នឹងតំរូវការ និង ការវិវត្តន៍របស់សកលលោក ។
- កែលំអការងារយុវជន ទាំងនៅក្នុង និងក្រៅសាលារៀន ដោយសិក្សាលទ្ធភាពផ្ដល់ការបណ្ដុះបណ្ដាលមុខរបរបច្ចេកទេសវិជ្ជាជីវៈ តួបផ្សំនឹងសកម្មភាពមានប្រយោជន៍ដល់សង្គមជាតិ និងរៀបចំការបោះជំរំថ្នាក់ជាតិ និងអន្តរជាតិ តាមរយៈកិច្ចសហប្រតិបត្តិការនានា ។
- បង្កើនសកម្មភាពអប់រំកាយ និង ការហ្វឹកហាត់កីឡា បំពាក់បំប៉នបច្ចេកទេស ការគ្រប់គ្រងវិន័យលើកទឹកចិត្តកីឡាករ និង សហការជាមួយគ្រប់មូលដ្ឋាន អង្គការនានា ក្រុមហ៊ុនឯកជន សប្បុរសជន ដើម្បីស្ដារហេដ្ឋារចនាសម្ព័ន្ធកីឡា និង ផ្នែកសំភារៈបច្ចេកទេស ។



## II. ការបង្កើនគុណភាពអប់រំ - បណ្ដុះបណ្ដាល

សមត្ថភាពជំនាញ និង ល័ក្ខខ័ណ្ឌបំពេញការងាររបស់គ្រូបង្រៀន ជាកត្តាគន្លឹះដល់គុណភាពអប់រំ ។ ដូចនេះត្រូវយកចិត្តទុកដាក់ ៖

- បន្តបង្កើនសមត្ថភាព និងមនសិការវិជ្ជាជីវៈជូនបុគ្គលិកសិក្សាលើផ្នែកចំនេះដឹងទូទៅ បទពិសោធ សម្បទាវិជ្ជាជីវៈ និងការគ្រប់គ្រង ។

- បន្តការអភិវឌ្ឍន៍សៀវភៅសិក្សាតាមកម្មវិធីសិក្សាប្រព័ន្ធអប់រំថ្មី ១២ឆ្នាំ សទិទានកម្មការប្រើប្រាស់សៀវភៅសិក្សា និងសំភារឧបទេស ។
- ធ្វើការសិក្សាកែលំអ ការវាយតំលៃសិក្សា រៀបចំប្រព័ន្ធតេស្តត្រួតពិនិត្យលទ្ធផលសិក្សាតាមថ្នាក់សំរាប់ជាមធ្យោបាយជួយដល់ការប្រលងបញ្ចប់មធ្យមសិក្សាបឋមភូមិ និង ទុតិយភូមិ ។
- ស្វែងរកធនធានពង្រឹងអធិការកិច្ច ត្រួតពិនិត្យការងារគ្រប់គ្រងគ្រប់ផ្នែក : គ្រប់គ្រងកម្មវិធីសិក្សា គ្រប់គ្រងធនធានមនុស្ស និងគ្រប់គ្រងហិរញ្ញវត្ថុ - សំភារៈ ។
- ជំរុញការកែសំរួលល័ក្ខខ័ណ្ឌបំពេញការងាររបស់មន្ត្រីអប់រំ និង រិះរកគោលនយោបាយឧបត្ថម្ភអោយបានសមស្របដល់បុគ្គលិកសិក្សា នៅតំបន់ព្រៃភ្នំដាច់ស្រយាល និងតំបន់ដែលមានការលំបាក ។
- បន្តកែលំអរចនាសម្ព័ន្ធ និង ការគ្រប់គ្រងឧត្តមសិក្សា ដើម្បីលើកកំពស់គុណភាពនៃការបណ្តុះបណ្តាលនៅឧត្តមសិក្សា មធ្យមសិក្សាឯកទេស និង បណ្តុះបណ្តាលវិជ្ជាជីវៈ ។
- បន្តសិក្សារៀបចំគោលនយោបាយកសាងសិស្សពូកែ ។
- លើកកំពស់គុណភាពការងារគ្រប់គ្រង និង បច្ចេកទេសដល់យុវជនក្នុង និង ក្រៅសាលារៀន ។
- ស្តារ និង ពង្រីកសកម្មភាពកីឡា និង អត្តពលកម្ម ។

## III. ពង្រឹងផែនការកម្ម និង គ្រប់គ្រង

- បន្តពង្រីកប្រព័ន្ធពតិមានគ្រប់គ្រងអប់រំ ពីផ្នែកសាធារណៈទៅផ្នែកឯកជន ដើម្បីអោយមូលដ្ឋានពតិមាននៃការគ្រប់គ្រងអប់រំកាន់តែពេញលេញ ។
- បន្តបណ្តុះបណ្តាលសមត្ថភាពជំនាញមន្ត្រីគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ : ថ្នាក់ក្រសួង ថ្នាក់ខេត្ត - ក្រុង ថ្នាក់ស្រុក - ខ័ណ្ឌ និងឈានដល់នាយកកំរងសាលារៀន ដោយប្រើប្រាស់ម៉ូឌុលទាំង ៧នៃឯកសារផ្នែកផែនការកម្ម ការគ្រប់គ្រង និង រដ្ឋបាលអប់រំ ។
- បន្តបើកវគ្គសិក្ខាសាលាដល់មន្ត្រីគ្រប់គ្រង អោយចេះប្រើប្រាស់ពតិមាន ដែលផលិតដោយមជ្ឈមណ្ឌលប្រព័ន្ធពតិមានគ្រប់គ្រងអប់រំ ក្នុងការលើកផែនការអភិវឌ្ឍន៍ផ្សេងៗ នៃតំរូវការជាក់ស្តែងមូលដ្ឋាន សំដៅពង្រឹងការទទួលខុសត្រូវ ដែលជាវិធានការឈានទៅរកវិមជ្ឈការនៃការគ្រប់គ្រងអប់រំ ។
- កែលំអការគ្រប់គ្រងមន្ត្រីរាជការ និងលិខិតបទដ្ឋាននានា ធ្វើសនិទានកម្មមន្ត្រីគ្រប់គ្រងលំដាប់ថ្នាក់ រួមចំណែកក្នុងកំនែទំរង់មុខងារសាធារណៈរបស់មន្ត្រីរាជការ ។

# សិស្សយើងខ្សោយតែងសេចក្តីណាស់ !

## Nos élèves sont faibles en rédaction

តាមរយៈការងារអធិការកិច្ចនៅតាមសាលារៀនបឋមសិក្សា មធ្យមសិក្សា និងតាមរយៈកំនែវិញ្ញាសាប្រលងវិញ្ញាបនប័ត្របឋមសិក្សា សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និង ទុតិយភូមិ ការប្រលងសិស្សពូកែទាំងបីកំរិតសិក្សា ការប្រលងប្រជែងចូលមហាវិទ្យាល័យ និងវិជ្ជាជីវៈនានាមក យើងបានសង្កេតដោយព្រួយបារម្ភថា : **សិស្សយើងខ្សោយតែងសេចក្តីណាស់ !** ។ សិស្សានុសិស្សអាចធ្វើការប្រឹងប្រែងបានរីកចំរើនផ្នែកអំណាន និង ផ្នែកគណិតវិទ្យា តែគេកំរណាស់នឹងបានរីកចំរើនផ្នែកតែងសេចក្តី ដែលគេមានឧត្តមគតិសមហេតុផល តែពិបាកសំរេចជោគជ័យថា : « ចេះសរសេរអោយបានត្រឹមត្រូវ និងចេះរកពាក្យដាក់អោយបានចំក្នុងការបញ្ចេញគំនិត » « Savoir écrire correctement et trouver les mots propres pour exprimer leurs pensées» ។

បណ្តាលំហាត់ទាំងអស់ តែងសេចក្តីជាលំហាត់សំខាន់ជាងគេ ។ ការបង្រៀនមុខវិជ្ជានេះ ជួបប្រទះការលំបាក និងជាញឹកញយទទួលបានការខកចិត្ត ។

តើសិស្សយើងខ្សោយតែងសេចក្តីនេះបណ្តាលមកពីហេតុអ្វីខ្លះ ? តើតែងសេចក្តីមានអត្ថប្រយោជន៍អ្វីខ្លះ ? តើវិធីសាស្ត្រក្នុងការបង្រៀនតែងសេចក្តីយ៉ាងដូចម្តេចខ្លះ ? ដើម្បីដណ្តើមជោគជ័យក្នុងមុខវិជ្ជានេះបាន តើគ្រូបង្រៀនត្រូវមានប្រការណាខ្លះដែលគួរចងចាំ ?

## I. សិស្សយើងខ្សោយតែងសេចក្តីណាស់ !

មូលហេតុមានច្រើនតែគេអាចសង្កេតឃើញជាអាទិ « ជំងឺងាយព្យាបាលណាស់ កាលណាស្គាល់រោគច្បាស់ » « Il est facile de guérir un mal que l'on connait bien »

១. ជាទូទៅសិស្សយើងនិយាយមិនល្អដោយទំលាប់ទទួលឥទ្ធិពលពីគ្រួសារ និង ពីសង្គមដែលនិយាយភាសាគ្មានល្បះ គ្មានឃ្លា គ្មានប្រយោគ មិនចំពាក្យសង្ខេបឃ្លាប្រយោគដែលផ្ទុយពីភាសារៀន ។

២. ការបង្រៀនរៀនអាន និងមេសូត្រត្រង់មាត់ « **អត្ថបទគំរូ** » ដែលជាទុនសំខាន់ខាងអត្ថរូប អត្ថន័យ ការរៀនហ្វឹកហាត់តែងសេចក្តី មិនបានរួមវិភាគទាន ក្នុងការហាត់តែងសេចក្តីដូចជាគំនិតសំខាន់ៗ និងឃ្លាប្រយោគល្អៗ ជាដើម ។

៣. ការប្រើប្រាស់ឃ្លាប្រយោគដោយវាចា តិចតួចពេក ភាសានិយាយត្រូវមានមុនភាសាសរសេរ ។ បើអោយសរសេរ មុននិយាយ សិស្សយើងមិនចេះសរសេរទេ ។ គឺជាការដាក់ទង្គំលពីមុខគោ ។

៤. ការបង្រៀនមិនបានត្រឹមត្រូវតាមវិធីសាស្ត្រ មិនគោរពកម្មវិធី មិនជ្រើសរើសប្រធាន មិនធ្វើគំរោងតែង គ្មានសំភារៈឧបទេសសំរាប់សង្កេត មិនធ្វើកំនែ និងរបាយការណ៍តែងសេចក្តីបានត្រឹមត្រូវ មិនពិនិត្យកំនែរបស់សិស្ស មិនបានលើកទឹកចិត្តសិស្សពូកែ . . . ចំនុចទី ៤ ចុងក្រោយនេះ ជាមូលហេតុសំខាន់ជាងគេ ដែលគ្រូបង្រៀនយើងត្រូវមានកាតព្វកិច្ចយកចិត្តទុកដាក់ជាពិសេស ។

## II. អត្ថប្រយោជន៍នៃមុខវិជ្ជាតែងសេចក្តី

### ១. ចំនេះតែងសេចក្តី និង ឆាកជីវិត

ក្នុងឆាកជីវិតយើងត្រូវការចំនេះខាងតែងសេចក្តីណាស់ ។ ការសរសេរសំបុត្រផ្នែករដ្ឋបាលក៏ដូចជាឯកជនដែរ ការថ្លែងសុន្ទរកថា ការប្រជុំ ។ល។ ត្រូវយកចំនេះ និងគោលការណ៍តែងសេចក្តីមកប្រើប្រាស់ជានិច្ច ដូចជាសេចក្តីផ្តើម តួសេចក្តី និងយោបល់បញ្ចប់ ទើបការងារនោះបានចំប្រធានសព្វគ្រប់មិនបាំចរហោច ចំណាយពេលវេលាដ៏មានតំលៃដោយឥតប្រយោជន៍ ។

### ២. មធ្យោបាយមួយរបស់គ្រូសំរាប់វាស់កំពស់ និងកំរិតយល់ដឹងរបស់សិស្ស

សិស្សបានសិក្សាពីគ្រូមុខវិជ្ជារៀនអាន មេសូត្រតែមាត់ សរសេរតាមអាន លំហាត់វេយ្យាករណ៍ វាក្យស័ព្ទ . . . ។ សិស្សធ្លាប់បានឆ្លើយនឹងសំនួរលោកគ្រូជាច្រើនរួចមកហើយ ក្រោមការណែនាំរបស់លោកគ្រូ ។ សិស្សបានពិនិត្យ សង្កេតមជ្ឈដ្ឋានដែលរស់នៅ : ផ្ទះ ភូមិ ឃុំ សាលារៀន មនុស្ស សត្វ ផលដំណាំ ចំការ ស្រែ រោងចក្រ វត្តអារាម ។ល។ ជាបន្តមកទៀត យើងបង្ហាត់សិស្សអោយធ្វើកិច្ចការសរសេរ « ប្រើភាសាសរសេរ » ជាឃ្លាប្រយោគត្រឹមត្រូវស្មោះត្រង់នឹងអ្វីដែលខ្លួនបានឃើញ បានឮ បានប្រព្រឹត្ត បានរំភើប . . . ។ ក្នុងការសរសេរនេះទៀតសោត ត្រូវមានព្រំដែនតាមសំណូមពររបស់ប្រធាន មិនបាចហោច គ្មានព្រំដែននោះទេ ។ គ្រូបង្រៀនត្រូវផ្តល់សេរីភាពក្នុងការបញ្ចេញយោបល់ បញ្ចេញមតិ និង ការផ្តោតអារម្មណ៍ទៅលើអ្វីមួយ ។ ចំពោះប្រធានដូចគ្នា ចំពោះវត្ថុត្រូវសង្កេតដូចគ្នា សិស្សទាំងអស់យល់ប្រធាន និងមើលវត្ថុនោះមិនដូចគ្នាទេ ។

ឧ. តេស្ត « Test » របស់លោក « Binet » ក្នុងការធ្វើតែងសេចក្តីអំពីស្លឹកឈើ ។ កូនស្រីភ្លោះរបស់គាត់ពីរនាក់ កូនទី ១ មាននិស្ស័យខាងអក្សរសាស្ត្រ និងកូនទី ២ មាននិស្ស័យខាងវិទ្យាសាស្ត្រ ។

## III. វិធី និង របៀបបង្រៀនតែងសេចក្តីនៅបឋមសិក្សា

### ១. របៀបជ្រើសរើសប្រធាន

ការជ្រើសរើសប្រធាន និង ការសរសេរប្រធានជាការងារមួយដែលគ្រូបង្រៀនគ្រប់រូប ត្រូវតែប្រុងប្រយ័ត្នពិចារណាអោយបានល្អិតល្អន់ ដាក់កំរិតអោយបានសមស្រប បើពុំនោះទេនឹងក្លាយទៅជាការខកការគួរអោយស្តាយ ។

យោងទៅលើ « អោយអំរែកត្រូវមើលស្មា » ថ្នាក់ទី ១, ទី ២, ទី ៣, ទី ៤, ទី ៥, និង ទី ៦, នឹងឆ្លើយតបតាមកម្មវិធីប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ ។ ប្រធានតែងសេចក្តីទាំងឡាយត្រូវសមស្របតាមសមត្ថភាពសិស្សថ្នាក់នីមួយៗ ។ វាដូចជាព្រិកហួសពេក កាលណាគេដាក់អោយកុមារថ្នាក់ទី ២ ពិពណ៌នាអំពីសត្វឆ្មា មួយ ហើយក៏វាហាក់ដូចជាល្ងាចហួស កាលណាគេដាក់អោយសិស្សថ្នាក់ទី ៣ តែងឃ្លាជំនួសប្រធានតែងសេចក្តីនៅចុងឆ្នាំថ្នាក់ទី ១ និងដើមឆ្នាំថ្នាក់ទី ២ ។ ការតែងសេចក្តីត្រូវជំនួសដោយលំហាត់បំពេញឃ្លាដែលខ្វះប្រធាន រឺកិរិយាស័ព្ទ រឺកម្មបទ ដោយវាចា និងដោយសរសេរ រឺដោយការតែងឃ្លា និងការឆ្លើយសំនួរដែលមានចំលើយត្រឹមត្រូវ ។

យើងត្រូវស្គាល់ប្រធានបទតែងសេចក្តី ពោលគឺនៅពេលរដូវប្រាំងគេមិនត្រូវដាក់ប្រធានអំពីការស្ទូងនោះទេ ។ នៅពេលបុណ្យភ្ជុំបិណ្ឌគេមិនត្រូវដាក់ប្រធានអំពីបុណ្យចូលឆ្នាំ រឺក៏បុណ្យកឋិនទាននោ ះទេ ។

យើងត្រូវចៀសវាងអោយសិស្សបញ្ចេញយោបល់ មនោសញ្ចេតនាខ្ពស់ហួសសមត្ថភាព និងការយល់ដឹងរបស់សិស្សឡើយ ។ ឧ. លិខិតដែលទាហានម្នាក់សរសេរទៅកាន់ឪពុកម្តាយនៅពេលដែលខ្លួនមកដល់ទីបញ្ជាការជាលើកដំបូង ។

លំដាប់លំដោយនៃជំហានឈានឡើងនៃប្រធានតែងសេចក្តីទាំងឡាយនៅបឋមសិក្សា ៖

១. លំហាត់បំពេញឃ្លា « ប្រធាន កិរិយាស័ព្ទ កម្មបទ »

២. តែងឃ្លាខ្លីៗ « ជុំវិញគំនិតប្រធានណាមួយ - ឥតផ្អែកលើប្រធានណាមួយ »

៣. ឆ្លើយនឹងសំនួរពីរ រឺ បីទាក់ទងនឹងវត្ថុដែលបានសង្កេតរួចហើយ ។ ចំលើយនៃឃ្លាទាំងឡាយផ្សំបានជាកូនតែងសេចក្តីតូចមួយ ។

៤. រាប់ឈ្មោះវត្ថុនៅក្នុងផ្ទះ នៅក្នុងសាលារៀន ប្រដាប់ប្រដាសិស្ស ប្រដាប់ប្រដាកសិករ ប្រដាប់ប្រដាជាងឈើ ប្រដាប់ប្រដាជាងដែក ។ល។ ដោយវាចា រឺដោយសរសេរ ។

៥. រាប់សកម្មភាពដែលគេបានធ្វើដោយវាចារួចដោយសរសេរ ។

៦. តែងសេចក្តីតូចៗ តាមរូបភាពគំនូរដែលបានអោយសិស្សពិនិត្យសង្កេតជាមុន ។

## កំនត់សំគាល់

ក. គ្រប់លំហាត់តែងសេចក្តីត្រូវបង្ហាញសំភារៈ រឺ កាយវិការជាមុន ។

ខ. ការងារនេះត្រូវគោរពសមត្ថភាព និងចិត្តសាស្ត្រកុមារ ។

៧. ពិពណ៌នាវត្ថុដែលនៅជុំវិញខ្លួន : សៀវភៅ តុ ក្តារខៀន . . .

៨. ពិពណ៌នាអំពីសត្វ : ឆ្កែ ឆ្មា ទា ជ្រូក គោ ក្របី សេះ . . .

៩. ពិពណ៌នាអំពីរុក្ខជាតិ : ដើមល្ហុង ដើមចេក ដើមស្វាយ ដើមខ្នុរ ដើមត្នោត ដើមឫស្សី . . .

១០. ពិពណ៌នាអំពីមនុស្ស : សិស្សល្អ ឪពុកម្តាយ ជីតាជីដូន លោកគ្រូ អ្នកគ្រូ កសិករ ជាងដែកជាងឈើ គ្រូពេទ្យ ជាងកាត់សក់ . . .

១១. អំពីទីកន្លែង : ផ្ទះ សាលារៀន វត្ត ផ្សារ . . .

១២. អំពីការដ្ឋាន : ការភ្ជួរស្រែ ការដាំពោត ការស្ទូងស្រូវ ពលកម្មសំអាតសាលារៀន ពលកម្មសង្គម ។ល។

១៣. អំពីបាតុភូត : ថ្ងៃរះ ថ្ងៃលិច ខ្យល់ព្យុះ ភ្លៀងរងា ក្តៅ ។ល។

១៤. អំពីទេសភាព : ស្រុកស្រែ ស្រុកក្រុង ស្រុកភ្នំ ស្រុកសមុទ្រ . . .

១៥. អំពីពិធីបុណ្យ : ប្រពៃណីជាតិ បុណ្យជាតិ បុណ្យអន្តរជាតិ បុណ្យចូលឆ្នាំប្រពៃណីជាតិ បុណ្យឯករាជ្យជាតិ បុណ្យភ្ជុំបិណ្ឌ បុណ្យទិវាកុមារអន្តរជាតិ . . .

១៦. និទានរឿងខ្លីៗ ដែលសមស្របតាមការយល់ដឹងរបស់សិស្ស និង មានខ្លឹមសារបំរើការងារអប់រំ បំរើសីលធម៌ សុជីវធម៌ សុភាវធម៌ជាដើម ។

១៧. ការសរសេរសំបុត្រ ជូនឪពុកម្តាយ ជីដូនជីតា មាមីង បងប្អូន លោកគ្រូ អ្នកគ្រូ មិត្តភក្តិ . . .

## កំនត់សំគាល់

ត្រូវចងក្រងជាក្រុមប្រធាន មនុស្ស បុណ្យ រុក្ខជាតិ សត្វ រឿងនិទាន សំបុត្រ . . . ហើយជាគ្រូបង្រៀនជាឪពុកម្តាយ ជាសិស្ស ជាសិស្សល្អ ជាសិស្សអាក្រក់ ជាជាងដែក ជាជាងឈើ . . . សិស្សអាចមានសមត្ថភាពធ្វើបាន ។

ផលវិបាកដែលមានរួចមកហើយ មានការប្រឡងធ្លាក់ជាដើម មកពីបេក្ខជនមិនបានយកចិត្តទុកដាក់ក្នុងការសិក្សាប្រធានអោយបានហ្មត់ចត់ ។ សិស្សអានប្រធានញាប់ពេក ហើយចាប់ផ្ដើមធ្វើតែងសេចក្ដីតែម្ដង ដូចជាការប្រលងជ្រើសរើសការងាររដ្ឋជាដើម ។

តាមការសង្កេតដ៏ខ្លីៗ នេះ យើងត្រូវមានការចាំបាច់ណែនាំសិស្សអោយសិក្សាប្រធានអោយបានហ្មត់ចត់មុននឹងធ្វើគំរោងតែងសេចក្ដី សេចក្ដីព្រាង និងការចំលងដាក់ក្រដាសស្អាត ។

**២. តើយើងត្រូវសិក្សាប្រធានយ៉ាងដូចម្ដេច ?**

- អោយសិស្សអានប្រធានពីរ រឺ បីដងដោយពិនិត្យពិច័យ ។
- អោយសិស្សគូសពាក្យគន្លឹះ ពាក្យសំខាន់ៗ ជាងគេ
- អោយសិស្សយល់ន័យរបស់ពាក្យ ។
- អោយសិស្សចាប់អោយបានទូវគំនិតរបស់ប្រធាន ។
- អោយសិស្សយល់ពីគោលដៅ និង ព្រំដែននៃប្រធានដែលគេចង់សួរយើងត្រឹមណា តើគេចង់អោយយើងនិយាយពីអ្វី ?

**៣. ការកសាងគំរោងតែង**

ពេលដែលសិក្សាប្រធាន ចាប់បានគំនិតនៃប្រធានរួចហើយ យើងមិនត្រូវអោយសិស្សចាប់សរសេរភ្លាមទេ ។ គ្រូបង្រៀនត្រូវណែនាំសិស្សអោយធ្វើជាគំរោងតែងសេចក្ដីមួយ ។

ការងារនេះត្រូវធ្វើជាសមូហភាពដោយវាចា និង ដោយសរសេរនៅក្ដារខៀន ដោយមានសំភារៈឧបទេស ព្រមទាំងសហការយ៉ាងសកម្មរវាងគ្រូ សិស្ស សិស្ស និង សិស្ស ធ្វើយ៉ាងណាអោយសិស្សមានមោទនភាពសប្បាយរីករាយក្នុងការកសាងបានទូវគំរោងតែងសេចក្ដីមួយដែលជាស្នាដៃរួម ក្រោមការដឹកនាំរបស់គ្រូខ្លួន ។ គឺជាថ្នាក់សកម្មមួយ ។

ថ្នាក់ទាំងមូលស្វែងរកគំនិតទាំងឡាយក្រោមការបំផុសសំនួររបស់លោកគ្រូ ។ គឺជាលំហាត់មួយក្នុងចំណោមលំហាត់ដែលមានលក្ខណៈរស់រវើកជាងគេនៅសាលារៀនបឋមសិក្សា កាលណាត្រូវបានដឹកនាំត្រឹមត្រូវ ។

- គំនិតគន្លឹះទាំងឡាយបានកត់ត្រានៅក្ដារខៀន ។
- បន្ទាប់មកបែងចែកគំនិតទាំងឡាយជាក្រុម ជាកថាខ័ណ្ឌបែបតក្កវិទ្យា ។
- បន្ទាប់មកទៀត គេឈានទៅពង្រីកគំនិតទៅតាមកថាខ័ណ្ឌនីមួយៗ ។

ក្នុងការណែនាំផ្លូវដែលត្រូវដើរ គ្រូទុកអោយសិស្សដើរដោយខ្លួនឯង ទើបសិស្សអាចបញ្ចេញគំនិតផ្ដួចផ្ដើមផ្ទាល់ខ្លួនបាន ។

ក្នុងមុខវិជ្ជាតែងសេចក្ដីនេះ គេមិនបានទាមទារអោយសិស្សចេះដូចជាប្រវត្តិវិទ្យា រឺវិទ្យាសាស្ត្រទេ ប៉ុន្តែចេះធ្វើ « Savoir- faire » ។ គេទាមទារជាដំបូងដៃ អោយសិស្សយល់ប្រធាន រកគំនិតសំរិតសំរាំង គំនិតរៀបចំគំនិតជាលំដាប់ និង អោយបញ្ចេញគំនិតដោយការសរសេរបានត្រឹមត្រូវ ។ ក្នុងលំដាប់នេះ គេណែនាំអោយសិស្សយល់ថា : ពីព្រោះអ្វីបានជាគេ ពិពណ៌នាពីអ្វីដែលគេបានឃើញមុនអ្វីដែលគេបានឮ ? ការពិពណ៌នារូបសម្បត្តិមុនការ ពិពណ៌នាអំពីចរិយាសម្បត្តិរបស់មនុស្ស ? ។

គ្រប់កិច្ចការតែងសេចក្ដីត្រូវមាន ៣ផ្នែកគឺ :

- សេចក្ដីផ្ដើម
- តួសេចក្ដី
- សេចក្ដីបញ្ចប់

**បញ្ចប់**

គ្រូត្រូវគោរពបុគ្គលិកលក្ខណៈរបស់កុមារ ដោយអនុញ្ញាតអោយកុមារបញ្ចេញពីអ្វីដែលជាគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន ។

**ក. សេចក្តីផ្តើម**

- បង្ហាញវត្ថុ សត្វ មនុស្ស ដែលត្រូវពិពណ៌នា ។
- បញ្ជាក់ដើមហេតុ ពេលវេលា ទីកន្លែង កាលៈទេសៈ ឆាក ផ្តើមរឿង

**ខ. តួសេចក្តី**

ត្រូវមានកថាខ័ណ្ឌច្រើន ដែលមានចង្កោមគំនិតរៀបរាប់តាមលំដាប់លំដោយ ហូរហែរតាមដំនើរ ដែលមិនត្រូវធ្វើតែពីសតែពាសគ្មានសណ្តាប់ធ្នាប់នោះទេ ដើម្បីផ្សំជាសំណុំគំនិតមួយល្អប្រសើរ ឆ្លើយទឹងបញ្ហា ដែលប្រធានបានចោទ ។

**១. បើសិនជាត្រូវរៀបរាប់ពីមនុស្ស ឪពុកម្តាយ លោកគ្រូ សិស្ស**

*គំរោងតែងសេចក្តីមានដូចតទៅ :*

- រូបសម្បត្តិ : អាយុ កំពស់ ខ្លួន មុខមាត់ លក្ខណៈពិសេស សំលៀកបំពាក់ របស់ប្រើប្រាស់ ។
- ចរិយាសម្បត្តិ : អត្តចរិត និងចរិយាជាគុណសម្បត្តិ និងជាគុណវិបត្តិ ។

**២. បើសិនជាត្រូវរៀបរាប់អំពីសត្វ : ឆ្កែ ឆ្មា មាន់ទា គោ ក្របី សេះ។**

*គំរោងមានដូច តទៅ :*

ទិដ្ឋភាពទូទៅ :

- ចំនែកទាំងឡាយនៃខ្លួនប្រាណ ដោយបញ្ជាក់លក្ខណៈសំខាន់ៗ
- ទំលាប់អត្តចរិត ចរិយារបស់វា
- ផលប្រយោជន៍ ដែលវាផ្តល់ដល់យើង

**៣. បើសិនជាត្រូវរៀបរាប់អំពីវត្ថុ : តុ កៅអី ក្តារខៀន**

*គំរោងតែងសេចក្តីមានដូចតទៅ :*

- ទិដ្ឋភាពខាងក្រៅ : រាង ពណ៌ ទំហំ ទីកន្លែង
- ទិដ្ឋភាពខាងក្នុង : ចំនែកផ្សេងៗ
- ការប្រើប្រាស់ និងផលប្រយោជន៍

**៤. បើសិនជាត្រូវនិយាយពីឆាកអ្វីមួយ**

*គំរោងតែងសេចក្តីមានដូចតទៅ :*

- ការរៀបចំឆាក រឺ មុនឆាក
- កន្លែង ពេលវេលា តួអង្គ
- ដំនើរការឆាក ដំណាក់កាលផ្សេងៗ នៃសកម្មភាព
- លទ្ធផល និងផលវិបាកនៃឆាក

គ. យោបល់បញ្ចប់

ការពិចារណាផ្ទាល់ខ្លួន យោបល់ផ្ទាល់ខ្លួន សញ្ចេតនាផ្ទាល់ខ្លួន ។

កាលណាសិស្សមានអ្វីដែលត្រូវនិយាយរួចហើយ នោះសិស្សគ្រាន់តែសរសេរអោយបានត្រឹមត្រូវតែប៉ុណ្ណោះ ។ ការសរសេរដោយប្រញាប់ប្រញាល់ និងដោយមិនបានគិតសព្វគ្រប់អាចបន្ថយតំលៃនៃកិច្ចការ ។

៤. សំណេរកិច្ចការ

ក. ក្រដាសព្រាងសំណៅ

សេចក្តីសង្កេត : ធ្វើគំរោងរួចហើយ សិស្សខ្លះសរសេរយកតែម្តង ការងារនេះមានផលអាក្រក់ណាស់ មានលុបច្រើនកន្លែង ខ្វះពាក្យពិបាកថែម មានអក្ខរាវិរុទ្ធពិបាកកែ ។ ស្នាដៃនេះ ទោះបីមានខ្លឹមសារខាងគំនិតល្អក៏ដោយ ក៏កខ្វក់ដែរ ពិន្ទុថយតាមនេះ ។ អាស្រ័យហេតុនេះពេលធ្វើគំរោងរួចហើយ គ្រូត្រូវណែនាំសិស្សអោយសរសេរលើក្រដាស់ព្រាងជាដាច់ខាត ។ ក្នុងក្រដាសព្រាងត្រូវសរសេរពាក្យ វោហារស័ព្ទអោយបានច្បាស់លាស់ ជៀសវាងពាក្យពិបាក ពាក្យដែលអាចច្រឡំន័យ ពាក្យច្រំដែល ចៀសវាងអក្ខរាវិរុទ្ធ ។ ឃ្លាទាំងឡាយត្រូវងាយ ច្បាស់លាស់ ជៀសវាងឃ្លាដែលវែងពេក ។

**កំនត់សំគាល់**

កន្លងមកមានការយល់ច្រឡំ អំពីការសរសេរតែងសេចក្តីនេះ ថាទាល់តែមាន ពាក្យវប្បធម៌ច្រើន និង មានប្រវែងវែងទើបបានពិន្ទុល្អ បានពិន្ទុច្រើន ។ តាមការពិតពាក្យវប្បធម៌ប្រើមិនចំន័យនាំអោយខាត ហើយតែងសេចក្តីដែលវែងពេកច្រើនតែច្រំដែល ហើយមានកំហុសច្រើនផង ។

នៅថ្នាក់ទី ៣ និងទី ៤ គេតែងចាប់អារម្មណ៍ទៅលើអត្ថរូបជាងអត្ថន័យ ។ នៅថ្នាក់ទី ៥ និងទី ៦គេចាប់អារម្មណ៍ទាំងអត្ថរូប និង អត្ថន័យ ។

ពេលសរសេរលើក្រដាសព្រាងសំណៅចប់ហើយ ត្រូវអានមួយ រឺពីរចប់ ហើយត្រូវលុបពាក្យណាប្រយោគណាដែលផ្តាំផ្តង កំហុសអក្ខរាវិរុទ្ធ រឺបន្ថែមឃ្លាប្រយោគណាដែលខ្វះខាត ។

ខ. ពេលអានក្រដាសសំណៅរួចហើយ ត្រូវចំឡងដាក់ក្រដាសស្អាត ព្រោះលោកអ្នកកែចាប់អារម្មណ៍ទៅលើអត្ថរូប និង អត្ថន័យ ជាពិសេសសោភណភាពក្នុងការតែងសេចក្តី ។ សិស្សត្រូវសរសេរពីរភាគបីនៃក្រដាស់ស្អាត ខាងស្តាំតាមគំរូខាងក្រោមនេះ ។

| | |
|---|---|
| ឈ្មោះ . . . . . . . . .<br>ថ្នាក់ទី . . . . . . . . . | ថ្ងៃ សៅរ៍ ទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៨១<br>**តែងសេចក្តី**<br>**ប្រធាន** : . . . . . . . . . . . . . . . . . . . . ។ |
| ពិន្ទុ . . . . . . . . . . | **មូលវិចាររបស់គ្រូ**<br>. . . . . . . . . . . . . . . . . . . . . |

## សេចក្តីអធិប្បាយ

| | |
|---|---|
| សំរាប់សេចក្តីផ្តើម ៤ រឺ ៥ បន្ទាត់ | ............................ ។ |
| សំរាប់តួសេចក្តី ២ ទំព័រ | ............................ ។ |
| សំរាប់យោបល់បញ្ចប់ ៣ រឺ ៤បន្ទាត់ | ............................ ។ |

**កំនត់សំគាល់**

គេមិនសរសេរពាក្យ « សេចក្តីផ្តើម តួសេចក្តី រឺយោបល់បញ្ចប់ » នៅក្នុងកិច្ចការតែងសេចក្តីទេ ។

លេខទាំងឡាយសរសេរជាអក្សរ ។

នៅពេលប្រឡងកិច្ចការតែងសេចក្តី អំពីសំបុត្រ មិនត្រូវដាក់ឈ្មោះ រឺចុះហត្ថលេខាខាងក្រោមឡើយ ។

ពេលសរសេរបានស្អាតបាតហើយ ត្រូវអានជាថ្មីម្តងទៀតក្រែងមានអក្ខរាវិរុទ្ធ រំលងពាក្យ រឺ លើសពាក្យណាមួយ ។

### ៥. កំនែតែងសេចក្តី

#### ក. កំនែកិច្ចការសិស្ស

ការកែតែងសេចក្តី គឺជាការបង្ហាញដល់សិស្សនូវកំហុសទាំងឡាយដែលសាមីខ្លួនធ្វើខុស ។

ក្រោយពេលដែលសិស្សធ្វើតែងសេចក្តីចប់សព្វគ្រប់ហើយ គ្រូបង្រៀនត្រូវប្រមូលយកទៅកែនៅផ្ទះអោយបានទៀងទាត់ និងហ្មត់ចត់ ។ ហាមកែនៅក្នុងថ្នាក់រៀន ដែលជាហេតុនាំអោយខាតពេល និងរំខានដល់ការរៀនសូត្រផង ។ កិច្ចការដែលប្រគល់ជូនលោកគ្រូហើយ សិស្សគ្មានរង់ចាំមើល សង្ឃឹមនិងទន្ទឹងថ្ងៃដែលប្រកាសលទ្ធផល ។ បើលោកគ្រូយើងមិនកែកិច្ចការ នោះនឹងក្លាយទៅជាឥតប្រយោជន៍ និងធ្វើអោយសិស្សខកចិត្ត និងចង់លែងធ្វើការដែលខ្លួនមិនបានទទួលលទ្ធផល ។ សិស្សមានជំនឿថាកិច្ចការដែលខ្លួនបានធ្វើផ្ចិតផ្ចង់ពិតជាគ្មានកំហុស ។ មានតែលោកគ្រូទេដែលជាអ្នកបង្ហាញកំហុសទាំងនោះ ។ កំហុសដែលមិនបានកែ នឹងមានជាប់រហូតក្នុងសន្តានចិត្តកុមារ ហើយនឹងមានតទៅទៀត ។ កំណែកំហុសត្រូវធ្វើម្តងមួយៗ រហូតទាល់តែអស់ ។

ជាគោលការណ៍កំហុសទាំងឡាយត្រូវគូសបន្ទាត់ ហើយធ្វើសញ្ញាដោយសញ្ញាប្រឌិត ។

ឧ. កំហុសវេយ្យាករណ៍ « វេ » « អក្ខរាវិរុទ្ធ » « អក្ខរា » ។ លោកគ្រូត្រូវប្រុងប្រយ័ត្នកែកំហុសដែលសិស្សមានសមត្ថភាពកែដោយខ្លួនឯង ។

**ចារសេចក្តីពន្យល់**

គឺអោយពិន្ទុ និងអោយមូលវិចារ បន្ទាប់ពីអានដោយផ្ចិតផ្ចង់មក ។ គឺកត់សំគាល់ដោយពន្យល់ហេតុផលដើម្បីពន្យល់សាមីសិស្សអំពីមូលហេតុនៃកំហុស ព្រមទាំងការពារកុំអោយកំហុសដដែលៗ កើតមានជាថ្មី ។

## សរងកំហុស

បន្ទាប់ពីធ្វើកំនែបានសព្វគ្រប់ហើយ លោកគ្រូត្រូវស្រង់កំហុសនានាទៅតាមផ្នែកអក្ខរាវិរុទ្ធ មិនចំន័យច្រំដែល វេយ្យាករណ៍មិនសមស្របដោយមានឈ្មោះសិស្សអ្នកធ្វើកំហុសផង ។ ត្រៀមអោយសិស្សកែកំហុសទាំងនោះដោយខ្លួនឯង ក្នុងករណីកំហុសទាំងនោះមិនពិបាកពេក ។ លោកគ្រូត្រូវកត់សំគាល់កំហុសរួម ការសង្កេតទូទៅ កំនត់សំគាល់ និង ចំនុចសំខាន់ៗ ដែលត្រូវសង្កត់ធ្ងន់នៅពេលពន្យល់ក្នុងថ្នាក់ រឺហៅតាមពាក្យបច្ចេកស័ព្ទ តែងសេចក្ដីថា « របាយការណ៍តែងសេចក្ដី » « compte-rendu de la rédaction » ។

## កំនត់សំគាល់

គ្រូយើងខ្លះ បានអោយពិន្ទុចំពោះសិស្សណាដែលសរសេរកិច្ចការមានសោភណ និងមានរបៀបរៀបរយ ។

**ខ. របាយការណ៍តែងសេចក្ដី**

ការងារនេះសំខាន់ជាងគេក្នុងការបង្រៀនតែងសេចក្ដី ។ការពន្យល់កំហុសក្នុងថ្នាក់ត្រូវមានលក្ខណៈសកម្ម សហការ និងសមូហភាព ។

*១. ត្រូវបង្ហាញកំហុសទូទៅ :* ការចាកប្រធាន ពន្យល់របៀបកែរំលឹកវេយ្យាករណ៍ រំលឹកវាក្យស័ព្ទ ដែលសិស្សមិនយល់ រឺ យល់ខុស កង្វះគំនិតក្នុងការនិយាយមិនក្បោះក្បាយ ឃ្លាប្រយោគមិនត្រឹមត្រូវ ការប្រើពាក្យខុសអត្ថន័យ . . .

*២. ត្រូវបង្ហាញកំហុសឯកជន :* ដោយអោយសាមីខ្លួន និង សមូហភាពកែ រឺ កែសំរួលឃ្លាប្រយោគ រឺអក្ខរាវិរុទ្ធ ។

*៣. ត្រូវបង្ហាញគុណសម្បត្តិសមូហភាព :* ការរិះគន់ចំរើនទាំងអត្ថន័យ ទាំងអត្ថរូប ។

**សំនូមពរ :** កុំអោយគុណវិបត្តិដដែលៗ កើតមានជាថ្មីឡើងវិញ ។

ហាមចែកកិច្ចការសិស្សមុនពេលពន្យល់ក្នុងថ្នាក់ ។

*៤. អំនានស្នាដៃល្អ :* ស្នាដៃល្អដែលសមរម្យជាងគេដែលលោកគ្រូកែរួចហើយ ត្រូវបានអានដោយម្ចាស់អត្ថបទអោយមិត្តរួមថ្នាក់ស្ដាប់ ។ សាមីខ្លួនម្ចាស់អត្ថបទពិតជាត្រេកអរ មានមោទភាព និងចង់បង្ហាញស្នាដៃជាថ្មីទៀតនៅពេលក្រោយ ។

សិស្សឯទៀតបានយល់ពីកំហុសខ្លួនពីគំនិតល្អៗ របស់មិត្ត ហើយក៏មា នចំនងចង់អោយស្នាដៃរបស់ខ្លួនត្រូវបានលោកគ្រូផ្ដល់កិត្តិយសអោយដែរ ។

*៥. កិច្ចការចុងក្រោយ :* គ្រូត្រូវទុកពេល ១៥នាទី ចុងក្រោយ ដើម្បីពិនិត្យការកែកំហុសរបស់សិស្សម្នាក់ៗ ។

*៦. សៀវភៅកិត្តយស សំរាប់តែងសេចក្ដី :* « Le cahier d’honneur pour la rédaction

នៅរាល់កិច្ចការតែងសេចក្ដី ពិតជាមានសិស្សសរសេរបានល្អពីរ រឺ បីនាក់ ។ កំហុសនានានៃស្នាដៃទាំងនេះ គ្រូកែរួចហើយ និងសាមីសិស្សក៏បានរួចហើយដែរ ។ លោកគ្រូអាចបង្កើតសៀវភៅកិត្តិយសមួយសំរាប់តែងសេចក្ដីដោយប្រមូលគ្រប់ស្នាដៃដែលល្អជាងគេ ។ សៀវភៅនេះមិនបណ្ដាលអោយនឿយហត់អ្វីទេក្នុងការបង្កើត ព្រោះថាគ្រាន់តែអោយសាមីសិស្សចំឡងដាក់ការងាររបស់ខ្លួន ក្នុងសៀវភៅកិត្តិយនេះទៅជាការស្រេចទៅហើយ ។ អំណោយផលល្អនៅត្រង់សិស្សសរសេរស្នា ដៃបានល្អច្រើន ។ សាមីសិស្សតែងត្រេកអរដោយខ្លួនមានកិត្តិយសបានត្រូវលោកគ្រូ សរសើរអំពី

ស្នាដៃរបស់ខ្លួន ។ សិស្សទាំងនេះពិតជាមានឆន្ទៈដ៏មាំចង់បានកិត្តិយសកន្លែងនេះនៅលើកក្រោយទៀត ។ សិស្សដទៃទៀតក៏មានឆន្ទៈចង់បានកិត្តិយសដ៏ឧត្តុង្គឧត្តមដែរ ។ នេះមិនតែជាការមានវឌ្ឍនភាពរី ? វាជាការប្រឡងប្រណាំងដ៏ល្អប្រសើរមួយ ។

ទង្វើបែបនេះមួយឆ្នាំសិក្សាកន្លងទៅ យើងនឹងចងបានជាសៀវភៅអនុស្សាវរីយ៍មួយសំរាប់ឆ្នាំសិក្សាសៀវភៅនេះគួរសរសេរជាចំនងជើងដូចតទៅ ៖

- សាលាបឋមសិក្សា . . .
- ស្រុក . . . ខេត្ត . . .

សៀវភៅកិត្តិយសសំរាប់តែងសេចក្តី ឆ្នាំសិក្សា ១៩៩៦ - ១៩៩៧

## IV. ប្រការដែលគ្រូបង្រៀនតែងចងចាំដើម្បីដណ្តើមជោគជ័យក្នុងការបង្រៀនមុខវិជ្ជាតែងសេចក្តី

**១. ការសង្កេតផ្ទាល់ក្នុងជីវភាពជាក់ស្តែងប្រចាំថ្ងៃ និងការសិក្សាដោយប្រុងប្រយ័ត្ននូវអត្ថបទគំរូនេះ ជាចំនុចពីរសំខាន់សំរាប់ឆ្លើយតប នឹងអត្ថប្រយោជន៍នៃតែងសេចក្តី និងសំរាប់ហ្វឹកហ្វឺនសិស្សអោយសរសេរបានល្អ។**

**ក. ការសង្កេតផ្ទាល់ក្នុងជីវភាពជាក់ស្តែងប្រចាំថ្ងៃ**

ការតែងសេចក្តី គឺជាការសិក្សាមជ្ឈដ្ឋាន ។ តាមរយៈការសង្កេត ដោយផ្ទាល់នូវជីវភាពប្រចាំថ្ងៃ គេអាចដកស្រង់បាននូវគំនិតដ៏រស់រវើក ។ លំហាត់ចាំបាច់ក្នុងការតែងសេចក្តី គឺដំនើរកំសាន្តសិក្សា ។ ដោយមានជំនួយពីសំនួរ និងគំរោងដែលបានធ្វើដោយលោកគ្រូ សិស្សចាប់ផ្តើមធ្វើការសង្កេត ។ គេអាចចែកសិស្សជាក្រុមតូចៗ ហើយចែកការងារអោយក្រុមនីមួយៗ ។ ពេលចប់ការងារនីមួយៗ គេដកស្រង់របាយការណ៍ប្តូរយោបល់ជាមួយក្រុមឯទៀត ដើម្បីធ្វើគំរោងទាំងអស់គ្នា ។ សិស្សមិនចេះសង្កេតមែនទែនទេ លោកគ្រូត្រូវណែនាំសិស្សអោយវែកញែកនូវចំនុចណាដែលសំខាន់ និងចំនុចណាដែលបន្ទាប់បន្សំ ។

ក្រោមឱវាទលោកគ្រូ សិស្សដកស្រង់បានការសង្កេតច្រើនណាស់ ហើយដោយសប្បាយរីករាយទៀតផង ។ ពេលនេះ យើងគ្រាន់តែសុំអោយបកស្រាយនូវអ្វីដែលសិស្សបានឃើញ បានសន្និដ្ឋាន គ្រេបរសជាតិអោយក្លាយជាប្រយោគដ៏ស្មោះត្រង់ ជាភាសាសរសេរអោយបានច្បាស់លាស់ពិតប្រាកដឥតខុសពីធាតុដើម ។ ឧ. បើយើងចង់អោយសិស្សសរសេរពីដើមចេក យើងណែនាំសិស្សអោយសង្កេតពីដើមចេកសិន រួចណែនាំសិស្សអោយសរសេរពីដើមចេកនេះ ដើម្បីអោយមានការសរសេរអំពីដើមចេកនេះមានពតិមានសមស្របអំពីដើមចេកមែនទែន ជាពិសេសដើម្បីអោយមានលំដាប់លំដោយល្អ គួរអោយសិស្សចាប់សង្កេតពីគល់ទៅចុង ។ យើងបានសង្កេតហើយគួរអោយសោកស្តាយថា តាមរយៈអធិការកិច្ចតាមថ្នាក់ខ្លះ នៅពេលម៉ោងបង្រៀនតែងសេចក្តី អំពីដើមចេក អំពីដើមដូង ដើមត្នោត ដើមស្វាយ ... គ្រូបង្រៀនយើងខ្លះណែនាំគំរោងតែងតែនៅក្នុងបន្ទប់រៀន ថ្វីបើរុក្ខជាតិទាំងនេះមានក្នុងរបងសាលាក៏ដោយ ។ សំភារឧបទេសដ៏មានតំលៃ និងមិនចំណាយទុននេះ បើនិយាយបែបកំប្លែងបន្តិចថា ជាសំភារឧបទេសដែលគ្មានចំណាយទុន ។ នេះជាការប្រព្រឹត្តបទល្មើសមួយ ប្រឆាំងនឹងបញ្ញាកុមារដែលត្រូវការសង្កេតផ្ទាល់ ។

### កំនត់សំគាល់

នៅក្នុងការបង្រៀន គណិតវិទ្យា ភូមិវិទ្យា វិទ្យាសាស្ត្រ ទាមទារអោយសិស្សសង្កេតមជ្ឈដ្ឋាន ដែលរស់នៅ ។

នៅក្នុងការបង្រៀនតែងសេចក្តី ក៏មាននិយាយអំពីការពិនិត្យសង្កេតមជ្ឈដ្ឋានដែរ ។ គ្រូបង្រៀនយើងមិនត្រូវយល់ច្រឡំអំពីការពិពណ៌នាអក្សរសិល្ប៍ « **តែងសេចក្តី**» និងអំពីការពិពណ៌នាវិទ្យាសាស្ត្រ « **វត្ថុស្វាធ្យាយន៍** » នោះទេ ។

ការពិនិត្យសង្កេតផ្ទាល់ជីវភាពជាក់ស្តែងប្រចាំថ្ងៃរបស់កុមារ គឺជាអាទិភាពមុនការសិក្សាអត្ថបទដោយប្រុងប្រយ័ត្ន ។ ការសិក្សាចិត្តសាស្ត្រកុមារបានប្រាប់យើងអោយដឹងថា : កុមារត្រូវការមេរៀនដែលមានលក្ខណៈរូបី មុនអរូបី ។ ដូចនេះយើងត្រូវណែនាំសិស្សអោយសង្កេតជាមុនសិន សឹមសិក្សាអត្ថបទជាក្រោយ ។

**១. ការសិក្សាដោយប្រុងប្រយ័ត្ននូវអត្ថបទទាំងឡាយ**

សិស្សបានពិនិត្យសង្កេតរួចហើយ សិស្សត្រូវយកលទ្ធផលនៃការពិនិត្យសង្កេតនោះ ទៅប្រៀបធៀបជាមួយអត្ថបទដែលមានប្រធានដូចប្រធាននៃការពិនិត្យសង្កេតដែរ ដើម្បីកែលំអ និងជាគំរូនៃការបញ្ចេញមតិផង និងជាគំរូនៃការរៀនសរសេរផង ។ គំរោងអត្ថបទ ពាក្យពេចន៍ច្បាស់លាស់ វោហារស័ព្ទ រចនាបថ មធ្យោបាយអត្ថបទល្អៗ ផ្តល់ជាគំរូផង ផ្តល់ជាវិធីពិនិត្យសង្កេតផង ផ្តល់ជារបៀបតែងសេចក្តីផង និងផ្តល់ជារបៀបបញ្ចេញមតិផង ។

### កំនត់សំគាល់

ហាមសិស្សសរសេរអត្ថបទគំរូមួយអោយចាំមាត់ ដើម្បីសរសេរនៅពេលប្រលង រឺពេលធ្វើកិច្ចការ ។

ការពិនិត្យសង្កេត និង ការសិក្សាអត្ថបទត្រូវការជំនួយគ្នាទៅវិញទៅមក ។ ក្នុងន័យនេះយើងអាចបង្កើតពាក្យបច្ចេកទេសគរុកោសល្យមួយក្នុងតែងសេចក្តីថា : « ការពិនិត្យ សង្កេត - ការសិក្សាអត្ថបទ »

**២. មុខវិជ្ជាណាក៏ដោយអាចជួយអភិវឌ្ឍន៍តែងសេចក្តីដែរ**

គរុវិទូម្នាក់ បានមានប្រសាសន៍ថា : « មេរៀនសីលធម៌ គឺជាមេរៀនតែងសេចក្តីដ៏ល្អ ។ មេរៀនវិទ្យាសាស្ត្រដែលដឹកនាំបានល្អ បង្រៀនយើងអោយចេះសង្កេតតាមរយៈនេះ នាំយើងអោយចេះពិពណ៌នា ។ ឆ្លើយនឹងសំនួរមេរៀន ប្រវត្តិវិទ្យា និងភូមិវិទ្យា តាមលំដាប់ និងតាមវិធីសាស្ត្រ គឺជាការបង្រៀនតែងសេចក្តី ។ គ្រប់សំនួរទាំងអស់ជាលំហាត់ភាសាបើសិនណាជាគេចេះកែបានត្រឹមត្រូវ » ។

បើសិនជាគេបង្រៀនកុមារអោយបញ្ចេញគំនិតបានត្រឹមត្រូវ លំហាត់គណិតវិទ្យាក៏អាចជួយអភិវឌ្ឍលំហាត់ភាសាដូចមុខវិជ្ជាដទៃដែរ ។ គេត្រូវយកការបង្រៀនតែងសេចក្តី ជាមជ្ឈមណ្ឌលប្រធានបទអចិន្ត្រៃយ៍ ទោះបីមុខវិជ្ជាណាក៏ដោយ ។

**៣. សិក្សាប្រៀបធៀបការបង្រៀនមុខវិជ្ជាតែងសេចក្តី ជាមួយមុខវិជ្ជាគំនូរ**

« គេអាចប្រៀបធៀបពីវិធីបង្រៀនគំនូរតាមបែបថ្មីជាមួយការបង្រៀនតែងសេចក្តី » ។ សព្វថ្ងៃសាស្ត្រាចារ្យ គំនូរដាក់តថភាពពីមុខកុមារ និង សាកសួរអោយកុមារគូរពីអ្វី ដែលគេបានឃើញដោយមធ្យោបាយផ្ទាល់ខ្លួនរបស់គេ ។ ឧទាហរណ៍និង ការហ្វឹកហាត់ត្រូវធ្វើមុន ។ កំកែ និង ការទិតៀនត្រូវធ្វើក្រោយហើយចេះប្រមាណ ដោយមិនសំញែងពេក និងដោយមានចិត្តប្រណី ។

**ក្បួនបង្រៀនគំនូរ**

« គ្រូល្អត្រូវតែជំរុញជាជាងទិតៀន អោយយោបល់ជាជាងកែ ស្នើជាជាងបង្ខំ » « Le bon maître doit exciter plus que critiquer, suggérer plus que corriger, proposer plus qu'imposer » ។ វិធីនេះគ្រូបង្រៀនយើងក៏អាចយកមកប្រើក្នុងការបង្រៀនតែងសេចក្តីដែរ ។

**៤. វិធីសាស្ត្រល្អ និងវិធីសាស្ត្រមិនល្អ**

ក្នុងវិធីសាស្ត្របង្រៀន គរុវិទូម្នាក់បានបំភ្លឺគ្រូបង្រៀនយើងថា : ជាទូទៅគ្រប់វិធីសាស្ត្រសុទ្ធតែអាក្រក់ បើសិនជាវិធីសាស្ត្រនោះមិនបានបណ្តាលចិត្តកុមារអោយចង់ចកស្រាយនូវចំណាប់អារម្មណ៍ និងអោយចង់រកសំនួនវោហារស័ព្ទ

ធ្វូនល្អមដើម្បីបកស្រាយចំណាប់អារម្មណ៍នេះ ។ គ្រប់វិធីសាស្ត្រសុទ្ធតែល្អ ប្រសិនបើវិធីសាស្ត្របណ្តាលចិត្តកុមារចង់ប្រឹងនូវបំណងទាំងពីរនេះ ។ វិធីសាស្ត្រនេះនឹងសុក្រឹត ប្រសិនបើបំណងនេះរីកដុះដាលដល់កុមារ រហូតដល់មានការស្រលាញ់ងប់ និងការស្រើបចិត្ត ។ « D'une manière générale, toute méthode est mauvaise si elle n'inspire pas à l'enfant, le désir de traduire ses impressions, de chercher pour cette traduction l'expression adéquate. Toute méthode est bonne si elle lui inspire ce double désir. Elle est parfaite si ce désir croit chez l'enfant jusqu'à la passion et l'enthousiame ».

### ៥. ចៀសវាងការធ្វើតំរោងតែងសេចក្តីដោយចំពេក និង ដោយជាក់លាក់ពេក

ប្រធានតែងសេចក្តីបានជ្រើសរើសរួចហើយ និង បានដាក់អោយសិស្សធ្វើ ។ ដោយសិស្សពុំទាន់មានបទពិសោធ គ្រូត្រូវណែនាំសិស្សអោយធ្វើតំរោងតែងរួម ។ ក្នុងការធ្វើតំរោងរួមនេះអ្នកគរុកោសល្យបានណែនាំ គ្រូបង្រៀនកុំអោយធ្វើតំរោងរួមដោយចំពេកព្រោះគេយល់ថា : « បើធ្វើដូចនេះកុមារនឹងបាត់គំនិតផ្តួចផ្តើម សេរីភាពក្នុងការបញ្ចេញសំនួនវោហារ និង ការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈ » ។

តំរោងតែងរួមនេះត្រូវជារបស់សិស្ស មិនមែនជារបស់គ្រូទេ ។ ប៉ុន្តែគេក៏មិនអាចហាមពីការធ្វើតំរោងតែងរួមជាសង្ខេប និងរហ័សនោះទេ ។

### ៦. ការអានអត្ថបទគំរូ មុននឹងធ្វើតំរោង

កិច្ចការគំរូរបៀបបង្ហាញការធ្វើកិច្ចការតែងសេចក្តី និង ទំរង់ទាក់ទងទៅនឹងការជ្រើសរើសពាក្យ « le choix des mots » ភាពត្រឹមត្រូវ « la correction » និងសេចក្តីច្បាស់លាស់នៃរចនាបថ « la clarté du style » ការអានកិច្ចការគំរូ មុនពេលធ្វើតំរោងតែងនេះធ្វើអោយអសកម្ម ។ សិស្សស្តាប់ដោយប្រុងប្រយ័ត្ន និងកត់ត្រាដើម្បីឈានទៅធ្វើអធិប្បាយតែងសេចក្តីមួយ ដូចអត្ថបទដែលខ្លួនបានឮ ។ សិស្សគ្មានបានបញ្ចេញគំនិតបង្កើតថ្មី និង គ្មានបានបង្ហាញបុគ្គលិកលក្ខណៈរបស់ខ្លួនទេ ។

គរុវិទូម្នាក់បានមានប្រសាសន៍ថា : ផ្តល់ដល់កុមារនូវគំនិត និងសំនួនសេចក្តីទាំងឡាយ ដែលបានធ្វើរួចស្រេចហើយនោះ គឺរុញច្រានគំនិតផ្ទាល់ខ្លួនរបស់កុមារដែលយើងមានករណីយកិច្ចត្រូវភ្ញាស់ ទៅជាអារ « ធ្វើអោយឥតផល ឥតថ្លៃ » « Fournir aux enfants des idées et des expressions, toutes faites, c'est refouler leurs pensées personnelles dont nous avons le devoir de favoriser l'éclosion ».

### ៧. កំណែ

លោកប៉ាយ៉ូត « Payot » គរុវិទូម្នាក់បានមានប្រសាសន៍ថា : « រាល់កំណែដែលទុកអោយកុមារអសកម្ម ដែលធ្លាក់ពីលើកៅអីគ្រូ មកចូលត្រចៀកសិស្ស គឺពិតជាគ្មានប្រយោជន៍ គឺជាពេលវេលាដែលបាត់បង់ ។ ក្នុងករណីនេះគ្រូបាត់កំលាំង ឯសិស្សស្ទើរលក់ ស្ទើរភ្ញាក់ ។ តាមពិតសិស្សត្រូវតែសកម្ម និងត្រូវតែធ្វើការងារទាំងអស់ ពោលគឺសិស្សជាអ្នកធ្វើការ ខំប្រឹង គ្រូបង្រៀនមិនត្រូវធ្វើជំនួសសិស្សទាល់តែសោះ » ។ « Toute correction qui laisse l'enfant passif, qui tombe du haut de la chaise dans l'oreille est pratiquement inutile; c'est du temps perdu. Le maître s'y exténue et les élèves somnolent. Or les élèves deviennent actifs et font tout le travail. C'est l'élèlve qui doit travailler, faire l'effort. Le maître ne doit jamais se subtituer à lui »

តាមរយៈការសិក្សាខាងលើ យើងបានឃើញថា បើសិនជាគ្រូបង្រៀនយើងបង្រៀនមុខវិជ្ជានេះ តាមវិធីសាស្ត្រត្រឹមត្រូវដោយគោរពកម្មវិធី គោរពលំដាប់លំដោយនៃជំហានឈានឡើងរបស់ប្រធានតែងសេចក្ដីទៅបឋមសិក្សា ជ្រើសរើសប្រធានសិក្សា ប្រធានធ្វើគំរោងតែងរួម និងធ្វើកំណែបានត្រឹមត្រូវ ដោយយកចិត្តទុកដាក់ទៅលើប្រការទាំង ៧ ចំនុចដែលគ្រូបង្រៀនគួរចងចាំខាងលើនេះ ការបង្រៀនតែងសេចក្ដីទៅបឋមសិក្សាពិតជាសំរេចបានលទ្ធផលសមតាមប្រាថ្នា ទោះបីជាមុខវិជ្ជានេះពិបាកយ៉ាងណាក៏ដោយ ។ ដោយតែងសេចក្ដីជាបុប្ផានៃការបង្រៀន « La rédaction est la fleur de l'enseignement » កាលណាគេបានឃើញកិច្ចការរបស់សិស្សានុសិស្ស គេស្គាល់សមត្ថភាពគ្រូបង្រៀន និងស្គាល់មនសិការវិជ្ជាជីវៈរបស់គ្រូបង្រៀន ។ បឋមសិក្សាសាធារណៈតាមរយៈមុខវិជ្ជាតែងសេចក្ដីនេះ គឺជាថ្នាលសំរាប់បណ្ដុះបណ្ដាលអនាគតកវី អ្នកនិពន្ធ វាគ្មិន អ្នកនយោបាយ អ្នកច្បាប់ ទស្សនវិទូ . . . ជូនមាតុភូមិ ព្រោះថា : គ្រូបង្រៀនជាសិល្បករ ឆ្លាក់អនាគតប្រទេស « L'instituteur est l'artisan de l'avenir du pays » ។

ដោយលោក **ឃ៉ឹម សុត**

# ការទទួលខុសត្រូវរបស់គ្រូទទួលបន្ទុកថ្នាក់បង្រៀន
## Les responsabilités du chargé de cours

ក្នុងការបង្ហាត់បង្រៀនសិស្សនៅក្នុងថ្នាក់ គ្រូបង្រៀន និង សាស្ត្រាចារ្យត្រូវទទួលខុសត្រូវ ដូចខាងក្រោមនេះ ៖

### I. ការទទួលខុសត្រូវស្មារតី រឺ សីលធម៌ la responsabilité spirituelle ou moral

គ្រូបង្រៀន និង សាស្ត្រាចារ្យជាមន្ត្រីរាជការ ត្រូវបានរដ្ឋ និងប្រជារាស្ត្រទទួលស្គាល់ ហើយប្រគល់ភារកិច្ចអោយបំពេញការងារបំរើប្រទេសជាតិ មាតុភូមិលើវិស័យអប់រំ ។ គេជាវិស្វករព្រលឹង « Ingénieur de l'âme » និងជាជាងច្នៃអនាគតនៃប្រជាជាតិ l'artisan de l'avenir de la nation ។ វិស័យអប់រំ ជាកត្តាកំនត់ការរីវត្តរីកចំរើន និងសន្ទុះអភិវឌ្ឍន៍របស់សង្គមជាតិ ។ គ្រូបង្រៀន និង សាស្ត្រាចារ្យមានភារកិច្ចទទួលខុសត្រូវក្នុងការកសាងធនធានមនុស្ស ដែលជាអ្នកកំនត់ជោគវាសនា និងអនាគតនៃប្រទេសជាតិ ។ គ្រប់គ្រួសារទាំងអស់គេបានបញ្ជូនកូនចៅដែលជាទីស្រឡាញ់ស្មើជីវិតរបស់គេ អោយមកទទួលការអប់រំពីគ្រូបង្រៀន និងសាស្ត្រាចារ្យដែលជាអ្នកជំនាញលើវិស័យនេះ ។ គ្រូបង្រៀនសាស្ត្រាចារ្យ មានភារកិច្ចទទួលខុសត្រូវលើការអប់រំ បង្ហាត់បង្រៀន បំពាក់បំប៉ន បណ្តុះបណ្តាលកូនចៅប្រជាជន អោយបានក្លាយទៅជាកូនល្អ មានចំនេះដឹង និងសីលធម៌ល្អ សមតាមទំនុកចិត្តរបស់ឪពុកម្តាយ និងអាណាព្យាបាល ។ គេតែងចាត់ទុកគ្រូបង្រៀន និងសាស្ត្រាចារ្យជាជនគំរូ ។ គេទុកចិត្តផ្ញើជោគវាសនាអនាគតរបស់កូនគេលើគ្រូ និងសាស្ត្រាចារ្យ ។ គេតែងយល់ថា គេបានទទួលចំនេះដឹងដោយសារគ្រូបង្រៀន និងសាស្ត្រាចារ្យនេះឯង ។

ដូចនេះ គ្រូបង្រៀន និងសាស្ត្រាចារ្យត្រូវមានស្មារតីទទួលខុសត្រូវយ៉ាងធំធេងណាស់ នៅចំពោះមុខរដ្ឋ និងប្រជាជាតិ ចំពោះមុខសង្គម ចំពោះមុខគ្រួសារសិស្ស និងចំពោះមុខសិស្សានុសិស្សដែលមានទំនុកកចិត្តមកលើខ្លួន ។ ការខកខានក្នុងការងារ ការធ្វេសប្រហែសក្នុងការកសាងបុគ្គលិកលក្ខណៈរបស់សិស្ស ការខ្ជីខ្ជាក្នុងការងាររបស់គ្រូបង្រៀន និងសាស្ត្រាចារ្យ គឺជាការខាតបង់របស់ប្រទេសជាតិ និងរបស់សង្គម ហើយក៏ជាការខកចិត្ត និងជាការខាតបង់របស់គ្រប់គ្រួសារសិស្ស និងរបស់សិស្សានុសិស្សទាំងអស់ ។ ដូចនេះ ការងាររបស់គ្រូបង្រៀន និងសាស្ត្រាចារ្យ សុទ្ធតែមានតំលៃសំរាប់សិស្សដែលពុំអាចកាត់ថ្លៃបាន ។ ឆ្លើយតបទៅនឹងទំនុកចិត្តរបស់ប្រជាជាតិ សង្គម គ្រួសារ និង សិស្សានុសិស្ស គ្រូបង្រៀន សាស្ត្រាចារ្យ ត្រូវមានវត្តមានទៀងទាត់ គោរពម៉ោងធ្វើការ គោរពកាលវិភាគ និងអនុវត្តតាមកម្មវិធីសិក្សាអោយបានត្រឹមត្រូវល្អ ដើម្បីរួមចំណែកអភិវឌ្ឍប្រទេសជាតិអោយបានឆាប់រហ័ស ។

### II. ការទទួលខុសត្រូវរដ្ឋបាល << La responsabilité administrative >>

ជាអ្នកគ្រប់គ្រងថ្នាក់ទាំងមូល គ្រូបង្រៀន និងសាស្ត្រាចារ្យ មានភារកិច្ចទទួលខុសត្រូវគ្រប់គ្រងសំភារៈ ឯកសារសៀវភៅសិក្សា និងបញ្ជីផ្សេងៗ គ្រប់គ្រងវិន័យ សណ្តាប់ធ្នាប់ អនាម័យ សោភ័ណភាពថ្នាក់ និងរក្សាសុវត្ថិភាពគ្រប់សកម្មភាពសិក្សាទាំងនៅក្នុងថ្នាក់ និងទាំងនៅក្រៅថ្នាក់ ។

សំភារៈសិក្សាទាំងអស់ជាជំនួយដល់ការសិក្សា ។ ឯវិន័យជាកត្តាកំនត់នាំមកនូវជោគជ័យនៃការសិក្សា ។ ដូចនេះ គ្រូបង្រៀន និង សាស្ត្រាចារ្យ ត្រូវទទួលខុសត្រូវដឹកនាំសិស្សានុសិស្ស អោយចូលរួមកសាងសំភារៈឧបទេស ជួយថែរក្សាសាលារៀន ថ្នាក់ និងសំភារៈសិក្សាអោយនៅគង់វង្ស និងប្រើប្រាស់បានល្អ ។ តាមសកម្មភាពវិន័យសណ្តាប់ធ្នាប់ល្អតែងនាំមកនូវសុខសុវត្ថិភាព និងលទ្ធផលរៀនសូត្រល្អប្រសើររបស់សិស្ស ។ ដូចនេះ គ្រូត្រូវថែរក្សាវិន័យក្នុងថ្នាក់អោយបានល្អប្រសើរ និងបំផុសដល់ចលនាស្វ័យគ្រប់គ្រងក្នុងជួរសិស្ស ។

### III. ការទទួលខុសត្រូវបច្ចេកទេសគរុកោសល្យ << La responsabilité technique et pédagogique >>

គ្រូបង្រៀន និងសាស្ត្រាចារ្យជាមន្ត្រីបច្ចេកទេស ជាមន្ត្រីជំនាញដែលបានឆ្លងកាត់ការបណ្តុះបណ្តាលដែលទទួលបំពាក់បំប៉នលើការងារបច្ចេកទេស ចិត្តសាស្ត្រគរុកោសល្យ និងរដ្ឋបាលសិក្សា ។ អ្នកដែលពុំបានទទួលការបណ្តុះបណ្តាលពុំអាចបង្រៀនបានល្អឡើយ ទោះបីបង្រៀនបាន ក៏ពុំអាចធានាបាននូវគុណភាពអប់រំឡើយ ។ គ្រូបង្រៀន និងសាស្ត្រាចារ្យត្រូវខិតខំសិក្សាស្រាវជ្រាវ រៀនហើយ រៀនទៀត និងស្វ័យសិក្សាអោយបានយល់ច្បាស់ និងស៊ីជំរៅ នូវទ្រឹស្តីចិត្តគរុកោសល្យ ចេះអនុវត្តវិធីសាស្ត្របង្រៀនជឿនលឿន និងចេះប្រើប្រាស់ល្បិចបង្រៀនសមស្រប សំដៅអោយសិស្សចង់រៀន ចូលចិត្តរៀន ចេះវិធីសាស្ត្ររៀន និងសប្បាយរីករាយចូលរួមសកម្មភាពសិក្សា ។

ជាការខ្មាស់អៀនមួយ ដែលមន្ត្រីអប់រំនិយាយពីទ្រឹស្តីចិត្តគរុកោសល្យមានកំរិតទាបជាងជនដែលមិនដែលបានឆ្លងកាត់វគ្គសិក្សារៀនសូត្រនៅសាលាគរុកោសល្យ ។ ជាការគួរអោយសោកស្តាយបំផុត ដែលគ្រូបង្រៀន និងសាស្ត្រាចារ្យបង្រៀនខុសខ្លឹមសារមេរៀន រឺខុសគោលការណ៍ចិត្តគរុកោសល្យ ។ បើគ្រូពេទ្យម្នាក់អោយថ្នាំខុស គ្រោះថ្នាក់នឹងធ្លាក់លើអ្នកជំងឺម្នាក់ តែបើគ្រូ រឺសាស្ត្រាចារ្យបង្រៀនខុស នោះវាអាចធ្វើអោយសិស្សក្នុងថ្នាក់ទាំងអស់ខុសតាម ហើយវានឹងអាចអោយសិស្សជំនាន់ក្រោយៗ ខុសតៗ គ្នាទៀត ។

គ្រូបង្រៀន និងសាស្ត្រាចារ្យដែលមានភារកិច្ចបង្ហាត់បង្រៀនសិស្ស ចាំបាច់ត្រូវតែមានការរៀបចំម៉ត់ចត់បំផុត គឺត្រូវមានការរៀបចំសំភារៈ « préparation matérielle » រៀបចំកិច្ចតែងការបង្រៀនក្នុងខួរក្បាល « préparation mentale » រួចឈានទៅសរសេរកិច្ចតែងការបង្រៀន « préparation écrite » ។ គ្រូ និងសាស្ត្រាចារ្យត្រូវចងចាំនិងក្តាប់ខ្លឹមសារមេរៀនដែលបានរៀបចំ ហើយបង្រៀនទៅតាមខ្លឹមសារនោះ ។ បើអ្នកចំរៀង ច្រៀងកាន់ក្រដាស រឺគ្រូបើគ្រូបង្រៀន និងសាស្ត្រាចារ្យបង្រៀនកាន់សៀវភៅអានហើយពន្យល់ នោះអ្នកស្តាប់ និងអ្នកសិក្សាប្រាកដជាពុំអោយតំលៃខ្ពស់ឡើយ ។ ជានិច្ចកាល គ្រូបង្រៀន សាស្ត្រាចារ្យ ត្រូវយកចិត្តទុកដាក់ក្នុងការប្រជុំបច្ចេកទេសផ្លាស់ប្តូរបទពិសោធន៍គ្នាមានទំនាក់ទំនងជិតស្និទ្ធជាមួយគ្រួសារសិស្ស និងសិស្សានុសិស្ស ដើម្បីស្វែងយល់ និងស្គាល់ច្បាស់បុគ្គលិកលក្ខណៈរបស់សិស្ស សំដៅរៀបចំការបង្រៀនអោយកាន់តែមានលក្ខណៈសមស្រប និងមានប្រសិទ្ធភាពខ្ពស់ តាមច្បាប់គរុកោសល្យ ។ ធ្វើយ៉ាងនេះ គ្រូបង្រៀន និងសាស្ត្រាចារ្យ នឹងក្លាយទៅជាគ្រូបង្រៀន និងសាស្ត្រាចារ្យជាទីគោរព និងជាទីស្រលាញ់របស់សិស្សានុសិស្ស និងរបស់ប្រជាពលរដ្ឋទូទៅ ។ លទ្ធផលនៃការងាររបស់គ្រូបង្រៀន សាស្ត្រាចារ្យទាំងអស់ ពិតជាត្រូវបានចារឹកទុកក្នុងខួរក្បាល ដួងចិត្តនៃសង្គមមនុស្សមិនខានឡើយ ។ នេះហើយជារង្វាន់ធំបំផុតនៃជីវិតគ្រូបង្រៀនសាស្ត្រាចារ្យយើង ។

### IV. ការទទួលខុសត្រូវរដ្ឋប្បវេណី << La responsabilité eivrile >>

ក្នុងពេលម៉ោងការងារ គ្រូបង្រៀន និងសាស្ត្រាចារ្យមានភារកិច្ចរួមជាមួយសិស្សានុសិស្ស ទទួលខុសត្រូវចេញសោហ៊ុយជួសជុល រឺចេញថ្លៃសងដល់ការខូចខាតទ្រព្យសម្បត្តិសាធារណៈ រឺឯកជន រឺចេញសោហ៊ុយព្យាបាល ក្នុងករណីមានការធ្វេសប្រហែសរបស់គ្រូ និងសាស្ត្រាចារ្យ រឺបង្កឡើងដោយសិស្ស ។

### V. ការទទួលខុសត្រូវព្រហ្មទណ្ឌ << La responsabilité pénale >>

បណ្តាគ្រោះថ្នាក់ រឺបទល្មើសព្រហ្មទ័ណ្ឌដែលកើតឡើងដោយការធ្វេសប្រហែសរបស់គ្រូ និងសាស្ត្រាចារ្យក្នុងម៉ោងការងារ នោះគ្រូបង្រៀន និងសាស្ត្រាចារ្យត្រូវទទួលទោសតាមច្បាប់ ។ ប្រការនេះ បានទាមទារអោយគ្រូបង្រៀននិងសាស្ត្រាចារ្យយើង មានការប្រុងប្រយ័ត្នកំរិតខ្ពស់ក្នុងម៉ោងការងារ គឺមិនធ្វើអោយរាងកាយសិស្សរបួស រឺពិការ ត្រូវការពារកុំអោយសិស្សមានគ្រោះថ្នាក់ រឺស្លាប់ក្នុងថ្នាក់ រឺពេលចេញលេង ។ គ្រូត្រូវស្រង់វត្តមានត្រឹមត្រូវច្បាស់លាស់ ចៀសវាង

ផលវិបាកអាក្រក់ ដែលសិស្សអវត្តមាន មានគ្រោះថ្នាក់ស្លាប់ រឺទៅប្រព្រឹត្តបទល្មើសក្រៅសាលា តែក្នុងបញ្ជីពុំបានចុះអវត្តមាន បើគ្រូបង្រៀន រឺ សាស្ត្រាចារ្យខ្វះការប្រុងប្រយ័ត្ន គ្រោះថ្នាក់នឹងធ្លាក់មកលើគ្រូបង្រៀន សាស្ត្រាចារ្យ ដែលគួរអោយសោកស្ដាយ ។

សរុបមកឃើញថា លោកគ្រូ សាស្ត្រាចារ្យយើង មានការទទួលខុសត្រូវដ៏ធ្ងន់ធ្ងរនៅក្នុងម៉ោងបង្រៀន ដែលតំរូវអោយសាស្ត្រាចារ្យ គ្រូបង្រៀនម្នាក់ៗ យកចិត្តទុកដាក់នៅគ្រប់ជង្ហើមចេញចូល ។ តែការទទួលខុសត្រូវនេះ ក៏អាចចាត់ទុកថា ជាកិត្តិយសផងដែរ ក្នុងការបំពេញមុខវិជ្ជាជីវៈ ក៏ដូចជាការបណ្ដុះបណ្ដាលធនធានមនុស្ស សំរាប់អនាគតដ៏រុងរឿងរបស់ប្រទេសជាតិយើង ។

**តូ គីគុក**

អធិការបឋមសិក្សា និងជាអនុប្រធានមន្ទីរអ.យ.ក ខេត្ត កំពត

**ធ្វើអ្នករៀន ត្រូវខំរៀន អោយមោះមុត**
**រៀនដោយទ្រាំ ខំស្ដាប់គិត ដោយគោរព**
**រៀនទាល់ចេះ មិនទាន់ចេះ មិនទាន់ឈប់**
**រៀនទាល់ចប់ កុំឡិបឡប់ ឡេះឡោះឡើយ**

**ឡិម ណារី**

# យល់ដឹងពីជំងឺគ្រុនផ្តាសាយ

គ្រុនផ្តាសាយ ជាជំងឺមួយដែលបណ្តាលមកពីមេរោគប្រភេទវីរុសឈ្មោះ « **មីសូវ៉ារុសអាំងភ្លុយអង់សា** » ។ ជាទូទៅ ជំងឺនេះ បណ្តាលអោយក្តៅខ្លួន ហៀរសំបោរ ហៀរទឹកភ្នែក ក្អក កណ្តាស់ ឈឺបំពង់ក ជួនកាលវាធ្វើអោយឈឺក្បាលយ៉ាងខ្លាំង ឈឺឆ្អឹងឆ្អែង ចុកចាប់ពេញទាំងខ្លួន ។

គ្រុនផ្តាសាយពិតមែនតែពុំបណ្តាលអោយគ្រោះថ្នាក់ធ្ងន់ធ្ងរក៏ពិតមែន ប៉ុន្តែវាជាជំងឺមួយធ្វើអោយរំខាន តប់ប្រមល់យ៉ាងពិបាកទ្រាំដល់សរីរាង្គកាយ និងដល់ការងារប្រចាំថ្ងៃរបស់មនុស្សឈឺ ពិសេស វាជាជំងឺឆ្លងមួយ ដែលមានលក្ខណៈរាតត្បាតយ៉ាងឆាប់រហ័សក្រៃលែង ។ ក្នុងផ្ទះមួយបើមានអ្នកឈឺផ្តាសាយម្នាក់វានឹងរាលដាលពេញមួយផ្ទះ ។ ប៉ុន្តែពេលខ្លះវាជាជំងឺមួយធ្ងន់ធ្ងរណាស់ដែរ ប្រសិនបើឈឺប៉ះលើមនុស្សណាដែលខ្សោយ ហូបពុំគ្រប់គ្រាន់ មានជំងឺទឹកនោមផ្អែម រឺមានជំងឺរលាកច្រមុះ ។ ដោយសារប្រភេទវីរុសគ្រុនផ្តាសាយមានចំនួនច្រើន និងអាចផ្លាស់ប្តូរប្រែប្រួលរូបរាងជាបន្តបន្ទាប់ ទើបគេសង្កេតឃើញថា មនុស្សម្នាក់អាចទទួលជំងឺគ្រុនផ្តាសាយច្រើនដងបាន ។ ជំងឺគ្រុនផ្តាសាយនេះមានភាពរ៉ាំរ៉ៃ រឺបើមនុស្សម្នាក់កើតជំងឺគ្រុនផ្តាសាយច្រើនដងនោះ វាបណ្តាលអោយក្លាយទៅជាជំងឺរលាកទងសួតថែមទៀត ។

## I. ដើម្បីទប់ទល់នឹងជំងឺនេះ ចាំបាច់អ្នកជំងឺត្រូវអនុវត្តតាមវិធានការមួយចំនួនដូចខាងក្រោម ៖

១. អាស្ពីរីនគ្រាប់ ជាឱសថមានប្រសិទ្ធភាពល្អជាងគេទាំងអស់ សំរាប់ព្យាបាលជំងឺនេះ ។ បើអ្នកឈឺមានជំងឺរលាកក្រពះ គេអាចប្រើអាសេតាមីណូហ្វែន រឺប៉ារ៉ាសេតាម៉ុល ជាជំនួសអាស្ពីរីន តែគេមិនត្រូវប្រើប៉េនីស៊ីលីន តេត្រាស៊ីគ្លីន រឺអង់ទីប៊ីយ៉ូទិកដទៃទៀតទេ ព្រោះវាមិនអាចជួយអោយអ្នកឈឺបានធូរស្រាលអ្វីឡើយ ផ្ទុយទៅវិញ វាអាចនឹងបណ្តាលអោយមានគ្រោះថ្នាក់ថែមទៀត ។

២. ត្រូវទទួលទានទឹកក្តៅឧណ្ហៗ រឺទឹកតែឧណ្ហៗ អោយបានច្រើន ។ ដាច់ខាតគេមិនត្រូវអនុញ្ញាតអោយអ្នកជំងឺហូបទឹកកក រឺការ៉េមឡើយ ។

៣. ហូបបបរក្តៅឧណ្ហៗ ជាមួយសាច់ត្រី រឺសាច់ជ្រូក រឺសាច់គោដែលផុយ ហូបប៉េងប៉ោះ និង ផ្លែឈើដទៃទៀតដែលសំបូរជីវជាតិ « **សេ** » ដូចជាក្រូចពោធិសាត់ ទឹកក្រូចឆ្មារលាយស្ករស និង អំបិលជាជំនួយដ៏ ល្អប្រសើរបំផុត ។ មិនត្រូវហូបនំបញ្ចុកសម្លការី រឺគ្រឿងហឹរឡើយ ។

៤. ត្រូវសំរាកអោយបានគ្រប់គ្រាន់ ចៀសវាងការធ្វើការច្រើនពេក រឺប្រកបកិច្ចការធ្ងន់ៗ នៅហាលវាល ហាលខ្យល់ ហាលសន្សើម ហាលភ្លៀង រឺហាលថ្ងៃ ។ ចៀសវាងមុជទឹក និងលុបលាងមុខច្រើនពេក ហើយបើមុជទឹក គឺមុជទឹកក្តៅឧណ្ហៗ ចៀសវាងនៅក្នុងបន្ទប់ម៉ាស៊ីនត្រជាក់ ។

## II. វិធីការពារក្នុងករណីតឹងច្រមុះ និងហៀរសំបោរ

សំបោរនៅក្នុងច្រមុះ អាចបណ្តាលអោយឈឺត្រចៀកចំពោះកូនក្មេង រឺរលាកឆ្អឹងក្តោងច្រមុះចំពោះមនុស្សចាស់ ។ ដើម្បីអោយបាត់តឹងច្រមុះ គប្បីអនុវត្តដូចតទៅនេះ ៖

១. ចំពោះកូនក្មេងតូច គេអាចបឺតសំបោរនឹងមាត់ដោយទ្រាប់នឹងស្បៃ រឺយកសឺរ៉ាំងដែលគ្មានម្ជុលបូមយកសំបោរចេញ ។

២. ចំពោះក្មេងជំទង់ រឺមនុស្សចាស់ គេបន្តក់ទឹកអំបិលបន្តិចអោយចូលទៅក្នុងច្រមុះ ធ្វើរបៀបនេះដើម្បីអោយសំបោររាវ ហើយអាចហៀរចេញមកក្រៅបាន « របៀបលាយ គឺលាយអំបិលមួយស្លាបព្រាកាហ្វេ និងទឹកឆ្អិនកន្លះលីត្រ » ។

៣. ឆ្អុងទឹកក្ដៅទទេ រឺដាក់ស្លឹកជីរ រឺស្លឹកប្រេងខ្យល់ជាមួយ ដោយវិធីស្រូបយកចំហាយចំនួន ១៥នាទី ដើម្បីអោយច្រមុះធូរស្រួលដកដង្ហើម ។ ការហាត់ប្រាណជាជំនួយមួយសក្តិសិទ្ធិបំផុត ក្នុងការបំបាត់ភាពតឹងច្រមុះ ។

៤. ត្រូវជូតសំបោរតាមធម្មតា ចៀសវាងការញើសសំបោរខ្លាំងពេក ព្រោះការញើសសំបោរខ្លាំងពេក អាចនាំអោយឈឺត្រចៀក រឺក៏រលាកទន្ទច្រមុះតែម្ដង ។

## III. វិធីការពារកុំអោយជំងឺផ្ដាសាយឆ្លងទៅអ្នកដទៃទៀតបាន

ជំងឺផ្ដាសាយឆ្លងតាមរយៈខ្យល់ដកដង្ហើម ទឹកមាត់ ទឹកសំបោរ និងទឹកភ្នែក អ្នកជំងឺដែលនៅក្បែរខ្លួន ។ បរិយាកាសអាប់អួរ និងធាតុអាកាសផ្លាស់ប្ដូរនៃរដូវ ក៏ជាកត្តាមួយធំ បណ្ដាលអោយកើតជំងឺផ្ដាសាយផងដែរ ។

ដើម្បីកុំអោយមានការឆ្លងជំងឺនេះបាន គប្បីប្រកាន់ខ្ជាប់តាមក្បួនអនាម័យដូចខាងក្រោមនេះ ៖

### ១. ចំពោះអ្នកជំងឺ

- ត្រូវនៅដោយឡែកពីអ្នកជា និងនៅអោយឆ្ងាយពីកុមារ « ចៀសវាងពកុមារ »
- សំលៀកបំពាក់ កន្សែង មុង កន្ទេល ខ្នើយ ជាដើម មិនត្រូវប្រើឡូកឡំជាមួយនឹងអ្នកជាឡើយ ។
- ម្ហូបអាហារ ចាន ស្លាបព្រាជាដើម ត្រូវបរិភោគ និងប្រើប្រាស់តែម្នាក់ឯង ។
- ក្នុងពេលក្អក កណ្ដាស់ រឺញើសសំបោរ ត្រូវមានក្រូនកន្សែងខ្ទប់មាត់ ច្រមុះជានិច្ច ។
- ក្នុងករណីមានកើតជំងឺផ្ដាសាយធ្ងន់ធ្ងរ ត្រូវអញ្ជើញទៅមន្ទីរពេទ្យ ចៀសវាងការលេបថ្នាំផ្ដេសផ្ដាស ដោយស្មានៗ ។

### ២. ចំពោះអ្នកជា

- មិនត្រូវអង្គុយទល់មុខ រឺនិយាយជិតអ្នកមានជំងឺផ្ដាសាយឡើយ ។
- មិនត្រូវរួមបរិភោគជាមួយអ្នកជំងឺ រឺបរិភោគសល់ពីអ្នកជំងឺ ។
- មិនត្រូវយករបស់អ្នកឈឺមកប្រើឡើយ ។
- ត្រូវចៀសវាងបរិយាកាសអាប់អួរ ស្មោគគ្រោក រឺទីប្រជុំជនកុះករ ដែលខ្វះលក្ខណៈអនាម័យ ។
- ចៀសវាងលែងខ្លួនទទេ នៅហាលវាល ចៀសវាងនៅហាលក្ដៅ ក្រោមសន្សើម រឺភ្លៀងព្រិលក្នុងលក្ខណៈដែលខ្លួនមានភាពទន់ខ្សោយខាងកំលាំងកាយ ។ បើភ្លៀងទទឹកជោក ត្រូវប្រញាប់ផ្លាស់សំលៀកបំពាក់ រឺរុំដណ្ដប់ខ្លួនអោយជិត ដើម្បីអោយមានចំហាយក្ដៅក្នុងខ្លួនឡើងវិញ ។ បើអាចធ្វើបានពិសាទឹកក្ដៅមួយពែងផង ។
- ចៀសវាងការរួមដំណេកជាមួយគ្រួសារខ្លួនដែលឈឺផ្ដាសាយ ព្រោះវានាំអោយឆ្លងមេរោគផ្ដាសាយ និងនាំអោយគ្រួសារបាត់កំលាំងគ្រជាផង ។

ស្រាវជ្រាវដោយ : **អង្គការអតិថឡាន់កម្ពុជា**
តាមឯកសារអប់រំសុខភាពបោះផ្សាយឆ្នាំ ១៩៩១

# វិញ្ញាសាប្រលងអធិការបឋមសិក្សាលើកទី ៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មហាវិទ្យាល័យគរុកោសល្យ

## ប្រលងជ្រើសរើសនិស្សិតអធិការបឋមសិក្សាជំនាន់ទី ៤

| | | |
|---|---|---|
| សម័យប្រលង | : | ថ្ងៃទី ០៩ - ១០ - ៩៧ |
| មណ្ឌលប្រលង | : | មហាវិទ្យាល័យគរុកោសល្យ |
| វិញ្ញាសា | : | សិក្សាអត្ថបទ |
| រយៈពេល | : | ៣ ម៉ោង មេគុណ ៤ |

I. « . . . ដើម្បីឆ្លើយតបទៅនឹងតំរូវការបច្ចុប្បន្ននៃសង្គម - សេដ្ឋកិច្ច របស់ប្រទេសជាតិ និងដើម្បីអោយសមស្រប ទៅនឹងបរិបទសព្វថ្ងៃពិភពលោក ដែលកំពុងមានការរីកចំរើនខ្លាំង ខាងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានោះ ក្រសួងអប់រំ យុវជន និង កីឡា បានដាក់ចេញនូវសំនូមពរ និងវិធានការជាច្រើនសំរាប់លើកកំពស់គុណភាពអប់រំលើគ្រប់ផ្នែកក្នុង ទូទាំងប្រទេស . . . » ។

១. ដើម្បីសំរេចសំនូមពរ និងវិធានការ ដូចបានលើកឡើងក្នុងសំរង់អត្ថបទខាងលើ តើអ្នកយល់ថា គប្បីធ្វើអ្វីខ្លះ ជាសកម្មភាពអាទិភាព សំរាប់លើកកំពស់គុណភាពបង្រៀន និងរៀននៅបឋមសិក្សា ? ( ៣ ពិន្ទុ )

២. គោលដៅអប់រំជាតិ គឺបណ្ដុះបណ្ដាលជំនាន់យុវវ័យអោយទៅជាកូនល្អ សិស្សល្អ មិត្តល្អ និងពលរដ្ឋល្អ សំរាប់អនាគតនៃប្រទេសជាតិ ។

ចង់បានដូច្នេះ តើគ្រូបង្រៀនត្រូវអភិវឌ្ឍសិស្សអំពីចំនុចអ្វីខ្លះ ? ហើយតើត្រូវយកគោលវិធីអ្វីមកអនុវត្ត ? ( ៣ ពិន្ទុ )

ចូរពន្យល់បកស្រាយដោយលើកឧទាហរណ៍ ជាក់ស្ដែងក្នុងការបង្រៀនមុខវិជ្ជាណាមួយ នៅបឋមសិក្សាមកបញ្ជាក់ ។ ( ២ ពិន្ទុ )

II. គេអោយអត្ថបទរៀនអានថ្នាក់ទី ៤ ទំព័រ ១០៧ អំពីព្រៃកម្ពុជា :

« ប្រទេសកម្ពុជាសំបូរទៅដោយព្រៃដែលមានដើមឈើធំៗ ច្រើនឥតគណនា ។ នៅក្នុងភូមិចំការរុក្ខជាតិច្រើនយ៉ាង ផ្តល់ផ្លែជាចំនីអាហារដ៏មានឱជារស » ។

តាមតំបន់ព្រៃភ្នំក្រំថ្ម និងតាមខេត្តដាច់ស្រយាលមានដើមឈើចំរុះ ដូចជា បេង នាងនួន ពក ផ្ចឹក ក្រញូង សុក្រំ ជាដើម ។ គេយកឈើទាំងនោះធ្វើសំភារៈប្រើប្រាស់ និងជាគ្រឿងសំទង់លំនៅដ្ឋាន អាគាររដ្ឋ សាលារៀន ស្ពាន ។ល ។ ជុំវិញប្រាសាទបុរាណ ព្រៃឈើជារបាំងរាំងទប់ខ្យល់ការពារមិនអោយថ្មសឹក រេចរឹលរលំបាក់បែកបាន ។ម្យ៉ាងទៀត ព្រៃឈើជួយអោយប្រាសាទកេរ្តិ៍មរតក ពីបុរាណកាលរបស់យើងមានសោភ័ណភាពយ៉ាងស្រស់ប្រណិត ។

នៅរដូវទឹកឡើង ព្រៃរបោះជុំវិញទន្លេសាប ជាជំរកយ៉ាងកក់ក្តៅសំរាប់ត្រីពង និង ជារបាំងទប់ល្បប់កុំអោយហូរច្រោះទៅក្នុងទន្លេ ។

ព្រៃឈើជាសម្បត្តិរួមមានប្រយោជន៍យ៉ាងសំខាន់ ។ យើងត្រូវជួយថែរក្សាព្រៃឈើអោយបានគង់វង្ស ដូចពាក្យស្លោក : « ថែរក្សាសម្បត្តិរដ្ឋ គឺ ស្នេហាជាតិ » ។

ក. ចូរបង្ហាញអំពីគោលបំណងនៃអត្ថបទរៀនអានខាងលើនេះ ។ ( ៣ ពិន្ទុ )

ខ. ដើម្បីវាយតំលៃថា តើសិស្សបានសំរេចគោលបំណងនៃអត្ថបទខាងលើដែរ រឺទេនោះ តើអ្នកត្រូវធ្វើដូចម្តេច? ចូរពន្យល់ដោយលើកឧទាហរណ៍ជាក់ស្តែងក្នុងអត្ថបទខាងលើមកបញ្ជាក់ ។ ( ៣ ពិន្ទុ )

III. គេអោយមេរៀនគណិតវិទ្យា ថ្នាក់ទី ៤ ទំព័រ ១៤៧ អំពី « សញ្ញាណប្រភាគ $\frac{1}{4}$ ; $\frac{1}{3}$ » ។ តើអ្នកត្រូវដឹកនាំការបង្រៀនមេរៀនសញ្ញាណប្រភាគខាងលើនេះដូចម្តេច ដើម្បីគោរពតាមគោលដៅអប់រំជាតិ និងតាមវិធីសិស្សមជ្ឈមណ្ឌល ? ចូរពន្យល់ដោយធ្វើកិច្ចតែងការបង្រៀនទៅជំហានទី ៣ និងទី ៤ ។ ( ៦ ពិន្ទុ )

**ROYAUME DU CAMBODGE**
**Nation Religion Roi**
ЖЖЖ Ж ЖЖЖ

Ministère de l'Education,
de la Jeunesse et des Sports
ЖЖЖ Ж ЖЖЖ
Faculté de Pédagogie
ЖЖЖ Ж ЖЖЖ

## Concours de recrutement des Inspecteurs Primaires
## Session d'Octobre 1997

Epreuve : Etude de texte

Durée : 3 heures << Coefficient par 4 >>

I. << . . . Pour répondre aux besoins socio-économiques du pays, et face au développement du contexte mondial de la science et de la technologie, le Ministère de l'Education, de la Jeunesse et des Sports a entrepris plusieurs mesures destinées à renforcer la qualité de l'éducation dans l'ensemble du pays . . . >>

1. Pour parvenir à réaliser ces exigences ainsi ci-citées, à votre avis, qu'est-ce qu'il faut faire comme actions prioritaires pour renforcer la qualité de l'enseignement et de l'apprentissage à l'école primaire ?

2. L'objectif de l'éducation est de former chez la génération montante, un bon enfant, un bon élève, un bon ami et un bon citoyen pour l'avenir du pays.

Ce faisant, qu'est-ce que l'instituteur doit développer chez l'enfant ? Et quelles méthodes doit-il entreprendre ?

Expliquez à l'aide des exemples concrets à partir d'une discipline enseignée au niveau primaire.

II. A partir du texte de lecture ci-dessous << Manuel de 4$^{ème}$ page 107 >> : La forêt Cambogienne.

<< Le Cambodge a d'immenses forêts qui ont de hauts et grands troncs.

Des grands champs d'arbres fruitiers couvrent les villages . Leurs fruits sont excellents. Les différents types de bois comme Béng , Neang Nuon , Pok , Phchœuk , Kragnoung , Sokram poussent dans la région montagneuse et dans des provinces éloignées . Ces arbres sont utilisés pour fabriquer des meubles, la construction des maisons, des bâtiments, des écoles, des ponts etc . . .

Autour des monuments, la forêt protège les pierres contre le vent d'une part, et d'autre part, elle les décore et les rend magnifiques.

A la saison des pluies, la forêt inondée autour du Tonlé Sap est très favorable à la reproduction des poissons et sert de très grande barrière de boue.

La forêt est une richesse nationnale très importante. Nous devons la protéger éternellement, ainsi que le slogan a dit << Protéger la richesse de son état, c'est aimer sa patrie.

1. Montrez l'objectif d'enseignement de ce texte de lecture.
2. Comment savez-vous que les élèves comprennent ce texte ? Expliquez avec des exemples concrets.

III. On vous demande de faire une leçon de mathématiques au niveau 4 :

Les fractions 1/4 ; 1/3 << manuel de 4$^{ème}$ page 147 >>

1. Comment menez-vous une séquence d'enseignement de cette leçon pour répondre aux objectifs de l'éducation et pour mettre en application les méthodes actives << Child centered >> ?
2. Expliquez à l'aide d'une préparation de classe au 3$^{ème}$ pas et au 4$^{ème}$ pas d'enseignement

---

## វិញ្ញាសាវប្បធម៌ទូទៅ ( រយៈពេល ១២០នាទី )

១. ចូរអ្នកបង្ហាញពីតារាងមែកធាងនៃអរិយធម៌ ។ ( ២ពិន្ទុ )

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

២. ហេតុអ្វីបានជាគេអោយអាទិភាពដល់ការលើកកំពស់គុណភាពអប់រំនៅបឋមសិក្សាមុនគេបង្អស់ ? ( ឆ្លើយបីបន្ទាត់ តែចំណុចសំខាន់ៗ ) ។ ( ២ពិន្ទុ )

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

៣. សុភាសិតមួយបានលើកឡើងថា : « ការបង្រៀនអោយគេចេះស្ទូចត្រីប្រសើរជាងអោយត្រីគេ » ។ ចូរពន្យល់អោយបានបួនបន្ទាត់ដោយផ្សារភ្ជាប់នឹងការងារអប់រំ ។ ( ២ពិន្ទុ )

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

៤. តើការសិក្សាអំពីចិត្តសាស្ត្រមានប្រយោជន៍អ្វីខ្លះដល់គ្រូបង្រៀននៅបឋមសិក្សា ? ចូរគូស [√] តែចំណុចដែលត្រូវ : ( ១ពិន្ទុ )

☐ ស្គាល់សិស្ស ស្គាល់កុមារ ងាយស្រួលក្នុងការរៀបចំសកម្មភាព

☐ ស្គាល់ឪពុកម្ដាយសិស្ស ងាយស្រួលក្នុងការទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន

☐ គ្រូពុំចាំបាច់ធ្វើសកម្មភាព សិស្សធ្វើសកម្មភាពដោយខ្លួនឯង

☐ គ្រូច្រកបញ្ចូលចំណេះដឹងដល់សិស្ស

៥. ក្នុងការកំណត់គោលបំណងមេរៀននៅបឋមសិក្សា តើអ្នកផ្អែកលើកត្តាអ្វីខ្លះ ? ចូរគូស [√] តែចំលើយណាដែលត្រូវ ។ ( ១ពិន្ទុ )

☐ គំនិតអត្តនោម័តរបស់គ្រូ

☐ គំនិតផ្ទាល់ខ្លួនរបស់សិស្ស

☐ សំណូមពររបស់សង្គម

☐ គោលដៅនៃការអប់រំ

☐ ខ្លឹមសារមេរៀន

☐ បំណងរបស់ឪពុកម្ដាយសិស្ស

☐ អាយុ និងកំរិតយល់ដឹងរបស់សិស្ស ☐ សំណូមពរនៃសេចក្តីត្រូវការរបស់សិស្ស

☐ គោលបំណងនៃការបណ្តុះបណ្តាល ☐ តំរូវការរបស់សេដ្ឋកិច្ចទីផ្សារសេរី

៦. វិធីសាស្ត្របង្រៀនបែបប្រពៃណី ខុសពីវិធីសាស្ត្របង្រៀនបែបទំនើប ស្ថិតនៅត្រង់វិធីសាស្ត្របុរាណ : (២ពិន្ទុ)

☐ សិស្សធ្វើសកម្មភាព ☐ គ្រូអោយសិស្សកត់តាម ចាំតាម និងយល់តាម

☐ យកសិស្សជាមជ្ឈមណ្ឌល ☐ គ្រូធ្វើសកម្មភាពតិច សិស្សធ្វើសកម្មភាពច្រើន

☐ គ្រូធ្វើសកម្មភាពម្នាក់ឯង ☐ អោយសិស្សសង្កេត ពិនិត្យបញ្ចេញយោបល់ ពិភាក្សា

☐ គ្រូពន្យល់ផង និងអោយសិស្សកត់តាមផង ☐ គ្រូរិះរកមធ្យោបាយ ដើម្បីអោយសិស្សធ្វើសកម្មភាព

៧. ក្នុងការបង្ហាត់បង្រៀនក្នុងថ្នាក់ បើមិនយកសិស្សជាមជ្ឈមណ្ឌល តើបាន រឺមិនបាន ? បើបានព្រោះអ្វី ? បើមិនបានព្រោះអ្វី ? ចូរគូស ☑ តែចំលើយដែលត្រូវស្របបតាមគំនិតរបស់អ្នក ។ ( ២ ពិន្ទុ )

ក. បាន ☐

ខ. មិនបាន ☐

ព្រោះ

☐ សិស្សជាជង្រុកអាចទទួលយកអ្វីៗ គ្រប់ពេលវេលា

☐ សិស្សត្រូវធ្វើសកម្មភាពរៀនសូត្រ

☐ សិស្សមិនអាចធ្វើសកម្មភាពដោយខ្លួនឯង

☐ ការបង្រៀនពុំមែនប្រៀបបាន ការផ្ទេរទឹកពីពាងធំទៅពាងតូចទេ

☐ សិស្សមានលទ្ធភាពអាចទទួលចំណេះដឹង តាមរយៈការផ្តល់អោយពីគ្រូ

៨. ហេតុអ្វីបានជាក្នុងម៉ោងបង្រៀន ចាំបាច់ត្រូវបែងចែកសិស្សជាក្រុមពិភាក្សា ? ( ឆ្លើយ ៣បន្ទាត់តែចំណុចសំខាន់ៗ ) ( ២ ពិន្ទុ )

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

៩. តើត្រូវបែងចែកក្រុមពិភាក្សារបៀបណា បើតុសិស្សវែង ហើយសិស្សមានចំនួនច្រើន ? ( ឆ្លើយ ២បន្ទាត់តែចំណុចសំខាន់ៗ ) ( ១ពិន្ទុ )

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

១០. ហេតុអ្វីបានជាគេដាក់រូបតំណាងប្រាសាទអង្គរវត្តក្នុងទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា ? ( ឆ្លើយ ៣បន្ទាត់តែចំណុចសំខាន់ៗ ) ( ១ពិន្ទុ )

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

១១. ក. ចូររកពាក្យពេញនៃពាក្យ **UNESCO** ហើយតើពាក្យនេះមានន័យដូចម្ដេច ? ( ១ពិន្ទុ )

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

ខ. ចូររកពាក្យពេញនៃពាក្យ **UNICEF** ហើយពាក្យនេះមានន័យដូចម្ដេច ? ( ១ពិន្ទុ )

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

១២. ហេតុអ្វីបានជាគេនិយាយថា គ្រប់គ្រងល្អ ទើបបង្រៀនបានល្អ និងរៀនបានល្អ ? ( ឆ្លើយ ៥បន្ទាត់តែចំណុចសំខាន់ៗ ) ( ២ពិន្ទុ )

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

---

**ចំលើយទី ១ :**

នាងខ្ញុំឈ្មោះ **ស្វាយ ធៀម** សាស្ត្រាចារ្យវិទ្យាល័យអនុវត្ត សូមឆ្លើយសំនួរទី ១ ក្នុងទស្សនាវដ្ដីគ្រូបង្រៀនលេខ ៦ ។

ចំពោះការបកស្រាយបំភ្លឺរបស់សាស្ត្រាចារ្យម្នាក់ (១៩៦៧) នៅអនុវិទ្យាល័យមួយ នៅខេត្តកំពត នាងខ្ញុំយល់ថា មិនទាន់ត្រឹមត្រូវទេ ព្រោះ ៖

ពាក្យ : **បញ្ញាសជាតក** មិនអានថា **បញ្ញា ស ជាតក** ទេ គឺអានថា : **បញ្ញាស ជាតក**

- **បញ្ញាសជាតក** = **បញ្ញាស** + **ជាតក**
- **បញ្ញាស** = **៥០**

- **ជាតក** = រឿងរ៉ាវពីជាតិមុនៗរបស់ព្រះពុទ្ធ
- **បញ្ញាសជាតក** = រឿងរ៉ាវពីជាតិមុនៗ ទាំង ៥០ របស់ព្រះពុទ្ធ

ក្នុងបញ្ញាសជាតកមានរឿង : ( ក្រុងសុភមិត្រ សព្វសិទ្ធិ ពុទ្ធិសែន វរវង្សសូរវង្ស ព្រះសុធន សុវណ្ណស័ង្ខ. . .) ។

ចំណែកឯរឿងមហោសថ មិនស្ថិតនៅក្នុងសញ្ញាសជាតកទេ គឺស្ថិតនៅក្នុងទសជាតក ហើយគឺជារឿងទី ៥ ក្នុងទសជាតក ( តេមិយ ជនក សុវណ្ណសាម នេមិរាជ មហោសថ ភូរិទត្ត ចន្ទកុមារ នារទ វិធុរបណ្ឌិត វេស្សន្តរ )

ចំពោះសំនួរទី ១នេះ លោក **ខៀវ ស៊ីន** នាយកសាលាបឋមសិក្សា ខ្នុរដំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម បានពន្យល់យ៉ាងក្បោះក្បាយដូចគ្នានឹងអ្នកគ្រូ **ស្វាយ ឡៀម** ដែរ ។

ដោយទស្សនាវដ្ដីមានទំព័រកំរិត ខ្ញុំមិនបានចុះផ្សាយលិខិតគាត់ឡើយ ។

## ទី ២ : អំពីប្រាសាទភ្នំជីសូរ :

**ក. សំនួរ :**

ប្រាសាទភ្នំជីសូរស្ថិតនៅឯណា ? ប្រាសាទនេះ ស្ដេចអង្គណាកសាង ? ប្រាសាទនេះជ្រុងមួយៗ មានប្រវែងប៉ុន្មានម៉ែត្រ ? នៅជញ្ជាំងខាងក្នុងគុហាធំ គេឃើញមានរូបអ្វីខ្លះ ? ប្រាសាទសំរាប់មហាក្សត្រក្រសាលស្ថិតនៅខាងណាប្រាសាទធំនោះ ?

ខ. ចំលើយ :

ប្រាសាទភ្នំជីសូរ ស្ថិតនៅស្រុកសំរោង ខេត្ត តាកែវ ។ ប្រាសាទនេះ កសាងលើភ្នំជីសូរ ដោយ **ព្រះបាទសុរិយាវរ្ម័នទី ១** ក្នុងគ.ស. ១០០២-១០៥៨ ។ សព្វថ្ងៃ ប្រាសាទបុរាណនេះ បាក់បែកទ្រុឌទ្រោមអស់ហើយ ។ តួប្រាសាទមានរាង ៤ជ្រុងស្មើ ហើយជ្រុងមួយៗ មានប្រវែង ៤០ម ។ នៅលើផ្ទាំងកំពែង គេឃើញមានរូបចំលាក់ជាភាពរបៀបពលលើកទ័ពទៅធ្វើសង្គ្រាម ។

ខាងក្នុងកំពែង មានគុហាមួយធំខ្ពស់ ដែលមានកំពូលរៀវស្រួច ជាក្បាច់មុខព្រហ្មញញឹមស្រស់ប៉ប្រិមទៅទិសទាំងបួន ។ នៅជញ្ជាំងខាងក្នុងគុហាធំ មានព្រះពុទ្ធរូបមួយអង្គចូលនិព្វាន ឆ្លាក់ជាប់នៅជញ្ជាំងដែលប្រកបដោយក្បាច់រចនា និង អក្សរចារឹកផ្សេងៗ ។

បន្ទាប់ពីប្រាសាទសិលាជាគេរដំណែលពីបុរាណមកនេះ មានផ្លូវដើរមួយ ទទឹងប្រហែល ២ម ត្រង់ដូចបន្ទាត់ សំដៅទៅទិសបូព៌ា រហូតដល់ប្រាសាទមួយយ៉ាងតូច ដែលមានថែវបែកទៅទិសទាំងបួន ។ ប្រាសាទនេះ ជាវេទិកាសំរាប់ព្រះមហាក្សត្រក្រសាល និងទតទូរទេសភាពទាំងឡាយ ។

ដោយ **យ៉ង់ ធី**



## សំនួរ

**ទី១ :**

១. **ព្រះបាទ អង្គឌួង** ឡើងសោយរាជ្យពីឆ្នាំណា ?

- ហើយសោយទិវង្គតនៅឆ្នាំណា ? នៅឯណា ?
- នៅពេលមុន កំពុង និង ក្រោយសោយរាជ្យ តើប្រទេសកម្ពុជាស្ថិតនៅក្នុងស្ថានភាពបែបណា ?
- ហេតុអ្វីបានជាព្រះអង្គចាត់អោយលើកផ្លូវពីឧដុង្គមានជ័យ ទៅខេត្តកំពត ?
- តើព្រះអង្គបានកសាងស្នាដៃអ្វីខ្លះទៀត ?

២. **ព្រះបាទ នរោត្តម** ឡើងសោយរាជ្យពីឆ្នាំណា ?

- ព្រះអង្គយាងចេញពីទីក្រុងឧដុង្គមានជ័យ មកគង់នៅទីក្រុងភ្នំពេញនៅឆ្នាំណា ?
- ព្រះបរមរាជវាំងសាងសង់រួចនៅឆ្នាំណា ?

---

**ទី២ :**

ចូរប្រៀបធៀបទំហំផែនទីប្រទេសកម្ពុជា ដែលមានមាត្រដ្ឋានខុសគ្នា

- ផែនទី ១ : មានមាត្រដ្ឋាន ១/៥០០.០០០
- ផែនទី ២ : មានមាត្រដ្ឋាន ១/២.០០០.០០០

តើផែនទីទី ១ មានទំហំធំ រឺតូចជាងផែនទី ទី ២ ។ ពីព្រោះអ្វី ?

កំណាព្យ ( បទពាក្យ ៧ )

# ធម្មជាតិខ្ញុំអើយ !

កម្ពុជាតូចពិតតែសំបូរ សម្បត្តិហៀរហូរពាសពេញដី
មានស្ទឹងទន្លេ និងសត្វព្រៃ ត្បូងរ៉ៃក្រោមដីព្រមធ្វា ។

សំរស់រីកស្រស់យ៉ាងប្រណីត ហ្វូងសត្វម្រឹគពាសពេញព្រឹក្សា
ធម្មជាតិរីកស្រស់យ៉ាងសង្ហារ ហ្វូងសត្វមច្ឆាគួរចាប់ចិត្ត ។

ដែនដីស្រុកយើងសំបូរបែប រីកស្រស់ត្រដែតយ៉ាងប្រណីត
សម្បត្តិធម្មជាតិដុះជុំជិត គួរអោយនៃបនិត្យល្អត្រចះ ។

បក្សាបក្សីពាសពេញព្រៃ សត្វស្រុកសត្វព្រៃមិរដេរដាស
សូមរាប់ត្រួសៗ ដំនឹងខ្លះ ក្នុងព្រៃច្រើនណាស់រាប់មិនអស់ ។

សំរែកសត្វទោចយំពេញព្រៃ សំរែកសត្វគីលាន់ស្រនោះ
ប្រើសខ្ទីងរមាំងក្ដាន់លោតផ្លោះ ចូលព្រៃរបោះលាន់ទ្រហឹង ។

ក្របីដំរីសត្វតូចធំ សំរែកខ្លាធំលឺត្រហឹម
សំរែកសត្វក្រាលលាន់ទ្រហឹង ត្រយ៉ងឆ្លើយភឹងមិនចុះចាញ់ ។

រនាល និងខ្វែកខំឆ្លើយឆ្លង រលកខំផ្សងយ៉ាងត្របាញ់
ពពូលពពាក់ផ្ទាក់ប្រមាញ់ សំរែកមិនចាញ់ និងសារិកា ។

ចាបស្រុកចាបព្រៃលាន់ខ្ទៀវខ្ទា កក្រើកបុព្វតាហ្វូងបក្សា
បក្សីហោះធ្មោរកមេបា ក្នុងចិត្តជ្រះថ្លាស្វែងរកធី ។

ក្អែកស្រុកក្អែកមៀមតាវ៉ៅ ទីទុយសំដៅចាប់ចំណី
ចិត្តសែនសប្បាយជាប្រក្រតី ហោះហើរប្រញីចំណីគ្នា ។

សេះគោក្របីក្ងានមាន់ទា យំឆ្លើយឆ្លងគ្នាគ្រប់វេលា
ទ្រហឹងអឹងអាប់ស្ដាប់មិនជា កើតឈ្លោះនឹងគ្នាព្រោះចំណី ។

ក្នុងទ្រុងសត្វជ្រូកលាន់រងូក សំរែកអ៊ូកៗ ទាររកធី
កន្ទក់ដើមចេកមិនស្រដី ជាប្រក្រតីទើបសមរម្យ ។

សូមចាប់ចុងជូនពីព្រឹក្សា អោយថែរក្សាដងព្រៃភ្នំ
សំបូរឈើច្រើនតូច និង ធំ កុំកាប់រំលំឥតប្រយោជន៍ ។

គតិរកកោះ និងឈើផ្ចិត មិនងាយឆាប់សឹកអត់ហិនហោច
រាល់ឆ្នាំកន្លងមិនដាច់ដោច កុំឥតប្រយោជន៍ថែរក្សា ។

ខ្លឹមច័ន្ទតំលៃដ៏អស្ចារ្យ ក្រវាញជ្រះថ្លាថ្នាំជូនតា
ដើមដូងផ្លែឆ្ងាញ់ផ្អែមអស្ចារ្យ ដើមត្នោតផងណារាប់មិនអស់ ។

ទនោងបើងបោះខ្លឹមឆៃថាវ គ្រឡាច និងត្រាវជាតិមិនខ្សោះ
ដំឡូង និងល្ពៅដាំបានសោះ កុំទុកចន្លោះអោយសល់ដី ។

សេមាន់ម៉ាក់ប្រេង និងម៉ាក់ប្រាង ផ្អែមជូរសំរាំងកុំថាអី
អំពិលក្រសាំងទុំ និង ខ្វី សុទ្ធតែត្រូវឆីបានទាំងអស់ ។

ផ្លែម្កាក់កន្ទួតមានជូរអែម ខ្លះចត់ខ្លះផ្អែមមានចោះៗ
សុទ្ធមានប្រយោជន៍កុំចន្លោះ មុខផ្ទះមានសោះខំដាំផុះ ។

សូមរាប់បន្តផ្លែល្ហុងក្រូច ខ្នុលទៀបមិនខូចដាំចំរុះ
ជំពូចេកទុំដល់ដីផុះ ល្មុតមៀនចំរុះត្របែកស្វាយ ។

បើយើងឧស្សាហ៍មិនខ្វះចាយ ស្រុកយើងសប្បាយមានផល្លា
ធម្មជាតិស្រុកយើងរីកស្រស់ថ្លា បុព្វបាទចារទុកអោយធ្វើ ។

នាងនួនត្រាចធ្នង់សូមចំណាំ នេះជាបណ្ដាំអំពីឈើ
អ្នកភូមិអ្នកស្រុកខ្មែរស្រុកលើ កុំកាប់រុះរើត្រូវខំឆ្លៀត ។

កុំចោលម្សៀតគិតពីកាប់ ត្រូវមានសណ្ដាប់វែងចង្អៀត
ស្រឡៅដើមផ្គាវល្វិផ្សេងទៀត ល្វតលាស់ប្រជៀតគួរអោយស្រស់ ។

សូមចាប់អារម្មណ៍មកមច្ឆា ខំហែលឆ្វេឆ្វាប្រាថ្នាស្នេះ
ត្រីតូចត្រីធំមានមិនខ្សោះ មានច្រើនមិនអស់រាប់មិនចេញ ។

ត្រីខ្ចឹងកញ្ចុះ និងត្រីប្រា មានទាំងចង្វាររស់ជាតិឆ្ងាញ់
ត្រីឆ្លាំងត្រីឆ្ដូញ និងត្រីក្រាញ់ រស់ជាតិមិនចាញ់ត្រីអណ្ដែង ។

ត្រីឆ្ពិនត្រីក្រោះអណ្ដាតឆ្កែ មានជាហូរហែរពិតជាក់ស្ដែង
ត្រីកែសកំភ្លាញដូចមានថែង គួរអោយស្ញប់ស្ញែងកើ្ដទាំងឡាយ ។

ត្រីឆ្លាំងត្រីឆ្ដូញឆ្ងាញ់បវរ ត្រីក្រាញ់ឈ្ងួរឆរ និងសណ្ដាយ
ផ្ទក់រស់ត្រីធំត្រីខ្លាំងហាយ បង្កងរតាយសាច់ស្រស់ៗ ។

សូមស្នេះត្រឹមនេះរាប់មិនអស់ នៅត្រីស្រស់ៗ សូមចន្លោះ
សំបូរយ៉ាំងឯកមានឥតខ្ចោះ រាប់សល់ចោះៗ កុំថាអី ។

ផ្ទៃរាបដែនដីសំបូរជីរ
ប្រជារក់រីយ៉ាងខ្លាតខ្មី
ស្រូវខ្សាយដំណើបស្រូវសាលី
សណ្តែកដីធីឱជារស់ ។

ពោតសក្រហមល្ងបានផ្លៃ
លក់បានកំរៃត្រូវតែព្រោះ
កៅស៊ូពិសេសមានកិត្តិយស
ពួកយើងកុំដោះត្រូវតែដាំ ។

កង់ឡានតូចធំយ៉ាងដេរដាស
ស្បែកជើងក្មេងចាស់គួរចំណាំ
ស្ថិតជាប់បានយូរជាប្រចាំ
មិនសូវសាំញ៉ាំពាក់គ្រប់គ្នា ។

ផយោ ! សម្បត្តិធម្មជាតិជា
នៅជិតមីងមាអ៊ំពុំងា
ជួយថែរក្សារាល់ផងគ្នា
ចំណោញវេលាដល់ប្រជា ។

យើងខ្ញុំសូមលើកហត្ថប្រណម
យើងខំរៀបចំមិនសូវជា
ព្រោះយើងនៅហាត់រៀនវិជ្ជា
និងពេលវេលាមិនគ្រប់គ្រាន់ ។

**វ៉ូច ផេងសែ**
សមាសភាគីប្រចាំតំបន់ខេត្តដាច់ស្រយាល

# ដំណឹងមរណភាព

គណៈកម្មាធិការនាយកនៃស.ប.ស.ខ សូមជូនពត៌មានថា ៖ ក្នុងរយៈពេលបីខែ បន្តពីខែ មីនា ឆ្នាំ១៩៩៧ គឺខែ មេសា ឧសភា មិថុនា កក្កដា សីហា កញ្ញា និង តុលា ឆ្នាំ ១៩៩៧ សមាជិក សមាជិកាយើង បានទទួលអនិច្ចកម្មមានកំនើនទាំងអស់ចំនួន : **២០១ នាក់** ។ រីឯគូស្រករ ( ប្ដី រឺ ប្រពន្ធ ) ចំនួន : **១៥៤ នាក់** ដូចតារាងខាងក្រោម ៖

| ល.រ | ឈ្មោះខេត្ត - ក្រុង | ចំនួនសព សមាជិក | ល.រ | ឈ្មោះខេត្ត - ក្រុង | ចំនួនសព សមាជិក | ផ្សេងៗ |
|---|---|---|---|---|---|---|
| | **មន្ទីរក្រសួងអប់រំយុវជននិងកីឡា** | | ១២ | ខេត្ត ស្វាយរៀង | ០៦ នាក់ | |
| ០១ | + អង្គភាពចំណុះ | ១៧ នាក់ | ១៣ | ខេត្ត ព្រៃវែង | ១៦ នាក់ | |
| ០២ | ខេត្ត តាកែវ | ១៦ នាក់ | ១៤ | ខេត្ត បាត់ដំបង | ១២ នាក់ | |
| ០៣ | ខេត្ត កំពង់ធំ | ១១ នាក់ | ១៥ | ខេត្ត កំពង់ឆ្នាំង | ០៦ នាក់ | |
| ០៤ | ខេត្ត សៀមរាប | ១៩ នាក់ | ១៦ | ខេត្ត កំពង់ស្ពឺ | ០៩នាក់ | |
| ០៥ | ខេត្ត កណ្ដាល | ១៨នាក់ | ១៧ | រាជធានីភ្នំពេញ | ១០ នាក់ | |
| ០៦ | ខេត្ត កំពង់ចាម | ២៦ នាក់ | ១៨ | ខេត្ត ពោធិសាត់ | ០៤ នាក់ | |
| ០៧ | ខេត្ត បន្ទាយមានជ័យ | ០៩ នាក់ | ១៩ | ខេត្ត ស្ទឹងត្រែង | ០០ នាក់ | |
| ០៨ | ខេត្ត កំពត | ១១នាក់ | ២០ | ខេត្ត កោះកុង | ០១ នាក់ | |
| ០៩ | ខេត្ត ក្រចេះ | ០៣ នាក់ | ២១ | ខេត្ត រតនគិរី | ០០ នាក់ | |
| ១០ | ក្រុងព្រះសីហនុ | ០២ នាក់ | ២២ | ខេត្ត មណ្ឌលគិរី | ០១ នាក់ | |
| ១១ | ក្រុង កែប | ០១នាក់ | ២៣ | ខេត្ត ព្រះវិហារ | ០៣នាក់ | |
| | | សរុប : | | | **២០១ នាក់** | |

| ល.រ | ឈ្មោះខេត្ត - ក្រុង | ចំនួនសពគ្រួសារ ប្ដី រឺ ប្រពន្ធ | ល.រ | ឈ្មោះខេត្ត - ក្រុង | ចំនួនសពគ្រួសារ ប្ដី រឺ ប្រពន្ធ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | **មន្ទីរក្រសួងអប់រំ យុវជន និងកីឡា** | | ១២ | ខេត្ត ស្វាយរៀង | ០៦ នាក់ | |
| ០១ | + អង្គភាពចំណុះ | ០៥ នាក់ | ១៣ | ខេត្ត ព្រៃវែង | ០៨ នាក់ | |
| ០២ | ខេត្ត តាកែវ | ១១នាក់ | ១៤ | ខេត្ត បាត់ដំបង | ០៦ នាក់ | |
| ០៣ | ខេត្ត កំពង់ធំ | ១១ នាក់ | ១៥ | ខេត្ត ព្រះវិហារ | ០៤ នាក់ | |
| ០៤ | ខេត្ត សៀមរាប | ២១ នាក់ | ១៦ | ខេត្ត កំពង់ឆ្នាំង | ០២នាក់ | |
| ០៥ | ខេត្ត កណ្ដាល | ១៦ នាក់ | ១៧ | ខេត្ត កំពង់ស្ពឺ | ១៤ នាក់ | |
| ០៦ | ខេត្ត កំពង់ចាម | ១៥ នាក់ | ១៨ | រាជធានីភ្នំពេញ | ១១ នាក់ | |
| ០៧ | ខេត្ត បន្ទាយមានជ័យ | ០៥ នាក់ | ១៩ | ខេត្ត ពោធិសាត់ | ០២ នាក់ | |
| ០៨ | ខេត្ត កំពត | ០៦ នាក់ | ២០ | ខេត្ត ស្ទឹងត្រែង | ០២ នាក់ | |
| ០៩ | ខេត្ត ក្រចេះ | ០៧ នាក់ | ២១ | ខេត្ត កោះកុង | ០០ នាក់ | |
| ១០ | ក្រុងព្រះសីហនុ | ០០នាក់ | ២២ | ខេត្ត រតនគិរី | ០១ នាក់ | |
| ១១ | ខេត្ត មណ្ឌលគិរី | ០១នាក់ | ២៣ | ក្រុងកែប | ០០ នាក់ | |
| | | សរុប : | | | **១៥៤ នាក់** | |

អប់រំ គឺ ជាភារកិច្ច របស់ យើងទាំងអស់គ្នា

រោងពុម្ព ក្រសួងអប់រំ